CamboJA

សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា

*Cambodian Journalists Alliance Association*



# របាយការណ៍ស្តីពីស្ថានភាពសារព័ត៌មាន នៅកម្ពុជាឆ្នាំ២០២៤

## កំណត់ត្រាប្រចាំឆ្នាំស្តីពីករណីយាយីប្រឆាំងអ្នកសាព័ត៌មាន

# មាតិកា


I. សេចក្តីសង្ខេប ៣

II. សេចក្តីផ្តើម ៥

III. វិធីសាស្ត្រប្រមូលទិន្នន័យ ៧

១. វិសាលភាព និងដែនកំណត់ ៨

២. ពាក្យគន្លឹះ ៩

IV. ការរកឃើញសំខាន់ៗ ១០

១. និន្នាការនៃការយាយីលើអ្នកសារព័ត៌មានពីមួយឆ្នាំទៅមួយឆ្នាំ ១១

ក. ប្រធានបទដែលបានរាយការណ៍ និងតួអង្គពាក់ព័ន្ធ ១១

ខ. ចំនួនករណីយាយីដែលបានកត់ត្រាតាមឆ្នាំនីមួយៗ ១៣

គ. ទីតាំងនៃករណីយាយី ១៤

ឃ. អ្នកសារព័ត៌មានត្រូវបានឃុំខ្លួន/ដាក់ពន្ធនាគារ ១៧

ង. អ្នកសារព័ត៌មានត្រូវបានសម្លាប់/មរណភាព ១៩

២. ប្រភេទនៃករណីយាយី ២០

V. សេចក្តីរាយការណ៍ ២២

១. អ្នកសារព័ត៌មាននៅខេត្តមណ្ឌលគិរីម្នាក់ស្លាប់ក្នុងគ្រោះថ្នាក់ចរាចរណ៍ ២២

២. អ្នកសារព័ត៌មានបានស្លាប់ដោយការបាញ់ប្រហារ ២៥

៣. អ្នកសារព័ត៌មានស្ត្រី និងបញ្ហាប្រឈម ២៦

VI. ស្ថានភាពទូទៅនៃវិស័យសារព័ត៌មាន ៣១

VII. សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ៣៦

VIII. ឧបសម្ព័ន្ធ ៣៩

# I. សេចក្តីសង្ខេប

របាយការណ៍ប្រចាំឆ្នាំលើកទី៥ដែលបានចេញផ្សាយដោយខេមបូចា ចាប់តាំងពីការចាប់ផ្តើមដំណើរការ ពួកយើងបានកត់ត្រានូវសកម្មភាពពេញមួយឆ្នាំក្នុងអាណត្តិដំបូងរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត ក្រោយពីចូលកាន់តំណែងបន្តពីឪពុករបស់លោក ដែលតំណាងឱ្យអ្នកដឹកនាំជំនាន់ថ្មី។

រដ្ឋាភិបាលបានចាប់ផ្តើមជាមួយនឹងកង្វះការការពារអ្នកសារព័ត៌មាន និងសិទ្ធិរបស់ពួកគេដែលមានចែងក្នុងច្បាប់។ សេរីភាពសារព័ត៌មាននៅកម្ពុជាត្រូវបានកត់សម្គាល់ពីការធ្លាក់ចុះមួយកម្រិតទៀតដែលក្នុងនោះរួមមានករណីពីរដែលបានកើតឡើងលើអ្នកសារព័ត៌មានហើយវាត្រូវបានផ្សព្វផ្សាយជាសកល។

ការបាញ់ប្រហារដ៏តក់ស្លុតបំផុតលើអ្នកសារព័ត៌មានក្នុងឆ្នាំ២០២៤ គឺការសម្លាប់លោក ឈឿង ឈឹង អ្នកយកព័ត៌មានអំពីបញ្ហាបរិស្ថានម្នាក់ ដែលត្រូវបានបាញ់ប្រហារកាលពីថ្ងៃទី៤ ខែធ្នូ។ នេះជាករណីបាញ់ប្រហារអ្នកសារព័ត៌មានជាលើកដំបូងនៅក្នុងប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ២០១៤ ដែលពេលនោះលោក តាំង ទ្រី ត្រូវបានសម្លាប់ ខណៈកំពុងរាយការណ៍អំពីការកាប់ឈើខុសច្បាប់ផងដែរ។

ការចាប់ខ្លួនអ្នកសារព័ត៌មានដែលទទួលបានពានរង្វាន់ លោក ម៉ិច ដារ៉ា កាលពីថ្ងៃទី៣០ ខែកញ្ញា បានរងនូវប្រតិកម្មពីសំណាក់ក្រុមសង្គមស៊ីវិលជាតិ អន្តរជាតិ ស្ថាប័នប្រព័ន្ធផ្សព្វផ្សាយ និងរដ្ឋាភិបាលបរទេស។ លោក ដារ៉ា ត្រូវបានដោះលែងបន្ទាប់ពីឃុំខ្លួនអស់រយៈពេលជិតមួយខែ ប៉ុន្តែនៅតែប្រឈមមុខនឹងការចោទប្រកាន់ពីបទ «ញុះញង់បង្កឱ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម»ជុំវិញការបង្ហោះរូបភាពតាមបណ្តាញសង្គម។

ខេមបូចា ក៏បានធ្វើការស៊ើបអង្កេតអំពីករណីអ្នកសារព័ត៌មាននៅខេត្តមណ្ឌលគិរីម្នាក់ ដែលត្រូវបានស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍ ប៉ុន្តែសហការីរបស់គាត់បានដាក់ការសង្ស័យលើឧប្បត្តិហេតុនេះ។

ករណីទាំងនេះបានចង្អុលបង្ហាញពីការយាយីកាន់តែអាក្រក់លើអ្នកសារព័ត៌មាននៅកម្ពុជា។

ក្នុងឆ្នាំ២០២៤ យើងបានកត់ត្រាការយាយីចំនួន ៤១ករណី ដែលមានអ្នកសារព័ត៌មានយ៉ាងហោចណាស់ ៦៤នាក់ត្រូវរងផលប៉ះពាល់ ក្នុងនោះអ្នកសារព័ត៌មានស្ត្រីចំនួន ២នាក់។ ក្នុងចំណោមករណីសរុប មាន២៨ករណីជាការយាយីផ្នែកច្បាប់ បើធៀបនឹងឆ្នាំ២០២៣ ដែលមានតែ១៥ករណីប៉ុណ្ណោះ។

ចំនួននេះបានកើនឡើង ២៨ភាគរយ នៃករណីសរុប បើធៀបទៅនឹងឆ្នាំ២០២៣ ដែលមានចំនួន ៣២ករណី និងប៉ះពាល់អ្នកសារព័ត៌មានចំនួន ៥៥នាក់។ បើធៀបករណីគំរាមកំហែងតាមផ្លូវច្បាប់កើនឡើងរហូតដល់ ៨៧ភាគរយ។

ខណៈដែលចំនួនទាំងនេះបង្កជាការព្រួយបារម្ភ យើងក៏មានការប្រយ័ត្នប្រយែងដែរក្នុងការទាញសេចក្តីសន្និដ្ឋានពីតួលេខទាំងនេះ ព្រោះយើងកត់សម្គាល់ថា ការកត់ត្រានេះនៅតែមានការខ្វះចន្លោះ ដោយសារករណីខ្លះត្រូវបានគេលាក់លៀមមិនលាតត្រដាង ហើយអ្នកសារព័ត៌មានខ្លះ ខ្លាចអាមិនហ៊ានរាយការណ៍ ព្រោះខ្លាចមានការគុំគួនមកលើខ្លួន។

យើងក៏កត់សម្គាល់ផងដែរថា មានអ្នកសារព័ត៌មានយ៉ាងហោចណាស់៥នាក់ បានរងការចោទប្រកាន់ និងត្រូវបានឃុំខ្លួនក្នុងពន្ធនាគារកាលពីឆ្នាំ២០២៤ ខណៈអ្នកផ្សេងទៀតត្រូវបានឃាត់ និងឃុំខ្លួនពីមន្ត្រីនគរបាលដើម្បីសួរចម្លើយ។

ដូចកាលពីឆ្នាំមុនៗដែរ ការឃាយឺ និងការបំភិតបំភ័យភាគច្រើនត្រូវបានធ្វើឡើងដោយតួអង្គរដ្ឋ ដូចជាមន្ត្រីយោធា អភិបាលស្រុក/ខេត្ត និងអាជ្ញាធរមូលដ្ឋាន ហើយភាគច្រើនទាក់ទងនឹងសេចក្ដីរាយការណ៍ពីបរិស្ថាន ឬការចោទប្រកាន់ពីការរំលោភបំពានអំណាច និងអំពើពុករលួយផ្សេងៗ។

ប្រហែលជាការអភិវឌ្ឍ ដ៏សំខាន់មួយរបស់រដ្ឋាភិបាលចំពោះវិស័យសារព័ត៌មាន នោះគឺការដាក់ចេញនូវជម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មានដោយក្រសួងព័ត៌មាន ដែលទំនងជាមានគោលបំណងប្រឆាំងនឹង «ព័ត៌មានមិនពិត» និងលើកកម្ពស់ក្រមសីលធម៌វិជ្ជាជីវៈក្នុងវិស័យនេះ។

ក្រុមអ្នកសារព័ត៌មាន និងអ្នកជំនាញរបស់អង្គការសហប្រជាជាតិបានរិះគន់កិច្ចខិតខំប្រឹងប្រែងនេះ ថាខ្វះការពិគ្រោះយោបល់ដ៏ទូលំទូលាយ និងដំណោះស្រាយត្រឹមត្រូវសម្រាប់ប្រព័ន្ធផ្សព្វផ្សាយនៅពេលដែលមានកំហុសជាក់ស្តែង។

ការផ្តន្ទាទោសព្រហ្មទណ្ឌលើអ្នកសារព័ត៌មានត្រូវបានកើតឡើងជារឿយៗ។ ការផ្តន្ទាទោសព្រហ្មទណ្ឌមិនគួរត្រូវគេធ្វើឡើងចំពោះអ្នកសារព័ត៌មានឡើយ លុះត្រាតែដំណោះស្រាយតាមរយៈច្បាប់ស្តីពីរបបសារព័ត៌មានរបស់ប្រទេសកម្ពុជាត្រូវបានប្រើអស់។ យើងជឿថា ការគំរាមកំហែងចាប់ដាក់ពន្ធនាគារ និងការឃុំខ្លួន គឺជាវិធី ដែលគេប្រើដើម្បីបំបិទសំឡេងអ្នកសារព័ត៌មាន និងធ្វើឱ្យអ្នកសារព័ត៌មានរឹតត្បិតលើខ្លួនឯង។

ក្រសួងព័ត៌មានក៏បានចេញផ្សាយរបាយការណ៍ស្តីពីស្ថានភាពសារព័ត៌មាននៅកម្ពុជាកាលពីខែមេសា ដែលបានអះអាងថាជិត ៨០% នៃអ្នកសារព័ត៌មានចំនួន ៣៤១នាក់ ដែលត្រូវបានស្ទង់មតិបាននិយាយថា សេរីភាពសារព័ត៌មាននៅកម្ពុជាមានស្ថានភាព «ល្អ» ឬ «ល្អប្រសើរ» ។

អង្គការអ្នកសារព័ត៌មានគ្មានព្រំដែន បានដាក់ចំណាត់ថ្នាក់កម្ពុជាលើសន្ទស្សន៍សេរីភាពសារព័ត៌មានពិភពក្នុងចំណាត់ថ្នាក់ទី១៥១ ក្នុងចំណោម ១៨០ ប្រទេស ដោយធ្លាក់ចុះពី១៤៧ ក្នុងឆ្នាំ ២០២៣ ។

មាត្រា៤១ នៃរដ្ឋធម្មនុញ្ញរបស់កម្ពុជាចែងថា ពលរដ្ឋត្រូវបានធានានូវ«សេរីភាពនៃការបញ្ចេញមតិ សេរីភាពសារព័ត៌មាន សេរីភាពនៃការបោះពុម្ពផ្សាយ និងសេរីភាពក្នុងការជួបជុំគ្នា»។

ទោះបីវាហាក់នៅឆ្ងាយពីការធ្វើឱ្យរឿងនេះក្លាយជាការពិត ប៉ុន្តែ ខេមបូចា ប្តេជ្ញាថានឹងបង្ហាញការយកចិត្តទុកដាក់ចំពោះអ្នកសារព័ត៌មានក្នុងប្រទេស មិនថាស្ថិតក្នុងកាលៈទេសៈណាក៏ដោយ។ យើងជឿជាក់ថាប្រទេសរបស់យើងនឹងមានស្ថានភាពកាន់តែប្រសើរឡើង ប្រសិនបើពលរដ្ឋអាចបញ្ចេញមតិដោយមិនមានការភ័យខ្លាច ហើយអ្នកសារព័ត៌មានអាចធ្វើការងាររបស់ពួកគេដោយសុវត្ថិភាព។

# II. សេចក្តីផ្តើម

របាយការណ៍ប្រចាំឆ្នាំរបស់ខេមបូចា ស្តីពីស្ថានភាពអ្នកសារព័ត៌មាននៅកម្ពុជា គឺជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងរបស់យើង ក្នុងការឃ្លាំមើល និងតស៊ូមតិដើម្បីសេរីភាពសារព័ត៌មាននៅកម្ពុជា។ អ្នកសារព័ត៌មានគួរតែមានសេរីភាពក្នុងការធ្វើការងាររបស់ពួកគេដោយផ្តល់ព័ត៌មានដល់សាធារណជនក្នុងការសម្រេចចិត្ត ដោយមិនមានការភ័យខ្លាច ការគំរាមកំហែងលើរាងកាយ ការយាយីតាមផ្លូវច្បាប់ និងជំរុញឱ្យអ្នកមានអំណាចទទួលខុសត្រូវ។

សម្រាប់ឆ្នាំទីប្រាំនៃដំណើរការរបាយការណ៍នេះ វាបានបង្ហាញថាអ្នកសារព័ត៌មានមានហេតុផលសមស្របដែលបង្ហាញថា ពួកគេមានការភ័យខ្លាចចំពោះអាជីព សេរីភាព សុវត្ថិភាព ហើយក្នុងករណីធ្ងន់ធ្ងរបំផុតគឺសុវត្ថិភាពលើអាយុជីវិតរបស់ពួកគេ នៅពេលដែលពួកគេរាយការណ៍អំពីប្រធានបទរសើបដែលទាក់ទងនឹងបុគ្គលមានអំណាច និងអង្គភាពណាមួយ។

អ្នកសារព័ត៌មាននៅតែទទួលរងនូវការយាយី ការបំភិតបំភ័យ ការរើសអើង ចំណាត់ការផ្លូវច្បាប់ និងការឃុំខ្លួនដើម្បីសាកសួរ ឬបង្ខាំងនៅខុសកន្លែង និងពេលវេលាជាដើម។ ជាមួយគ្នា អ្នកសារព័ត៌មានទាំងនេះទំនងជាប្រឈមមុខនឹងការផ្តន្ទាទោសច្រើនជាងជន ដែលប្រព្រឹត្តល្មើស។

ទោះមើលទៅស្ថានភាពលទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជាមានភាពទូលំទូលាយប៉ុន្តែសេរីភាពសារព័ត៌មានបច្ចុប្បន្ននៅតែស្ថិតក្នុងកម្រិតទាប។

ក្នុងទស្សវត្សរ៍ចុងក្រោយនេះ អង្គភាពសារព័ត៌មានដែលទទួលបានប្រជាប្រិយភាពជាច្រើនក្នុងស្រុកត្រូវបានបិទ ឬធ្វើឱ្យរួមតូច ដោយសារការរាយការណ៍រិះគន់រដ្ឋាភិបាល។ ឧទាហរណ៍ថ្មីៗជាក់ស្តែង វិទ្យុសំឡេងប្រជាធិបតេយ្យ (វីអូឌី) ត្រូវបានលោក ហ៊ុន សែន ដែលកាលនោះជានាយករដ្ឋមន្ត្រី បញ្ជាឱ្យបិទនៅឆ្នាំ២០២៣ បន្ទាប់ពីមិនពេញចិត្តនឹងការរាយការណ៍មួយ។

ខេមបូចា សង្ឃឹមថា មេដឹកនាំជំនាន់ថ្មីក្រោមការដឹកនាំរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត នឹងចាត់វិធានការយ៉ាងម៉ឺងម៉ាត់ដើម្បីការពារអ្នកសារព័ត៌មាន ទៅតាមអនុសាសន៍ដាក់ជូនដោយខេមបូចា ក៏ដូចជាអ្នកឃ្លាំមើលប្រព័ន្ធផ្សព្វផ្សាយផ្សេងទៀត។

នៅពេលដែលនាយករដ្ឋមន្ត្រីថ្មីបាននិយាយអំពីការធ្វើទំនើបកម្មវិស័យប្រព័ន្ធផ្សព្វផ្សាយ ការផ្លាស់ប្តូរភាគច្រើនគិតមកដល់ពេលនេះហាក់ឆ្លុះបញ្ចាំងពីចេតនា ក្នុងការបង្កើនការគ្រប់គ្រងរបស់រដ្ឋលើប្រព័ន្ធផ្សព្វផ្សាយ។ ក្នុងនោះក៏មានការព្រួយបារម្ភកាន់តែខ្លាំងឡើងថា ការអនុគ្រោះរបស់រដ្ឋាភិបាលមានកម្រិតចំពោះការមិនពេញចិត្ត នឹងនាំទៅដល់ការពង្រីកការត្រួតពិនិត្យ និងការរើសអើងចំពោះប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងអ្នកសារព័ត៌មាន។

ការឃ្លាំមើលរបស់យើងបង្ហាញឱ្យឃើញនូវការព្រួយបារម្ភអំពីសុវត្ថិភាពអ្នកសារព័ត៌មាន ដោយសារហានិភ័យផ្លូវច្បាប់ ការឃ្លាំមើលរបស់រដ្ឋ និងការគំរាមកំហែងលើរាងកាយចំពោះអ្នកសារព័ត៌មាន ជាពិសេសអ្នកដែលរាយការណ៍ពីប្រធានបទរសើប។

បន្ថែមលើនេះ ក្រសួងព័ត៌មានហាក់មានការរើសអើងទៅលើការចេញបណ្ណសារព័ត៌មានឱ្យអ្នកសារព័ត៌មាន ស្របពេលដែលអាជ្ញាធរមួយចំនួនបដិសេធនិយាយជាមួយអ្នកសារព័ត៌មានដែលមានបណ្ណហួសសុពលភាព។ នេះជាបញ្ហាចម្បងសម្រាប់អ្នកសារព័ត៌មានឯករាជ្យ។

យោងតាមអត្ថបទចុះផ្សាយកាលពីខែកក្កដា របស់សារព័ត៌មានខេមបូចា បានលាតត្រដាង «យុទ្ធសាស្ត្រប្រតិបត្តិការជាប្រព័ន្ធ» ដែលត្រូវបានបង្កើតឡើងដើម្បីវាយប្រហារស្ថាប័នប្រព័ន្ធផ្សព្វផ្សាយជាភាសាខ្មែរ ដែលកំពុងប្រតិបត្តិការក្នុងប្រទេស និងខ្លះទៀតកំពុងនិរទេសខ្លួន ដោយសារការរាយការណ៍រិះគន់រដ្ឋាភិបាលកម្ពុជា។

ខេមបូចា និងសមាជិករបស់យើងស្វាគមន៍ការពិភាក្សាអំពីអនាគតនៃវិស័យប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា ដើម្បីធ្វើយ៉ាងណាអាចរក្សាបាននូវតុល្យភាពក្នុងការប្រយុទ្ធប្រឆាំងព័ត៌មានមិនពិត សន្តិសុខជាតិ និងសិទ្ធិដឹងឮជាសាធារណៈ។ ប៉ុន្តែអ្នកសារព័ត៌មានចាំបាច់ត្រូវចូលរួមក្នុងកិច្ចសន្ទនានេះ។

យើងសូមកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងព័ត៌មាន និងភាគីពាក់ព័ន្ធ ក្នុងការបង្កើនឱកាសសម្រាប់ការបណ្តុះបណ្តាលផ្នែកសារព័ត៌មាន ដើម្បីបង្កើនជំនាញ និងការរំពឹងទុករបស់អ្នកដែលធ្វើការក្នុងវិស័យនេះ។ ហើយច្បាប់របស់យើងអាចត្រូវបានពង្រឹង និងកែលម្អ ដើម្បីឆ្លុះបញ្ចាំងពីបរិយាកាសនាពេលបច្ចុប្បន្ននេះ ដោយមិនមានការរារាំងដល់អ្នកសារព័ត៌មាន។

គោលនយោបាយថ្មីគួរតែផ្តោតលើការការពារសារសំខាន់នៃសារព័ត៌មាននៅក្នុងលទ្ធិប្រជាធិបតេយ្យ មិនមែនសំដៅទៅលើការការពារកេរ្តិ៍ឈ្មោះរបស់អ្នកកាន់អំណាចនោះទេ។



# III. វិធីសាស្ត្រប្រមូលទិន្នន័យ

របាយការណ៍នេះ ប្រើវិធីសាស្ត្រប្រមូលទិន្នន័យបែបគុណវិស័យ។ ទិន្នន័យស្តីពីករណីយាយីមកលើអ្នកសារព័ត៌មាន ត្រូវបានចងក្រងដោយផ្អែកលើករណី ដែលគេបានរាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានផ្សេងៗ ការបង្ហោះតាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម និងសេចក្តីប្រកាសព័ត៌មានជាសាធារណៈរបស់តុលាការ។

ករណីទាំងនេះ ត្រូវបានផ្ទៀងផ្ទាត់តាមរយៈការពិនិត្យមើលឯកសារដែលមានស្រាប់ បណ្តាញប្រចាំខេត្តរបស់ខេមបូចា ការឃ្លាំមើលដំណើរការកាត់ក្តី និងបទសម្ភាសន៍ជាមួយមេធាវី អ្នកសារព័ត៌មានដែលរងគ្រោះ និងសមាជិកគ្រួសាររបស់ពួកគេ។ ចំពោះករណីពាក់ព័ន្ធនឹងអ្នកសារព័ត៌មាន ដែលរងការចោទប្រកាន់ពីបទកំហែងយកប្រាក់ ខេមបូចាបានចាត់ទុកករណីទាំងនេះថា ជាការយាយី បន្ទាប់ពីយើងធ្វើការស៊ើបអង្កេត ហើយបានរកឃើញភស្តុតាងថាសកម្មភាពនេះធ្វើឡើងដើម្បី គំរាមកំហែង បំភិតបំភ័យ ឬសកម្មភាពផ្សេងទៀត ដែលធ្វើឱ្យប៉ះពាល់ដល់សេរីភាពសារព័ត៌មាន។

ក្នុងនាមជាសមាជិកនៃសម្ព័ន្ធស្ថាប័នសារព័ត៌មានក្នុងតំបន់ ដែលបានចាប់ផ្តើម ដំណើរការកាលពីខែធ្នូ ឆ្នាំ២០២២ យើងបានរួមគ្នាឃ្លាំមើលការវាយប្រហារលើប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននៅអាស៊ីអាគ្នេយ៍ (ភាគច្រើនគឺនៅក្នុងប្រទេសកម្ពុជា ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន ទីម័រខាងកើត និងប្រទេសថៃ)។ វិធីសាស្ត្រឃ្លាំមើលរបស់យើងត្រូវបានកែសម្រួលនៅដើមឆ្នាំ ២០២៣ ដើម្បីឱ្យស្របនឹងសូចនាករក្នុងតំបន់ ដែលតាមដានបញ្ហាសុវត្ថិភាពរបស់អ្នកសារព័ត៌មាន ដោយផ្អែកលើទិដ្ឋភាពសំខាន់បីគឺ សុវត្ថិភាពផ្លូវច្បាប់ សុវត្ថិភាពឌីជីថល និងសុវត្ថិភាពផ្នែករាងកាយ។ យើងក៏បានកត់ត្រាពីសកម្មភាពនានា ដែលអាចបង្កគ្រោះថ្នាក់ បំភិតបំភ័យ រារាំង ឬបំបិទមាត់អ្នកសារព័ត៌មាន ដោយគ្មានច្បាប់ទម្លាប់ ឬហេតុផលស្របច្បាប់ ឬរារាំងស្ថាប័នសារព័ត៌មាន ឬអ្នកសារព័ត៌មានមិនឱ្យបំពេញភារកិច្ចជាអ្នកសារព័ត៌មានរបស់ពួកគេដោយសុវត្ថិភាព និងឯករាជ្យ ក៏ដូចជាការវិវឌ្ឍណាមួយដែលនាំមកនូវផលប៉ះពាល់អវិជ្ជមានចំពោះសេរីភាពសារព័ត៌មានផងដែរ។

## ១. វិសាលភាព និងដែនកំណត់

របាយការណ៍នេះមានដែនកំណត់ និងភាពចន្លោះប្រហោងខ្លះ។ របាយការណ៍នេះ មិនរាប់បញ្ចូលគ្រប់ករណីយាយីលើអ្នកសារព័ត៌មានទាំងអស់នៅក្នុងត្រីមាសនេះទេ ដោយបញ្ចូលតែករណីដែលត្រូវបានរាយការណ៍ និងរកឃើញតាមរយៈការស្រាវជ្រាវរបស់ខេមបូចាប៉ុណ្ណោះ។ វាអាចថា មានករណីផ្សេងទៀតជាច្រើនមិនត្រូវបានរាយការណ៍ ដោយសារអ្នកសារព័ត៌មានជារឿយៗប្រឈមនឹងការយាយីនៅតាមបណ្តាខេត្ត ទីដែលករណីទាំងនោះទំនងជាត្រូវបានបន្តបិទបាំង ដោយសារធនធានសម្រាប់ការឃ្លាំមើល និងជំនួយផ្នែកច្បាប់នៅមានកម្រិត។

## ២. ពាក្យគន្លឹះដែលប្រើប្រាស់ក្នុងរបាយការណ៍នេះត្រូវបានកំណត់ដូចខាងក្រោម៖

**អ្នកសារព័ត៌មាន៖** គឺសំដៅដល់បុគ្គលិកព័ត៌មាន ដូចជាអ្នកសារព័ត៌មាន អ្នកសារព័ត៌មានសេរី អ្នកថតរូបសារព័ត៌មាន បុគ្គលិកគាំទ្រ និងអ្នកសម្របសម្រួល អ្នកកាន់បណ្ណសារព័ត៌មានដែលចេញដោយ ក្រសួងព័ត៌មាន ឬកាន់កាតសម្គាល់ខ្លួន ចេញដោយស្ថាប័នព័ត៌មានរបស់ពួកគេ អ្នកដែលសកម្មក្នុងបណ្ដាញ សារព័ត៌មានសហគមន៍ និងអ្នកសារព័ត៌មានពលរដ្ឋ។ ពាក្យអ្នកសារព័ត៌មាននេះមិនរាប់បញ្ចូលអ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម ដែលគ្មានវិញ្ញាបនបត្រវិជ្ជាជីវៈនោះទេ។

**ការយាយីតាមផ្លូវច្បាប់៖** គឺសំដៅដល់វិធានការផ្លូវច្បាប់ ឬតុលាការ/ការគំរាមកំហែងអ្នកសារព័ត៌មាន រួមទាំងពាក្យបណ្ដឹង ការចោទប្រកាន់ ការឃុំខ្លួនក្នុងពន្ធនាគារ (ការឃុំខ្លួនបណ្ដោះអាសន្នមុនពេលជំនុំជម្រះ លើបទចោទជាក់លាក់ ឬការឃុំខ្លួនក្នុងពន្ធនាគារបន្ទាប់ពីការផ្តន្ទាទោស) ការឃាត់ខ្លួន (ឃាត់ខ្លួនដើម្បីសាកសួរពីរបីម៉ោង ឬពេញមួយយប់ ប៉ុន្តែមិនត្រូវ បានចោទប្រកាន់ ឬឃុំខ្លួនក្នុងពន្ធនាគារ) ការព្យួរ /ការលុប អាជ្ញាបណ្ណព័ត៌មាន (ការប្រើប្រាស់អំណាចនីតិប្រតិបត្តិដើម្បីព្យួរ/លុបចោលអាជ្ញាបណ្ណរបស់ស្ថាប័នព័ត៌មានជាក់លាក់មួយដោយគ្មានការកាត់ក្ដីត្រឹមត្រូវ) ការសួរចម្លើយ ការកោះហៅមកសាកសួរ និងការចាប់ខ្លួន (ដែលអាច ឬមិនអាចឈានដល់ការចោទប្រកាន់ជាផ្លូវការ ប៉ុន្តែយ៉ាងហោចណាស់ពាក់ព័ន្ធ នឹងការត្រូវអាជ្ញាធរឃាត់ខ្លួនបណ្ដោះអាសន្នដែរ) និងសកម្មភាពផ្សេងទៀតដែលពាក់ព័ន្ធនឹងការប្រើវិធានការផ្លូវច្បាប់ ដើម្បីបំបិទមាត់អ្នកសារព័ត៌មាន និងស្ថាប័នព័ត៌មាន ។

**ការយាយីលើរាងកាយ៖** គឺសំដៅដល់ករណីវាយដំលើរាងកាយ ការបំផ្លិចបំផ្លាញសម្ភារ និងទ្រព្យសម្បត្តិផ្ទាល់ខ្លួន /ទ្រព្យសម្បត្តិផ្សេងទៀតរបស់ស្ថាប័នព័ត៌មានការឃាត់ខ្លួនដោយមិនឆ្លងកាត់នីតិវិធីច្បាប់ ការបៀតបៀនផ្លូវភេទ ការបំភិតបំភ័យ លើរាងកាយ និងករណីផ្សេងៗទៀតដែលពាក់ព័ន្ធនឹងកាយវិការ ឬមានបំណងបង្កគ្រោះថ្នាក់ដល់រាងកាយ។

**ការយាយីតាមប្រព័ន្ធឌីជីថល៖** គឺសំដៅដល់ករណីនៃការធ្វើបាបតាមប្រព័ន្ធ អ៊ីនធឺណិត ការត្រូល ការបំភិតបំភ័យតាមប្រព័ន្ធ អ៊ីនធឺណិត ការបៀតបៀនផ្លូវភេទតាមប្រព័ន្ធអ៊ីនធឺណិត ការបិទប្រព័ន្ធអ៊ីនធឺណិត ការលួចចូលក្នុងប្រព័ន្ធកុំព្យូទ័រ ខុសច្បាប់ ការវាយប្រហារបែប DDos ការបង្ហាញព័ត៌មាន ឯកជនរបស់អ្នកសារព័ត៌មាន និងការផ្សាយព័ត៌មានមិនពិត/ការបង្ខូចកេរ្តិ៍ឈ្មោះ។

**ការរឹតត្បិត/ការរើសអើង៖** គឺសំដៅដល់ករណីដែលក្នុងនោះមន្ត្រី ឬស្ថាប័នបានផ្ដោតគោលដៅលើប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ឬរារាំងមិនឱ្យចូលយកព័ត៌មានចំពោះ អ្នកសារព័ត៌មាន ដែលគេមើលឃើញថារិះគន់រដ្ឋាភិបាល ។ ចំណុចនេះក៏សំដៅដល់ករណីដែលអាជ្ញាធរបានចេញសេចក្ដីព្រមានមិនផ្លូវការ ឬក៏បញ្ជាឱ្យអ្នកសារព័ត៌មានចាកចេញពីកន្លែងមួយក្នុងបំណងបិទបាំងព័ត៌មានមិនឱ្យចុះផ្សាយ ឬរារាំងអ្នកសារព័ត៌មានមិនឱ្យចូលយកព័ត៌មាន។



# IV. ការរកឃើញសំខាន់ៗ

# ១. និន្នាការនៃការយាយីលើអ្នកសារព័ត៌មានពីមួយឆ្នាំទៅមួយឆ្នាំ

ខេមបូចា បានកត់ត្រាករណីយាយីចំនួន៤១ ទៅលើអ្នកសារព័ត៌មានយ៉ាងហោចណាស់៦៤នាក់ក្នុងឆ្នាំ២០២៤។ ប្រភេទនៃការយាយី ដែលជួបប្រទះញឹកញាប់បំផុត គឺការគំរាមកំហែងផ្នែកផ្លូវច្បាប់ ហើយក្នុងនោះ ខេមបូចាបានកត់ត្រារហូតដល់ ២៨ករណី រួមមានចំណាត់ការផ្លូវច្បាប់ ការដកអាជ្ញាបណ្ណ ការចាប់ខ្លួន ឃុំខ្លួនសួរចម្លើយ ឬដាក់ពន្ធនាគារ។

ក្នុងចន្លោះពីខែមករា ដល់ខែធ្នូ ឆ្នាំ២០២៤ ខេមបូចា បានកត់ត្រាអ្នកសារព័ត៌មានចំនួន ៥នាក់ត្រូវបានឃុំខ្លួនបណ្ដោះអាសន្ន និង/ឬ ផ្តន្ទាទោសដោយសារការបំពេញការងាររបស់ពួកគេ។

ខេមបូចាក៏បានកត់ត្រាករណីយាយីផ្នែករាងកាយចំនួន ៦ករណី ដូចជា ការវាយបំផ្លាញឧបករណ៍និងទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់អ្នកសារព័ត៌មាន និងឃាតកម្មលើអ្នកសារព័ត៌មាននៅអង្គភាពកម្ពុជាអភិវឌ្ឍន៍ប្រចាំខេត្តសៀមរាប លោក ឈឿង ឈឹង។

លើសពីនេះករណីរើសអើង ឬការបំភិតបំភ័យចំនួន ៧ករណីត្រូវបានកត់ត្រា ដែលក្នុងនោះអ្នកសារព័ត៌មានបានទទួលអារម្មណ៍ថាគ្រោះថ្នាក់ ឬមិនត្រូវបានស្វាគមន៍នៅកន្លែងដែលពួកគេមានសិទ្ធិចុះទៅបំពេញការងារ។ យើងបានកត់ត្រាទៀតថា អាជ្ញាបណ្ណអង្គភាពសារព័ត៌មានយ៉ាងហោចណាស់ ៣ ត្រូវបានដកហូត។

ឆ្នាំនេះ ការរាយការណ៍អំពីប្រធានបទដ៏ចម្រូងចម្រាសដូចជាការកាប់បំផ្លាញព្រៃឈើ និងបញ្ហាបរិស្ថាន ដែលមាន១៦ ករណី ជាញឹកញាប់បាននាំឲ្យមានការយាយីលើអ្នកសារព័ត៌មាន បន្ទាប់មកគឺការរាយការណ៍ពីវិវាទដីធ្លី ដែលមាន៧ ករណី ។

ករណីភាគច្រើនដែលបានកត់ត្រាក្នុងឆ្នាំ ២០២៤ ត្រូវបានបង្ករឡើងដោយតួអង្គរដ្ឋ ដែលមានរហូតដល់ ២៦ ករណីហើយភាគច្រើនជាប់ទាក់ទងនឹងបញ្ហាបរិស្ថាន។

## ក. ប្រធានបទដែលបានរាយការណ៍ និងតួអង្គពាក់ព័ន្ធ

ជារួមករណីនៃការយាយី ជាញឹកញាប់ទាក់ទងទៅនឹងការរាយការណ៍អំពីការកាប់បំផ្លាញព្រៃឈើ និងបញ្ហាបរិស្ថាន បន្ទាប់មកដោយវិវាទដីធ្លី និងការឆបោកតាមអនឡាញ។

អ្នកសារព័ត៌មានអនឡាញ ជាពិសេសអ្នកដែលផ្សព្វផ្សាយលើបណ្តាញសង្គមហ្វេសប៊ុក ប្រឈមមុខនឹងការយាយីជាងអ្នកសារព័ត៌មានដែលធ្វើការនៅតាមអង្គភាពបែបប្រពៃណី ដូចជាកាសែត និងស្ថានីយ៍ទូរទស្សន៍/វិទ្យុ។

ករណីភាគច្រើនដែលបានកត់ត្រាពាក់ព័ន្ធតួអង្គជាមន្ត្រីសាធារណៈ ដូចជាមន្ត្រីនគរបាល អភិបាលខេត្ត /ស្រុកនិងអាជ្ញាធរមូលដ្ឋាន។ ក្នុងករណីជាច្រើន អ្នកសារព័ត៌មានត្រូវបានចោទប្រកាន់ពីបទញុះញង់ និងបរិហារកេរ្តិ៍ពាក់ព័ន្ធនឹងការរាយការណ៍ដែលប៉ះពាល់ដល់មុខមាត់អាជ្ញាធរ និងបុគ្គលមានអំណាច។

ក្រាហ្វិចទី១ ៖ អំពីប្រធានបទដែលត្រូវបានរាយការណ៍




តារាងទី១ ៖ តួរអង្គពាក់ព័ន្ធ

| តួរអង្គ | ចំនួនករណី | ចំនួនអ្នកសារព័ត៌មានរងគ្រោះ | គិតជាភាគរយ |
|---|---|---|---|
| តួរអង្គរដ្ឋ | ២៦ | ៤៤ | ៦៤% |
| តួរអង្គមិនមែនរដ្ឋ (ក្រុមហ៊ុន) | ៥ | ៨ | ១២% |
| តួរអង្គមិនមែនរដ្ឋ (បុគ្គល) | ១០ | ១៣ | ២៤% |

ក្រាហ្វិចទី២ ៖ អំពីប្រភេទនៃសារព័ត៌មានដែលប៉ះពាល់




## ខ. ចំនួនករណីយាយីដែលបានកត់ត្រាតាមឆ្នាំនីមួយៗ

ក្នុងរយៈពេលប្រាំឆ្នាំ ពីឆ្នាំ ២០២០ ដល់ ២០២៤នេះ ខេមបូចាបានកត់ត្រានូវឧប្បត្តិហេតុនៃការយាយីអ្នកសារព័ត៌មានសរុបចំនួន ១៩២ករណី ប៉ះពាល់ដល់អ្នកសារព័ត៌មាន និងអ្នកធ្វើការក្នុងវិស័យប្រព័ន្ធផ្សព្វផ្សាយយ៉ាងហោចណាស់ ៣៤៥នាក់ (អ្នកសារព័ត៌មានស្ត្រី ២៣នាក់ ឬស្មើ ៧ភាគរយ)។

ទោះបីស្ថានការណ៍តែងតែប្រែប្រួលក្នុងអំឡុងពេលនេះ ប៉ុន្តែនិន្នាការនៃការយាយីលើអ្នកសារព័ត៌មាននៅកម្ពុជានៅបន្តជាក្តីបារម្ភ។

ក្នុងឆ្នាំ ២០២០ មានករណីយាយីសរុបចំនួន ៣៥ ប៉ះពាល់អ្នកសារព័ត៌មានចំនួន ៧២នាក់។ នៅឆ្នាំបន្ទាប់ គឺឆ្នាំ២០២១ មានចំនួន ៤៥ ប៉ះពាល់អ្នកសារព័ត៌មានចំនួន ៩៦នាក់។ ទោះបីយ៉ាងណា មានការថយចុះគួរឱ្យកត់សម្គាល់ក្នុងឆ្នាំ២០២២ ដែលមាន ៣៥ករណី ប៉ះពាល់ដល់អ្នកសារព័ត៌មានចំនួន ៥៤នាក់។ រីឯក្នុងឆ្នាំ ២០២៣ មានករណីចំនួន ៣២ ត្រូវបានកត់ត្រា ដែលប៉ះពាល់ដល់អ្នកសារព័ត៌មានចំនួន ៥៩នាក់។ ហើយក្នុងឆ្នាំ ២០២៤ បានបង្ហាញពីការកើនឡើងរហូតដល់ ៤១ ករណី ដែលប៉ះពាល់ដល់អ្នកសារព័ត៌មានចំនួន ៦៤ នាក់។

ចំនួនអ្នកសារព័ត៌មានស្ត្រីដែលរងផលប៉ះពាល់មានការប្រែប្រួល ដោយនៅឆ្នាំ២០២៤ មាន ២នាក់ និងកាលពីឆ្នាំ២០២២មាន ៨នាក់។ ទោះបីចំនួនអ្នកសារព័ត៌មានស្ត្រីរងផលប៉ះពាល់ថយចុះ ប៉ុន្តែវានៅតែមានសារៈសំខាន់ក្នុងការដោះស្រាយបញ្ហាប្រឈមរបស់អ្នកសារព័ត៌មានស្ត្រីដែលបន្តជាគោលដៅនៅក្នុងឧប្បត្តិហេតុទាំងនេះ។

ក្រាហ្វិចទី៣ ៖ បង្ហាញពីករណីដែលកត់ត្រាតាមឆ្នាំ (២០២០-២០២៤)



## គ. ទីតាំងនៃករណីយាយី

ទីតាំងដែលកើតឡើងញឹកញាប់បំផុតសម្រាប់ករណីយាយីក្នុងឆ្នាំ២០២៤នេះគឺរាជធានីភ្នំពេញ  បន្ទាប់មកគឺខេត្តមណ្ឌលគិរី និងខេត្តកណ្តាល ដែលមានចំនួន ៧ករណី និង៤ករណី។



តារាង២ បង្ហាញពីករណីដែលកើតឡើងតាមខេត្ត ក្រុង

| ខេត្ត / ក្រុង | ចំនួនករណី | គិតជាភាគរយ |
|---|---|---|
| ភ្នំពេញ | ៨ | ២០% |
| មណ្ឌលគិរី | ៤ | ១០% |
| កណ្ដាល | ៣ | ៧% |
| ស្ទឹងត្រែង | ៣ | ៧% |
| តាកែវ | ៣ | ៧% |
| បន្ទាយមានជ័យ | ៣ | ៧% |
| បាត់ដំបង | ២ | ៥% |
| ក្រចេះ | ២ | ៥% |
| ពោធិ៍សាត់ | ២ | ៥% |
| សៀមរាប | ២ | ៥% |
| រតនគិរី | ២ | ៥% |
| ព្រះវិហារ | ១ | ២% |
| ស្វាយរៀង | ១ | ២% |
| កំពង់ចាម | ១ | ២% |
| ព្រះសីហនុ | ១ | ២% |
| កំពង់ធំ | ១ | ២% |
| ឧត្ដរមានជ័យ | ១ | ២% |
| កែប | ១ | ២% |
| សរុប | ៤១ | |

## ឃ. អ្នកសារព័ត៌មានត្រូវបានឃុំខ្លួន/ដាក់ពន្ធនាគារ

ក្នុងអំឡុងខែមករា ដល់ខែធ្នូ ឆ្នាំ២០២៤ ខេមបូចា បានកត់ត្រាពីករណីអ្នកសារព័ត៌មាន ៥នាក់ ដែលត្រូវបានចាប់ និងឃុំខ្លួននៅពន្ធនាគារទាក់ទងនឹងការបំពេញការងាររបស់ពួកគេ។ អ្នកសារព័ត៌មាន ៣នាក់ត្រូវបានដោះលែងឱ្យនៅក្រៅឃុំ (អ្នកសារព័ត៌មាន ២នាក់ត្រូវបានកាត់ទោស) និង២នាក់ទៀតកំពុងស្ថិតក្នុងការឃុំខ្លួនបណ្ដោះអាសន្ន។

នៅចន្លោះខែឧសភា ដល់ខែធ្នូ ឆ្នាំ២០២៤ អ្នកសារព័ត៌មានជាច្រើនបានប្រឈមមុខនឹងការចោទប្រកាន់តាមផ្លូវច្បាប់ ដោយពួកគេជាច្រើនត្រូវបានឃុំខ្លួន ឬប្រឈមនឹងការជាប់ពន្ធនាគារ។

- **លោក សឿ សុជា** ជាអ្នកសារព័ត៌មាននៃអង្គភាព HPN News ប្រចាំខេត្តកំពង់ធំ ត្រូវបានចោទប្រកាន់ពីបទញុះញង់ឱ្យមានការរើសអើង និងត្រូវបានជាប់ពន្ធនាគារពីថ្ងៃទី២៤ ខែឧសភា ដល់ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២៤។
- **លោក វីរិទ្ធីយ៉ា** ជាអ្នកសារព័ត៌មានមកពីអង្គភាព GG TV Net ក្នុងខេត្តកណ្ដាល ត្រូវបានចោទប្រកាន់ពីបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ ហើយត្រូវបានឃុំខ្លួនពីថ្ងៃទី៦ ខែកក្កដា ដល់ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៤។
- **លោក ម៉ិច ដារ៉ា** អ្នកសារព័ត៌មានសេរី នៅរាជធានីភ្នំពេញ ប្រឈមនឹងការចោទប្រកាន់ពីបទញុះញង់បង្កឱ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម ជុំវិញការបង្ហោះរូបភាពតាមបណ្ដាញសង្គម។ លោកត្រូវបានឃុំខ្លួនជិតមួយខែនៅក្នុងពន្ធនាគារ ចាប់ពីថ្ងៃទី ៣០ ខែកញ្ញា ដល់ថ្ងៃទី ២៤ ខែតុលា ឆ្នាំ២០២៤។
- អ្នកសារព័ត៌មានពីរនាក់មកពីអង្គភាព SSB TV News នៃខេត្តកណ្ដាលគឺ**លោក សូ សំបូរ** និង**លោក នឿប ប៊ុន** ត្រូវបានចោទប្រកាន់ពីបទកំហែងហែកកេរ្តិ៍ ហើយត្រូវបានចាប់ខ្លួននៅថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ ២០២៤។ អ្នកទាំងពីរនៅតែស្ថិតក្នុងពន្ធនាគារគិតត្រឹមចុងឆ្នាំ២០២៤។

តារាងទី៣ បង្ហាញពីអ្នកសារព័ត៌មានដែលជាប់ឃុំនៅពន្ធនាគារ

| ឈ្មោះ អ្នកសារព័ត៌មាន | ស្ថាប័ន | ទីតាំង | ថ្ងៃចាប់ខ្លួន | ថ្ងៃដោះលែង | បទចោទ |
|---|---|---|---|---|---|
| សឿ សុជា | HPN News | កំពង់ធំ | ២៤ ឧសភា ២០២៤ | ៨ វិច្ឆិកា ២០២៤ | ញុះញង់ឱ្យមានការរើសអើង តាមមាត្រា៤៩៦នៃក្រម ព្រហ្មទណ្ឌ |
| រី រិទ្ធីយ៉ា | GG TV Net | កណ្ដាល | ៦ កក្កដា ២០២៤ | ១៤ សីហា ២០២៤ | ញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ជាអាទិ៍មាត្រា៤៩៥នៃក្រម ព្រហ្មទណ្ឌ និងមាត្រា ១០នៃ ច្បាប់ស្ដីពីរបបសារព័ត៌មាន |
| ម៉ិច ដារ៉ា | អ្នកសារព័ត៌មាន សេរី | ភ្នំពេញ | ៣០ កញ្ញា ២០២៤ | ២៤ តុលា ២០២៤ | ញុះញង់បង្កឱ្យមានភាពវឹកវរ ធ្ងន់ធ្ងរដល់សន្តិសុខសង្គម |
| សូ សំបូរ | SSB TV News | កណ្ដាល | ១៩ ធ្នូ ២០២៤ | កំពុងជាប់ឃុំ | កំហែងហែកកេរ្តិ៍ តាមមាត្រ ៣៧២ និង ៣៧៣នៃក្រម ព្រហ្មទណ្ឌ |
| នឿប ប៊ុន | SSB TV News | កណ្ដាល | ១៩ ធ្នូ ២០២៤ | កំពុងជាប់ឃុំ | កំហែងហែកកេរ្តិ៍ តាមមាត្រ ៣៧២ និង ៣៧៣នៃក្រម ព្រហ្មទណ្ឌ |

## ង. អ្នកសារព័ត៌មានត្រូវបានសម្លាប់/មរណភាព

អ្នកសារព័ត៌មាននៅខេត្តសៀមរាប លោក ឈឿង ឈឹង ត្រូវបានគេបាញ់ប្រហារ និងបានស្លាប់ដោយសាររបួសធ្ងន់ធ្ងរ។ វាជាឃាតកម្មលើកដំបូងលើអ្នកសារព័ត៌មានក្នុងប្រទេសកម្ពុជា ចាប់តាំងពីឆ្នាំ ២០១៤ ពេលដែលលោក តាំង ទ្រី ត្រូវបានសម្លាប់ ខណៈកំពុងរាយការណ៍អំពីការកាប់ឈើខុសច្បាប់ដូចគ្នា។

ខេមបូចា ក៏បានធ្វើការស៊ើបអង្កេតអំពីករណីអ្នកសារព័ត៌មាននៅខេត្តមណ្ឌលគិរីម្នាក់ដែលត្រូវបានស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍នៅពេលធ្វើដំណើរត្រឡប់មកផ្ទះ។ នេះបើតាមការបញ្ជាក់របស់មន្ត្រីនគរបាល ប៉ុន្តែសហការីរបស់គាត់បានដាក់ការសង្ស័យលើឧប្បត្តិហេតុនេះ។

តារាងពី៤ អំពីអ្នកសារព័ត៌មានដែលត្រូវបានសម្លាប់/ស្លាប់

| ឈ្មោះ អ្នកសារព័ត៌មានរងគ្រោះ | ស្ថាប័ន | ខេត្ត ក្រុង | ថ្ងៃកើតហេតុ | មូលហេតុ |
|---|---|---|---|---|
| **ឈឿង ឈឹង** | កម្ពុជាអភិវឌ្ឍន៍ | សៀមរាប | គាត់ត្រូវបានបាញ់នៅថ្ងៃទី៤ ធ្នូ ២០២៤ និងបានស្លាប់នៅថ្ងៃទី៧ ធ្នូ | អ្នកសារព័ត៌មានត្រូវបានបាញ់ចំពោះខណៈកំពុងធ្វើដំណើរត្រឡប់ពីយកព័ត៌មានពីបញ្ហាបរិស្ថាននៅស្រុកជីក្រែង |
| **ស្រ៊ន រ៉ារ៉ាន់** | CPN news | មណ្ឌលគិរី | បាត់ខ្លួននៅថ្ងៃទី១ មិថុនា ២០២៤ សាកសពរកឃើញនៅថ្ងៃទី ១៤មិថុនា | នគរបាលសន្និដ្ឋានថាស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍។ |

# ២. ប្រភេទនៃករណីយាយី

ប្រភេទនៃការយាយីត្រូវបានបែងចែកជាបីផ្នែកធំៗ (ការយាយីផ្នែកច្បាប់ ការយាយីផ្នែកឌីជីថល និងការយាយីផ្នែករាងកាយ) ក៏ដូចជាការរឹតបន្តឹង និងការបំភិតបំភ័យមកលើអ្នកសារព័ត៌មាន។

ការគំរាមកំហែងផ្នែកច្បាប់មានចំនួន ៦៨ភាគរយ នៃករណីសរុប ដោយមាន ២៨ករណី ប៉ះពាល់ដល់អ្នកសារព័ត៌មាន ៤៥នាក់។ ចំណែកឯក្តីបារម្ភអំពីសុវត្ថិភាពរាងកាយ ជាប់ចំណាត់ថ្នាក់លេខ២ ដោយមាន ៦ករណី ប៉ះពាល់ដល់អ្នកសារព័ត៌មាន ៩នាក់ ស្មើនឹង ១៥ភាគរយនៃឧប្បត្តិហេតុសរុប។

អ្នកសារព័ត៌មានមកពីអង្គភាពសារព័ត៌មានអនឡាញយ៉ាងហោចណាស់ចំនួន ៣២អង្គភាព បានទទួលរងការចោទប្រកាន់តាមផ្លូវច្បាប់ក្នុងឆ្នាំ ២០២៤ រួមមានការកោះហៅទៅតុលាការ ការដកហូតអាជ្ញាបណ្ណអង្គភាព ប្រឈមនឹងការគំរាមកំហែងផ្លូវច្បាប់ ការចោទប្រកាន់ ឃាត់ខ្លួនដើម្បីសាកសួរ ឬដាក់ឃុំខ្លួន។

អ្នកសារព័ត៌មានយ៉ាងហោចណាស់១០នាក់ ត្រូវបានចាប់ខ្លួន និងឃុំខ្លួននៅប៉ុស្តិ៍នគរបាល ដើម្បីសាកសួរ ខណៈអ្នកសារព័ត៌មាន៨នាក់ ត្រូវបានតុលាការ និងនគរបាលកោះហៅមកសួរនាំ។

ក្នុងឆ្នាំនេះ យើងបានកត់ត្រាករណីហិង្សាលើរាងកាយចំនួន ៦ករណី។ ករណីដ៏សាហាវបំផុតគឺអ្នកសារព័ត៌មាននៅខេត្តសៀមរាបម្នាក់ត្រូវបានគេសម្លាប់។ អ្នកសារព័ត៌មានខ្លះទៀតបានរាយការណ៍ថាត្រូវបានគេវាយដំលើរាងកាយ ឬឧបករណ៍ប្រើប្រាស់ត្រូវបានបំផ្លាញ។

យើងបានកត់ត្រាករណីរឹតត្បិតដោយមិនសមហេតុផល ឬរើសអើងលើអ្នកសារព័ត៌មានចំនួន ១១ នាក់ ក្នុងនោះរួមមានអ្នកសារព័ត៌មានស្ត្រី ២នាក់ ក្នុងអំឡុងពេលពួកគេបំពេញការងារ។

យ៉ាងហោចណាស់មានអ្នកសារព័ត៌មាន ៣នាក់ មិនត្រូវបានអនុញ្ញាតឱ្យចូលក្នុងបន្ទប់សវនាការសម្រាប់សវនាការពាក់ព័ន្ធនឹងលោក កឹម សុខា អតីតប្រធានគណបក្សសង្គ្រោះជាតិ បើទោះបីជាពួកគេបានចុះឈ្មោះមុនក៏ដោយ។

ទោះបីជាខេមបូចា មិនបានកត់ត្រាករណីណាមួយនៃការយាយីតាមប្រព័ន្ធឌីជីថល ប៉ុន្តែតាមរយៈការស៊ើបអង្កេតសារព័ត៌មានខេមបូចា បានរកឃើញយុទ្ធនាការអនឡាញដ៏អាក្រក់មួយដើម្បីវាយប្រហារប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនៅលើបណ្តាញសង្គមហ្វេសប៊ុក ជាកន្លែងដែលពេញនិយមសម្រាប់ប្រជាជនកម្ពុជា ទទួលបានព័ត៌មានរបស់ពួកគេ។

តារាងទី៥ បង្ហាញពីប្រភេទនៃការយាយី

| ប្រភេទ | ចំនួនករណីអ្នកសារព័ត៌មាន | ចំនួនអ្នកសារព័ត៌មានប៉ះពាល់ | គិតជាភាគរយ |
|---|---|---|---|
| សុវត្ថិភាពផ្នែកច្បាប់ | ២៨ | ៤៥ | ៦៨% |
| សុវត្ថិភាពផ្នែកឌីជីថល | ០ | ០ | ០% |
| សុវត្ថិភាពផ្នែករាងកាយ | ៦ | ៩ | ១៥% |
| ផ្សេងៗ | ៧ | ១០ | ១៧% |
| សរុប | ៤១ | ៦៤ | |

## និន្នាការនៃការគំរាមកំហែងផ្នែកច្បាប់ដែលបានកត់ត្រាតាមឆ្នាំនីមួយៗ

ចាប់ពីឆ្នាំ២០២០-២០២៤ ខេមបូចា សង្កេតឃើញថា ការគំរាមកំហែងផ្នែកច្បាប់ គឺជាមធ្យោបាយដែលប្រើញឹកញាប់បំផុតក្នុងការរឹតត្បិតសេរីភាពអ្នកសារព័ត៌មាន។ នៅឆ្នាំ២០២០ យើងបានកត់ត្រាករណីនៃការគំរាមកំហែងផ្នែកច្បាប់ចំនួន ២៤ករណី ឆ្នាំ២០២១ មាន ៣១ករណី បន្ទាប់មកទៀតឆ្នាំ២០២២ មាន ១៦ករណី និងឆ្នាំ២០២៣ មាន ១៥ករណី។ ដោយឡែក ឆ្នាំ២០២៤នេះកើនឡើងរហូតដល់ ២៨ ករណី។

តារាងទី៦ បង្ហាញពីការយាយីកត់ត្រាតាមឆ្នាំ

| ប្រភេទនៃការយាយី | ចំនួនករណី ២០២០ | ចំនួនករណី ២០២១ | ចំនួនករណី ២០២២ | ចំនួនករណី ២០២៣ | ចំនួនករណី ២០២៤ | សរុប |
|---|---|---|---|---|---|---|
| សុវត្ថិភាពផ្នែកច្បាប់ | ២៤ | ៣១ | ១៦ | ១៥ | ២៨ | ១១៤ |
| សុវត្ថិភាពផ្នែកឌីជីថល | គ្មាន | គ្មាន | គ្មាន | ៥ | គ្មាន | ៥ |
| សុវត្ថិភាពផ្នែករាងកាយ | ១១ | ១៨ | ៤ | ៣ | ៦ | ៤២ |
| ផ្សេងៗ | គ្មាន | គ្មាន | ១៥ | ៩ | ៧ | ៣១ |

# V. សេចក្តីរាយការណ៍

## ១. អ្នកសារព័ត៌មាននៅខេត្តមណ្ឌលគិរីម្នាក់ស្លាប់ក្នុងគ្រោះថ្នាក់ចរាចរណ៍

លោក ស្រ៊ុន វ៉ាវ៉ាន់ អ្នកសារព័ត៌មានរបស់អង្គភាពព័ត៌មាន CPN ជាអ្នកសារព័ត៌មានអនឡាញម្នាក់ក្នុងចំណោម អ្នកសារព័ត៌មានអនឡាញបីនាក់ក្នុងខេត្តមណ្ឌលគិរី ដែលត្រូវបានចាប់ខ្លួនកាលពីខែតុលា ឆ្នាំ២០២៣ ពីបទជំរិតទារ ប្រាក់ពីក្រុមហ៊ុនរុករករ៉ែរបស់ចិននៅស្រុកកែវសីមា។ គាត់ត្រូវបានឃុំខ្លួនបណ្តោះអាសន្នរយៈពេលប្រាំមួយខែ ហើយត្រូវបានដោះលែងឱ្យនៅក្រៅឃុំក្នុងខែមីនា ឆ្នាំ ២០២៤។

នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៤ គាត់ត្រូវបានគេប្រទះឃើញស្លាប់នៅក្នុងប្រឡាយតាមបណ្តោយផ្លូវក្នុងខេត្ត បន្ទាប់ ពីបាត់ខ្លួនអស់រយៈពេលពីរសប្តាហ៍។

ស្នងការខេត្ត មណ្ឌលគិរី បានឱ្យដឹងថា លោក វ៉ាវ៉ាន់ បានបើកបរក្នុងស្ថានភាពស្រវឹងទើបបណ្តាលឱ្យធ្លាក់ផ្លូវស្លាប់។ ទោះបីជាយ៉ាងណាក៏ដោយ សហការីរបស់គាត់បានចោទជាសំណួរអំពីករណីនេះ ហើយសាច់ញាតិរបស់គាត់ បាននិយាយថា នគរបាលមិនបានប្រគល់ទូរស័ព្ទជនរងគ្រោះតាមការស្នើសុំរបស់សាច់ញាតិទេ ដោយបានដុតសម្ភារៈនៅជាប់ខ្លួនទាំងអស់ជាមួយនឹងសាកសព។

### ប៉ុន្មានថ្ងៃមុនការស្លាប់

នៅព្រឹកថ្ងៃទី១ ខែមិថុនា លោក វ៉ាវ៉ាន់ ដែលមានវ័យ៣៣ឆ្នាំ បានចាកចេញពីផ្ទះក្នុងស្រុកដាក់ដាំ ខេត្តមណ្ឌលគិរី ដើម្បីទៅ លេងមិត្តភក្តិនៅស្រុកកោះញែក។

បើតាមមិត្តរបស់គាត់ម្នាក់ បានប្រាប់ខេមបូចាឱ្យដឹងថា លោក វ៉ាវ៉ាន់ បានមកដល់ផ្ទះគាត់ប្រហែលជាម៉ោង ១០:៣០ នាទីព្រឹក និងបានចាកចេញពីផ្ទះគាត់បន្ទាប់ពីហូបបាយថ្ងៃរួច ដើម្បីទៅជួបមិត្តភក្តិម្នាក់ទៀតនៅក្នុងនៅវេលាម៉ោង៤ ល្ងាច។ «គាត់បានសុំមាន់ខ្ញុំពីរបីក្បាលយកទៅធ្វើម្ហូប ហើយថាចាំពេលត្រឡប់ពីផ្ទះមិត្តភក្តិម្នាក់ទៀតទើបចូលមកយក» នេះបើតាមមិត្តរបស់លោក វ៉ាវ៉ាន់។ «ខ្ញុំចាំមើលគាត់មកយកមាន់ ប៉ុន្តែមិនឃើញគាត់មកសោះ»។

មួយថ្ងៃបន្ទាប់ មិត្តភក្តិរូបនេះបានឲ្យដឹងថាប្រពន្ធ វ៉ាវ៉ាន់ បានទូរស័ព្ទមកលោកដោយប្រាប់ថា វ៉ាវ៉ាន់ មិនបានត្រឡប់មក ផ្ទះនោះទេ។ លោកបន្តថា ភរិយារបស់លោក វ៉ាវ៉ាន់ បានទូរស័ព្ទមកម្តងហើយម្តងទៀត ដោយប្រាប់ថាប្តីគាត់នៅតែមិន ទាន់ត្រឡប់មកផ្ទះវិញ។

ពេលនោះលោកក៏បានប្រាប់ឱ្យប្រពន្ធ វ៉ាវ៉ាន់ រាយការណ៍ទៅនគរបាលអំពីការបាត់ខ្លួនប្តីរបស់គាត់ ប៉ុន្តែ អ្នកស្រីមិនហ៊ាន ដោយខ្លាចថា នគរបាលគិតថាប្តីរបស់ខ្លួនរត់គេចខ្លួនពីការអនុវត្តទោសនៅក្រៅឃុំ។

ប្រពន្ធរបស់រ៉ាវ៉ាន់ បានឱ្យដឹងថា នៅថ្ងៃទី១ ខែមិថុនា នៅម៉ោង៨យប់ រ៉ាវ៉ាន់បានទូរស័ព្ទមកគាត់ ដោយប្រាប់ថា កំពុងនៅផ្ទះមិត្តភក្តិ ដោយជួបជុំផឹកស៊ីបន្តិចបន្តួច ហើយនឹងត្រឡប់វិញទាំងយប់ ប៉ុន្តែអ្នកស្រីបានប្រាប់មិនឱ្យស្វាមីរបស់ខ្លួនធ្វើដំណើរ មកផ្ទះវិញទាំងយប់នោះទេព្រោះបារម្ភពីសុវត្ថិភាព។

អ្នកស្រីបន្តថា លុះដល់ព្រឹកថ្ងៃទី២ ខែមិថុនា ប្តីរបស់គាត់បានទូរស័ព្ទមកប្អូនថ្លៃស្រី ដោយប្រាប់ថា នឹងមកដល់ផ្ទះឃើតបន្តិច ។ លុះដល់រសៀលម៉ោង១ នៅតែមិនទាន់ឃើញប្តីត្រឡប់មកផ្ទះវិញទៀត អ្នកស្រីបានព្យាយាមទូរស័ព្ទ ទៅមិត្តភក្តិនៅស្រុកកោះញែកដែល រ៉ាវ៉ាន់ បានស្នាក់នៅយប់ថ្ងៃនោះ។ ប៉ុន្តែមិត្តភក្តិបានប្រាប់ថា រ៉ាវ៉ាន់ បានចេញតាំងពីម៉ោង៥ និង ៣០នាទីព្រឹកម្ល៉េះ។

## សាកសពត្រូវបានរកឃើញនៅពីរសប្តាហ៍ក្រោយមក




មណ្ឌលគិរីៈ កម្មករកាត់ស្មៅបានប្រទះឃើញសាកសពមានសភាពស្អុយរលួយនៅក្នុងប្រឡាយចិញ្ចើមផ្លូវជាតិលេខ៧៦ ចំណុចប៉ាឆាដុតសពកូរីតជិតភ្នំបាយឆៅ ក្នុងសង្កាត់រមនាក្រុងសែនមនោរម កាលពីព្រឹកថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៣។

សាពសពបុរសដែលស្លាប់មានឈ្មោះស្រ៊ុន រ៉ាវ៉ាន់ ជាភ្នាក់ងារសារព័ត៌មាន CPN News ប្រចាំខេត្តមណ្ឌលគិរី។

តាមសន្និដ្ឋានរបស់នគរបាលជំនាញ សាកសពស្លាប់ដោយសារជិះម៉ូតូធ្លាក់ផ្លូវ ដោយសារទីតាំងមានសភាពកោងខ្លាំង។

តាមសាច់ញាតិ បានឲ្យដឹងថា ជនរងគ្រោះ បានចេញពីផ្ទះនៅឃុំដាក់ដាំ ស្រុកអូររាំង ដោយប្រាប់ប្រពន្ធថា ទៅយកព័ត៌មាននៅស្រុកកោះញែក តាំងពីថ្ងៃទី១ ខែមិថុនា មកម្ល៉េះ ហើយបាត់ដំណឹងតែម្តងទើបរកឃើញនៅពេលនេះ។

រូបភាពស្រ្គីនសត់សាច់ញាតនៅកន្លែងកើតហេតុដែលសាកសពជនរងគ្រោះត្រូវដបានគេប្រទះឃើញ នៅថ្ងៃទី ១៤ មិថុនា ឆ្នាំ២០០៤។

សាកសពរបស់លោក វ៉ាវ៉ាន់ ត្រូវបានរកឃើញនៅពីរសប្ដាហ៍បន្ទាប់ នៅព្រឹកថ្ងៃទី១៤ ខែមិថុនា ក្នុងប្រឡាយផ្លូវ នៅ បណ្ដោយផ្លូវជាតិលេខ៧៦។ សាកសពត្រូវបានរកឃើញដោយកម្មករកាត់ស្មៅ។

អាជ្ញាធរ បានអះអាងថា លោកវ៉ាវ៉ាន់បានស្លាប់ដោយសារគ្រោះថ្នាក់ចរាចរណ៍នៅចំណុចផ្លូវកោង។ រូបភាពដែលបានចែករំលែកជាមួយខេមបូចាដោយក្រុមអ្នកសារព័ត៌មានបង្ហាញឱ្យឃើញថា សាកសពស្ថិតក្នុងសភាពផ្អែកជញ្ជាំងប្រឡាយផ្លូវដោយម៉ូតូសង្កត់ពីលើ។

សាកសពត្រូវបានបូជានៅឈាបនដ្ឋានក្បែរកន្លែងកើតហេតុនោះដែលជាទីតាំងសម្រាប់បូជាសាកសពអ្នកស្លាប់ដោយកូវីដ១៩ ។ សាច់ញាតិរបស់សព និយាយថានគរបាលមិនបានប្រគល់ទូរស័ព្ទរបស់ជនរងគ្រោះមកវិញទេ ហើយបានដុតវាជាមួយនឹងសពតែម្ដង។

«នៅពេលសួររកទូរស័ព្ទ ប៉ូលីសបាននិយាយថាទូរស័ព្ទនោះកខ្វក់ដោយសារវានៅជាប់ជាមួយសាកសពជាច្រើនថ្ងៃ ដូច្នេះប៉ូលីសបានដុតវាចោលជាមួយសាកសពបាត់ហើយ»។ នេះបើតាមសាច់ញាតិ។

ស្នងការនគរបាលខេត្តមណ្ឌលគិរី លោក ឡេា សុខា ឱ្យដឹងថា ការស៊ើបអង្កេតនេះធ្វើឡើងដោយអាជ្ញាធរខេត្ត រួមទាំងអ្នកជំនាញរបស់មន្ទីរសុខាភិបាលខេត្ត។ លោកថា សមត្ថកិច្ចបានពិនិត្យករណីនេះយ៉ាងហ្មត់ចត់ ហើយសន្និដ្ឋានថា អ្នកសារព័ត៌មានស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍ដោយខ្លួនឯង។

លោក សុខា និយាយថា ជនរងគ្រោះបានធ្លាក់ចូលទៅក្នុងប្រឡាយផ្លូវជម្រៅ១,៥ ម៉ែត្រ ដែលបណ្ដាលឱ្យបាក់កស្លាប់។ នៅទីតាំងកើតហេតុ សាកសពត្រូវបានបាំងដោយគុម្ពស្មៅក្រាស់ខ្មឹក។ លោក សុខា អះអាងថា បន្ទាប់ពីបញ្ចប់ការ ស៊ើបអង្កេត សាកសពត្រូវបានប្រគល់ទៅឱ្យក្រុមគ្រួសារដើម្បីប្រារព្ធពិធីបុណ្យតាមប្រពៃណី។

អ្នកសារព័ត៌មានមួយចំនួនបានជជែក និងចែករំលែកការសង្ស័យរបស់ពួកគេនៅក្នុងក្រុមតេឡេក្រាមដែលត្រូវបានចែក រំលែកជាមួយខេមបូចា។ ពួកគេក៏បានលើកឡើងពីការព្រួយបារម្ភអំពីសុវត្ថិភាព របស់ពួកគេ និងបានណែនាំគ្នាឲ្យ មានការប្រុងប្រយ័ត្ននៅពេលធ្វើដំណើរ ។

«ខ្ញុំនៅតែមិនជឿថាគាត់ស្លាប់ដោយសាររឿងបែបហ្នឹងនោះទេព្រោះគាត់ដឹងពីស្ថានភាពផ្លូវច្បាស់ គាត់ជិះតាមផ្លូវហ្នឹងសឹងតែរាល់ថ្ងៃហើយ»។

«ផ្លូវដែលគាត់ត្រឡប់ពីកោះញែក គឺវាឡើងចំណោត វាមិនអាចបណ្ដាលឱ្យមនុស្សស្លាប់បានដូចនេះទេ។ ប៉ុន្តែខ្ញុំមិនអាចនិយាយអ្វីប្រឆាំងនឹងរបាយការណ៍របស់ប៉ូលីសបានទេ។ មិនអាចផ្លូវឡើងចំណោត ហើយដួលស្លាប់បែបនេះទេ បើគាត់បើកចុះចំណោតទើបវាសម»។

លោក ឡេា សុខា ក៏បានបញ្ជាក់ផងដែរថាទីតាំងកើតហាតុនោះគឺជាផ្លូវឡើងចំណោត ហើយគ្រោះថ្នាក់នេះបានកើត ឡើង នៅពេលដែលលោក វ៉ាវ៉ាន់ កំពុងបើកបរក្នុងស្ថានភាពស្រវឹង។

# ២. អ្នកសារព័ត៌មានបានស្លាប់ដោយការបាញ់ប្រហារ

**អ្នកសារព័ត៌មាននៅខេត្តសៀមរាបម្នាក់ ដែលរាយការណ៍ពីបញ្ហាបរិស្ថានបានស្លាប់ដោយការបាញ់ប្រហារ** លោក ឈឿង ឈឹង អ្នកសារព័ត៌មានអនឡាញនៃអង្គភាពកម្ពុជាអភិវឌ្ឍន៍ មានមូលដ្ឋាននៅខេត្តសៀមរាបបានស្លាប់បីថ្ងៃបន្ទាប់ពីរងរបួសដោយការបាញ់ប្រហារដោយកាំភ្លើង។

អ្នកសារព័ត៌មានវ័យ៦៣ឆ្នាំរូបនេះ ត្រូវបានជនដៃដល់បាញ់ចំពោះ កាលពីថ្ងៃទី៤ ខែធ្នូ ខណៈគាត់កំពុងធ្វើដំណើរនៅក្នុងស្រុកជីក្រែង ខេត្តសៀមរាប ដើម្បីរាយការណ៍ពីបទល្មើសព្រៃឈើនៅតំបន់អភិរក្ស។

បើតាមសម្តីអ្នកសារព័ត៌មានដែលឃើញហេតុការណ៍នោះ បាននិយាយថា លោក ឈឹង បានរងការបាញ់ប្រហារនៅចម្ងាយប្រមាណ ៤០ម៉ែត្រពីខាងមុខគាត់បណ្តាលឱ្យរងរបួសធ្ងន់ធ្ងរ។

ដំបូងឡើយគាត់ត្រូវបានគេដឹកយកទៅមណ្ឌលសុខភាពឃុំនៅម៉ោងប្រហែល ៨យប់ ប៉ុន្តែពីរម៉ោងក្រោយមក គាត់ត្រូវបានបញ្ជូនទៅមន្ទីរពេទ្យខេត្តសៀមរាប ហើយបានទទួលការវះកាត់នៅថ្ងៃទី ៥ ខែធ្នូ។

អាជ្ញាធរបានចេញសេចក្តីថ្លែងការណ៍មួយបញ្ជាក់ថា ជនសង្ស័យម្នាក់ត្រូវបានចាប់ខ្លួន ហើយបានសារភាពថាបានបាញ់លោក ឈឹង ដោយសារតែជម្លោះបុគ្គល។

អង្គការអ្នកសារព័ត៌មានគ្មានព្រំដែន (RSF) នៅថ្ងៃទី៨ ខែធ្នូ បានអំពាវនាវដល់អាជ្ញាធរកម្ពុជាត្រូវធានាថា គ្រប់ភាគីដែលទទួលខុសត្រូវចំពោះការបាញ់ប្រហារនេះ ត្រូវបានផ្តន្ទាទោសឱ្យធ្ងន់ធ្ងរ និងជំរុញឱ្យរដ្ឋាភិបាលកម្ពុជាចាត់វិធានការយ៉ាងតឹងរ៉ឹង ដើម្បីបញ្ចប់អំពើហិង្សាលើអ្នកសារព័ត៌មាន។




លោក ឈឿង ឈឹង អ្នកសារព័ត៌មានអនឡាញមកពីកម្ពុជាអភិវឌ្ឍន៍
ក្នុងខេត្តសៀមរាប ដែលស្លាប់ដោយសារការបាញ់នឹងកាំភ្លើង (ហ្វេសប៊ុក)

## គ. អ្នកសារព័ត៌មានស្ត្រី និងបញ្ហាប្រឈមដែលពួកគេជួបប្រទះនៅក្នុងវិស័យប្រព័ន្ធផ្សព្វផ្សាយ

**«បុប្ផា»** គឺជាឈ្មោះដែលខេមបូចាបានដាក់ ដើម្បីសម្គាល់អ្នកសារព័ត៌មានអនឡាញម្នាក់ក្នុងខេត្តបាត់ដំបងដែលអះអាងថានាងបានឆ្លងកាត់ការរើសអើង និងការបៀតបៀនក្នុងនាមជាអ្នកសារព័ត៌មានស្ត្រី។

នាងបានចូលប្រឡូកក្នុងវិស័យសារព័ត៌មាននៅឆ្នាំ ២០២០ ហើយបច្ចុប្បន្នកំពុងធ្វើការជាអ្នករាយការណ៍ព័ត៌មាននៅអង្គភាពសារព័ត៌មាន ASEAN Daily News ជាមួយនឹងស្ទូឌីយោថតសំឡេងដែលបង្កើតឡើងនៅក្នុងផ្ទះរបស់នាង។

មុនពេលក្លាយជាអ្នកសារព័ត៌មាន នាងបានរាយការណ៍អំពីបញ្ហានៅក្នុងសហគមន៍របស់នាងនៅក្នុង ស្រុកគាស់ក្រឡខេត្តបាត់ដំបង ប៉ុន្តែត្រូវប្រឈមមុខនឹងការព្រមានម្តងហើយម្តងទៀតពីសំណាក់អាជ្ញាធរ មូលដ្ឋាន។

នាងនិយាយថា៖ «នៅពេលដែលខ្ញុំចង់ថតរូបដើម្បីបង្ហោះលើបណ្តាញសង្គម ពួកគប្រាប់ខ្ញុំថា ខ្ញុំគ្មានតួនាទីធ្វើបែបនោះទេ [ព្រោះខ្ញុំមិនមែនជា] អ្នកសារព័ត៌មាន»។ បន្ថែមលើនេះ នាងក៏សម្រេចចិត្តចូលរៀនផ្នែកសារព័ត៌មាន៖ «ហើយក្រោយមក មានគេប្រាប់ឱ្យខ្ញុំធ្វើជាអ្នកសារព័ត៌មាន»។

បុប្ផាមិនបានទទួលការបណ្តុះបណ្តាលផ្នែកសារព័ត៌មាន ឬការសរសេរព័ត៌មាននៅឡើយទេ ពេលដែលនាងចាប់ផ្តើមរាយការណ៍ផ្ទាល់លើកដំបូងតាមបណ្តាញសង្គមហ្វេសប៊ុក។

នាងបាននិយាយថា៖ «ការរាយការណ៍ជាលើកដំបូងរបស់ខ្ញុំគឺអំពីទីតាំងលេងល្បែងមួយកន្លែង។ ពួកគេ [អ្នកលេងល្បែង] ចង់ធ្វើបាបខ្ញុំ។ នៅពេលនោះ ខ្ញុំទើបតែចាប់ផ្តើមការងារ ដូច្នេះខ្ញុំមិនដឹងពីរបៀបទទួលបានព័ត៌មាន និងការការពារសុវត្ថិភាពទេ»។

នៅឆ្នាំ ២០២១ នាងបានទទួលការបណ្តុះបណ្តាលស្តីពីការរាយការណ៍ព័ត៌មានដែលរៀបចំដោយអង្គការក្រុមការងារដើម្បីដោះស្រាយទំនាស់ដែលមានមូលដ្ឋាននៅរាជធានីភ្នំពេញ។ នាងបាននិយាយថា៖«ខ្ញុំបានចូលរួមវគ្គបណ្តុះបណ្តាលនេះ ហើយ [ក៏បានរៀន] ពីរបៀបប្រាស្រ័យទាក់ទងជាមួយសហគមន៍ អាជ្ញាធរ និងការដោះស្រាយជម្លោះ»។

បុប្ផាបានប្រើប្រាស់ទូរសព្ទរបស់នាងដើម្បីថតរូប និងវីដេអូពេលធ្វើការរាយការណ៍។ វីដេអូត្រូវបានកែសម្រួលជាមួយនឹងការបញ្ចូលសំឡេងក្នុងស្ទូឌីយោក្នុងផ្ទះរបស់នាងផ្ទាល់។ នាងបាននិយាយថា ៖ «ក្នុងសម័យឌីជីថល ការមានទូរសព្ទអាចធ្វើឱ្យអ្នកក្លាយជាអ្នកសារព័ត៌មានបាន»។

កំឡុងពេលរាយការណ៍អំពីជម្លោះដីធ្លី នាងបាននិយាយថា នាងត្រូវបានអាជ្ញាធរប្តឹង។ ហើយបច្ចុប្បន្ននេះ នាងរាយការណ៍តែពីចំណុចវិជ្ជមានប៉ុណ្ណោះ ដើម្បីរក្សាសុវត្ថិភាពផ្ទាល់ខ្លួន។

បុប្ផា បាននិយាយថា ក្នុងនាមជាអ្នកសារព័ត៌មានស្ត្រី នាងបានជួបប្រទះនឹងការរើសអើង និងបៀតបៀនផ្លូវភេទដោយអ្នកសារព័ត៌មានបុរស និងមន្ត្រីរដ្ឋាភិបាល។



អ្នកសារព័ត៌មានស្ត្រីកំពុងសម្ភាសប្រធានសហជីពកម្មករនៅទីក្រុងភ្នំពេញ ឆ្នាំ ២០២៥ (ព្រីង សំរាំង)

នាងបាននិយាយថា៖«ខ្ញុំបានសម្ភាសនមន្ត្រីថ្នាក់ខេត្តម្នាក់ ហើយគាត់បានប្រើពាក្យមិនសមរម្យទាក់ទងនឹងផ្លូវភេទ ហើយខ្ញុំពិតជាតូចចិត្តណាស់ ប្តីរបស់ខ្ញុំប្រាប់ខ្ញុំឱ្យឈប់ធ្វើការងារនេះ។ ខ្ញុំក៏ធ្លាប់ជួបការបៀតបៀនផ្លូវភេទដោយអ្នកសារព័ត៌មានជាបុរសពេលចុះយកព័ត៌មាននៅមូលដ្ឋាន ដែលវាជាការបន្លំប៉ះខ្ញុំដោយចេតនា»។

ទោះជាយ៉ាងណាក៏ដោយ នាងនៅតែមានសុទិដ្ឋិនិយមចំពោះការងាររបស់នាង ដោយបានបន្តថា៖ «ខ្ញុំចង់ឱ្យអ្នកសារព័ត៌មានស្ត្រីទាំងអស់ក្លាហាន រឹងមាំ ហើយមិនស្ទាក់ស្ទើរក្នុងការធ្វើការងារនេះទេ បើទោះជាអ្នកប្រឈមមុខនឹងការបៀតបៀនក៏ដោយ»។

បុប្ផា មិនមែនជាអ្នកសារព័ត៌មានស្ត្រីតែម្នាក់ដែលជួបប្រទះនឹងការរើសអើង និងការបៀតបៀននៅកន្លែងការងារនោះទេ។

យោងតាមការសិក្សាដែលធ្វើទ្បើងដោយអង្គការយូណេស្កូ អ្នកសារព័ត៌មានស្ត្រី និងស្ត្រីធ្វើការក្នុងវិស័យប្រព័ន្ធផ្សព្វផ្សាយនៅទូទាំងពិភពលោក រួមទាំងប្រជាជនកម្ពុជា ទទួលរងការវាយប្រហារទាំងនៅខាងក្រៅ និងលើប្រព័ន្ធអនឡាញកាន់តែខ្លាំងឡើង ហើយក៏ជាគោលដៅដែលទទួលរងនូវការគំរាមកំហែងដោយមិនស្មើភាព និងជាក់លាក់។

ការសិក្សានេះបានសន្និដ្ឋានថា ៧៣ភាគរយនៃបុគ្គលិកជាស្ត្រីដែលធ្វើការក្នុងវិស័យប្រព័ន្ធផ្សព្វផ្សាយបានជួបប្រទះអំពើហិង្សាតាមប្រព័ន្ធអនឡាញ។

ក្នុងឆ្នាំ២០២៣ អង្គការយូណេស្កូ និងអង្គការមណ្ឌលព័ត៌មានស្ត្រីកម្ពុជា បានចាប់ផ្តើមគម្រោងលើកកម្ពស់សុវត្ថិភាពអ្នកសារព័ត៌មានស្ត្រី និងពង្រឹងសេរីភាពនៃការបញ្ចេញមតិនៅកម្ពុជា។

អ្នកស្រី រឿន សំណាង អាយុ ៣៨ឆ្នាំ កំពុងបម្រើការនៅអង្គភាពសារព័ត៌មាន សាយ ប៉ូច ហតញូស៍ នៅខេត្តបាត់ដំបង បានចែករំលែកបញ្ហាប្រឈមស្រដៀងគ្នានេះ ក្នុងនាមជាអ្នកសារព័ត៌មានស្ត្រី។ គាត់បាននិយាយថា គ្រួសាររបស់គាត់មិនបានលើកទឹកចិត្តឱ្យធ្វើការជាអ្នកសារព័ត៌មាននោះទេ។

អ្នកស្រីបាននិយាយថា៖ «សម្រាប់ខ្ញុំគឺវាពិតជាមានការលំបាកមែនទែនក្នុងការទាក់ទងសុំព័ត៌មានពីប្រភព។ ពួកគេប្រាប់ខ្ញុំថាស្ត្រីមិនគួរធ្វើការជាអ្នកសារព័ត៌មានទេ»។

អ្នកស្រី សំណាង ធ្លាប់បានចូលរួមវគ្គបណ្តុះបណ្តាលផ្នែកសារព័ត៌មានដែលរៀបចំដោយមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM)។ គាត់បានបន្តថា វាគួរតែមានឱកាសបន្ថែមទៀតសម្រាប់អ្នកសារព័ត៌មានក្នុងស្រុក ជាពិសេសអ្នកសារព័ត៌មានស្ត្រី ដើម្បីកសាងសមត្ថភាពរបស់ពួកគេ។

អ្នកសារព័ត៌មានស្ត្រីរូបនេះក៏បានស្នើឱ្យអាជ្ញាធរមូលដ្ឋានបើកចិត្តទូលាយ ក្នុងការទទួលស្គាល់ពីតួនាទីជាអ្នកសារព័ត៌មាន។ គាត់បន្តថា៖ «ខ្ញុំចង់ឃើញអាជ្ញាធរសហការជាមួយអ្នកសារព័ត៌មាន និងសមាគមប្រព័ន្ធផ្សព្វផ្សាយដើម្បីផ្សព្វផ្សាយ និងគាំទ្រអ្នកសារព័ត៌មានស្ត្រីនៅពេលដែលយើងជួបបញ្ហា»។

ទាំងអ្នកស្រី សំណាង និងបុប្ផា បាននិយាយថា ពួកគេមិនទាន់បានទទួលការបណ្តុះបណ្តាលស្តីពីសុវត្ថិភាពតាមប្រព័ន្ធអនឡាញ និងសុវត្ថិភាពផ្នែករាងកាយនៅឡើយ។

កញ្ញា រ៉ាន់ ស្រីដែត ជាអ្នកសារព័ត៌មានសេរីម្នាក់នៅភ្នំពេញ ដែលសិក្សាផ្នែកសារព័ត៌មាននៅដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍ (DMC) បាននិយាយថា គ្រួសាររបស់នាងមិនបានលើកទឹកចិត្តឱ្យនាងធ្វើការជាអ្នកសារព័ត៌មានតាំងពីដំបូងឡើយ។

នាងបាននិយាយថា៖«ពួកគាត់បារម្ភពីខ្ញុំ ហើយបានសុំឱ្យខ្ញុំឈប់ធ្វើការងារនេះ ជាពិសេសនៅពេលពួកគាត់ឃើញខ្ញុំធ្វើការជាមួយប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ»។ កញ្ញាបន្តថា៖ «ដោយសារតែខ្ញុំស្រឡាញ់ការងារនេះ ខ្ញុំបានព្យាយាមពន្យល់ និងបញ្ចុះបញ្ចូលពួកគាត់អំពីការងាររបស់ខ្ញុំ។ ខ្ញុំចង់ក្លាយជាអ្នកសារព័ត៌មានវិជ្ជាជីវៈម្នាក់»។

ស្រីដែត បានចែករំលែកថា នាងបានទទួលរងការសម្លុតនៅពេលសម្ភាសនជាមួយមន្ត្រីរដ្ឋាភិបាល។

នាងបាននិយាយថា៖ «ខ្ញុំបានទូរសព្ទទៅមន្ត្រីម្នាក់ដើម្បីសួរអំពីករណីចាប់ខ្លួនអ្នកសារព័ត៌មានម្នាក់ ហើយមន្ត្រីនោះបានសួរខ្ញុំថាម្នាក់ណា?»។ «ខណៈពេល ខ្ញុំមិនបានចាំឈ្មោះអ្នកសារព័ត៌មាននោះទេ មន្ត្រីនោះបាននិយាយថា ហេតុអ្វីបានជាអ្នកមិនចេះធ្វើការ? [អ្នក] ល្ងង់ ហើយនៅតែចង់សម្ភាសខ្ញុំទៀត? »

ស្រីដែត បានបន្តថា ចំនួនអ្នកសារព័ត៌មានស្ត្រីដែលធ្វើការក្នុងស្ថាប័នប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនៅមានតិចតួចនៅឡើយ ដោយសារពួកគេខ្លាចការរាយការណ៍អំពីបញ្ហារសើប និងប្រឈមមុខនឹងការជំទាស់ពីសង្គម និងគ្រួសារ។ នាងបន្ថែមថា៖«ខ្ញុំគិតថាបញ្ហាយេនឌ័រមិនគួរជាឧបសគ្គសម្រាប់ស្ត្រីក្នុងការធ្វើអ្វីដែលពួកគេចង់ធ្វើនោះទេ។ ប្រសិនបើស្ត្រីបានទទួលការគាំទ្រពីគ្រួសារ ពួកគេនឹងមានអារម្មណ៍បើកចំហ។ យើងអាចធ្វើអ្វីដែលយើងចង់ធ្វើដោយគ្មានការព្រួយបារម្ភច្រើន»។



អ្នកសារព័ត៌មានស្ត្រី កញ្ញា ស៊ើង និមល់ កំពុងសម្ភាសពលរដ្ឋជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ពីគម្រោងឥណទានកាបូននៅឃុំថ្មដូនពៅ ស្រុកថ្មបាំង ខេត្តកោះកុង កាលពីថ្ងៃទី ៣០ តុលា ឆ្នាំ ២០២៤ ។ (ហ៊ែល កំសាន)

កញ្ញាបានបន្ថែមថា ពេលនិយាយអំពីបញ្ហាដូចជាការបៀតបៀនផ្លូវភេទ មានតែស្ត្រីប៉ុណ្ណោះដែលអាចយល់ពីបញ្ហាបាន។

តួលេខពិតប្រាកដនៃអ្នកសារព័ត៌មានស្ត្រីនៅកម្ពុជាមិនច្បាស់លាស់ទេ។

ក្នុងឆ្នាំ២០២៣ ក្រសួងព័ត៌មានបានចេញបណ្ណសារព័ត៌មានចំនួន ២៦៩ ជូនអ្នកសារព័ត៌មានស្ត្រី ដែលស្មើនឹង ៨,៧% នៃចំនួនបណ្ណសរុប ដែលបានចេញ។ របាយការណ៍ប្រព័ន្ធផ្សព្វផ្សាយក្នុងឆ្នាំ ២០២២ ដែលបានដកស្រង់ទិន្នន័យរបស់ក្រសួងបានលើកឡើងថា ក្នុងឆ្នាំ២០២១ កម្ពុជាមានចំនួនអ្នកសារព័ត៌មានស្ត្រីជាង ៤៧០ នាក់។

អ្នកស្រី ធន សុគន្ធា នាយិកាប្រតិបត្តិនៃមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM) បានស្នើទៅក្រសួងព័ត៌មានឱ្យផ្តល់ «ការការពារពិសេស» សម្រាប់អ្នកសារព័ត៌មានស្ត្រី ជាពិសេសនៅពេលដែលពួកគេចុះយកព័ត៌មាននៅកន្លែងដែលគ្មានសុវត្ថិភាព។

អ្នកស្រីមានប្រសាសន៍ថា៖ «នៅពេលដែលពួកគេរាយការណ៍ពីបញ្ហារំលោភដូចជាជម្លោះដីធ្លី ពួកគេត្រូវការចុះទៅមូលដ្ឋានផ្ទាល់ ឬចូលទៅក្នុងព្រៃ។ ប្រសិនបើមានអ្វីកើតឡើង តើអ្នកណាទទួលខុសត្រូវចំពោះសុវត្ថិភាពរបស់ពួកគេ?»។

អ្នកស្រី ហង្ស សម្ផស្ស ប្រធានបណ្ដាញអ្នកសារព័ត៌មានស្ត្រីកម្ពុជាបានថ្លែងថា ចំនួនអ្នកសារព័ត៌មានស្ត្រីមានតិចតួច ព្រោះបញ្ហាប្រឈមដូចជាការបៀតបៀនផ្លូវភេទនៅតែបន្តកើតមានទាំងនៅក្រៅ និងតាមប្រព័ន្ធអនឡាញ។

«សុវត្ថិភាព និងសន្តិសុខរបស់អ្នកសារព័ត៌មានជាស្ត្រីនៅមិនទាន់ទទួលបានការយកចិត្តទុកដាក់ដិតដល់នោះទេ នៅពេលពួកគេចេញទៅបំពេញការងារតាមមូលដ្ឋាន ឬធ្វើដំណើរនៅពេលយប់»។ អ្នកស្រីបន្តថា៖«ការយាយីតាមប្រព័ន្ធអនឡាញតែងតែកើតឡើងចំពោះអ្នកសារព័ត៌មានស្ត្រី ហើយអាជ្ញាធរគ្មានចំណាត់ការណាមួយឡើយ»។

អ្នកស្រី សម្ផស្ស បាននិយាយថា ការរឹតត្បិតលើសេរីភាពសារព័ត៌មាន ក៏ជាកត្តាដែលកំណត់ការចូលរួមរបស់ស្ត្រីនៅក្នុងវិស័យប្រព័ន្ធផ្សព្វផ្សាយដែរ។

អ្នកស្រីបន្ថែមថា ៖ «តួនាទីរបស់អ្នកសារព័ត៌មានស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្តណាមួយគួរតែត្រូវបានលើកកម្ពស់ជាមួយនឹងឱកាសបន្ថែមទៀតសម្រាប់ការកសាងសមត្ថភាព និងការគាំទ្រផ្នែកចិត្តសាស្ត្រ»។

# VI. ស្ថានភាពទូទៅនៃវិស័យសារព័ត៌មាន

## ចំណាត់ថ្នាក់សេរីភាពសារព័ត៌មាននៅកម្ពុជាក្នុងឆ្នាំ២០២៤ ថយចុះ

យោងតាមសន្ទស្សន៍សេរីភាពសារព័ត៌មានពិភពលោករបស់អង្គការអ្នកសារព័ត៌មានគ្មានព្រំដែនបង្ហាញថាកម្ពុជាស្ថិតនៅលេខរៀង១៥១ ក្នុងចំណោម ១៨០ប្រទេស ដោយធ្លាក់ចុះពីលេខរៀងទី ១៤៧ នៅក្នុងឆ្នាំ ២០២៣។

ពិន្ទុសរុបរបស់កម្ពុជាបានធ្លាក់ចុះពី៤២ ក្នុងឆ្នាំ២០២៣ មក៣៤ ក្នុងឆ្នាំ២០២៤។ សម្រាប់តំបន់អាស៊ីប៉ាស៊ីហ្វិក អង្គការអ្នកសារព័ត៌មានគ្មានព្រំដែន បានកត់សម្គាល់ថាប្រទេសកម្ពុជាស្ថិតនៅចំណាត់ថ្នាក់ខ្ពស់ជាងប្រទេសវៀតណាម និងមីយ៉ាន់ម៉ា។ របាយការណ៍នេះបានលើកឡើងថា «វិទ្យុទូរទស្សន៍ធំៗ និងសារព័ត៌មានដែលនៅសេសសល់តិចតួច ជាទូទៅស្របតាមរដ្ឋាភិបាល។ ប្រធានបទជាច្រើនដូចជា អំពីអ្នកនយោបាយបក្សប្រឆាំង អំពើពុករលួយ និងការកាប់បំផ្លាញព្រៃឈើ គឺមិនហ៊ានធ្វើសេចក្តីរាយការណ៍ទេ»។

## ប្រព័ន្ធផ្សព្វផ្សាយកម្ពុជាជំរុញឱ្យមានក្រុមប្រឹក្សាសារព័ត៌មានឯករាជ្យ

សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា កំពុងអំពាវនាវឱ្យមានក្រុមប្រឹក្សាសារព័ត៌មានឯករាជ្យមួយ ស្រដៀងនឹងប្រទេសក្នុងតំបន់អាស៊ានផ្សេងទៀតដែរ ក្នុងគោលបំណងពង្រឹងស្តង់ដារវិជ្ជាជីវៈ និងលើកកម្ពស់សុវត្ថិភាពសម្រាប់អ្នកសារព័ត៌មាន។

ក្នុងសន្និសីទនៅថ្ងៃទី៣១ ខែតុលា ស្តីពី «ទំនុកចិត្តលើសារព័ត៌មានកម្ពុជា» អង្គការយូណេស្កូបានរៀបចំវេទិកាពិភាក្សាជាមួយអ្នកសារព័ត៌មាន និងស្ថាប័នសារព័ត៌មានកម្ពុជា ដើម្បីប្រារព្ធទិវាអន្តរជាតិដើម្បីបញ្ចប់និទណ្ឌភាពនៃឧក្រិដ្ឋកម្មលើអ្នកសារព័ត៌មាន និងពិភាក្សាអំពីបញ្ហាប្រឈមរបស់អង្គភាពសារព័ត៌មានក្នុងប្រទេស។

## ប្រព័ន្ធផ្សព្វផ្សាយនិរទេស ក្លាយជាគោលដៅនៃ «យុទ្ធសាស្ត្រប្រតិបត្តិការជាប្រព័ន្ធ» តាមអនឡាញ

បន្ទប់ផ្សាយព័ត៌មានរបស់ខេមបូចា បានចេញផ្សាយអត្ថបទព័ត៌មានមួយ ដែលលាតត្រដាង «យុទ្ធសាស្ត្រប្រតិបត្តិការជាប្រព័ន្ធ» ដែលត្រូវបានបង្កើតឡើងដើម្បីវាយប្រហារស្ថាប័នប្រព័ន្ធផ្សព្វផ្សាយនៅក្រៅប្រទេស រួមមានវិទ្យុសំឡេងប្រជាធិបតេយ្យ(VOD) វិទ្យុអាស៊ីសេរី(RFA) និង ឌី ខេមបូឌាដេលីខ្មែរ។

គណនីបណ្តាញសង្គមដែលពាក់ព័ន្ធនឹងយុទ្ធនាការ trolling នេះជារឿយៗបង្ហាញរូបភាពមនុស្សស្លៀកពាក់ឯកសណ្ឋានយោធា ឬត្រូវបានបង្កើតឡើងកាលពីមួយឆ្នាំ ឬពីរឆ្នាំមុន។ អ្នកជំនាញផ្នែកប្រព័ន្ធផ្សព្វផ្សាយ បានយល់ឃើញថា ការចងក្រងបានយ៉ាងល្អនេះអាចមានគោលបំណងជួយគណបក្សកាន់អំណាច។ ស្ថាប័នប្រព័ន្ធផ្សព្វផ្សាយដែលជាមុខសញ្ញា ជាទៀងទាត់រាយការណ៍នូវរបាយការណ៍ និងអត្ថាធិប្បាយរិះគន់រដ្ឋាភិបាលកម្ពុជា។

ផ្អែកលើការស្រាវជ្រាវ ដែលធ្វើឡើងដោយអ្នកជំនាញសន្តិសុខឌីជីថលក្នុងស្រុក មតិភាគច្រើនពាក់ព័ន្ធនឹងការប្រើប្រាស់កម្មវិធីកុំព្យូទ័រដែលបង្កើតមតិដោយស្វ័យប្រវត្តិ រួមជាមួយនឹង មតិ ដែលបង្កើតឡើងដោយមនុស្សហើយយកទៅចម្លងតគ្នា។

## លោកនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត ផ្ដល់អនុសាសន៍មួយចំនួនសម្រាប់វិស័យសារព័ត៌មាន

ក្នុងលិខិតចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៤ នៅមុនវេទិកានិពន្ធនាយកសារព័ត៌មានកម្ពុជាលើកទី២១ នាថ្ងៃទី២១ ខែធ្នូ លោក ហ៊ុន ម៉ាណែត បានមានប្រសាសន៍ថា សមិទ្ធផលរបស់រដ្ឋាភិបាលគឺបានមកពីការចូលរួមយ៉ាងសកម្មពីស្ថាប័នសារព័ត៌មាន និងអ្នកសារព័ត៌មាន។

លោកបានអះអាងថា រាជរដ្ឋាភិបាលនឹងយកចិត្តទុកដាក់លើការលើកកម្ពស់សិទ្ធិសេរីភាពសារព័ត៌មាន និងសេរីភាពនៃការបញ្ចេញមតិស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ស្ដីពីរបបសារព័ត៌មាន។ លោកបានបន្តទៀតថា រដ្ឋាភិបាលកម្ពុជា ត្រូវការអ្នកសារព័ត៌មានដ៏មានឥទ្ធិពល មានទំនួលខុសត្រូវ វិជ្ជាជីវៈ ដែលហ៊ាននិយាយការពិត និងហ៊ានផ្តល់ការរិះគន់បែបស្ថាបនា ដើម្បីបង្ហាញតថភាពពិតក្នុងសង្គម ដោយជៀសវាងការផ្សព្វផ្សាយព័ត៌មានតែម្ខាង ឬមិនពិត។

ទោះជាយ៉ាងនេះក្ដី លោកក៏បានលើកឡើងដែរថា ការប្រើប្រាស់សិទ្ធិទាំងនេះក្នុងការបញ្ចេញមតិលើសពីដែនកំណត់នៃច្បាប់នៅតែកើតមានឡើង ដែលនាំឱ្យប៉ះពាល់ដល់សណ្ដាប់ធ្នាប់សង្គម និងផ្ដល់ភាពអវិជ្ជមានដល់ប្រជាពលរដ្ឋ។

លោកបន្ថែមថា សិទ្ធិបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងការចេញផ្សាយត្រូវបានធានាយ៉ាងពេញលេញស្របតាមច្បាប់ និងបទប្បញ្ញត្តិរបស់កម្ពុជា។ ដូច្នេះអ្នកសារព័ត៌មានមិនត្រូវប្រើប្រាស់សិទ្ធិទាំងនោះ ធ្វើឱ្យប៉ះពាល់ដល់កិត្តិយសអ្នកដ៏ទៃ និងប៉ះពាល់ដល់ទំនៀមទម្លាប់សង្គម សណ្ដាប់ធ្នាប់សាធារណៈ និងសន្តិសុខជាតិឡើយ។

## ការផ្សាយពាណិជ្ជកម្មតាមប្រព័ន្ធឌីជីថលបានកើនឡើងនៅឆ្នាំ២០២៤

រដ្ឋមន្ត្រីក្រសួងព័ត៌មាន លោក នេត្រ ភក្ត្រា មានប្រសាសន៍ថា ការផ្សាយពាណិជ្ជកម្មតាមប្រព័ន្ធឌីជីថលមានកំណើនជាង ២០០ ភាគរយនៅឆ្នាំ ២០២៤ ជាមួយនឹងទឹកប្រាក់សរុប ១៧០ លានដុល្លារ ទោះបីជាចំនួនប្រព័ន្ធផ្សព្វផ្សាយបានថយចុះពីជាង២០០០ស្ថាប័ន មកត្រឹមតែជាង១០០០ស្ថាប័ន ដោយសារបញ្ហាប្រឈមផ្នែកហិរញ្ញវត្ថុក៏ដោយ។

ថ្លែងក្នុងសន្និសីទ ស្ដីពីការអភិវឌ្ឍ ប្រព័ន្ធផ្សព្វផ្សាយលើកទី២ នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៤ លោក នេត ភក្ត្រា បានកត់សម្គាល់ថា ក្នុងឆ្នាំ ២០១៦ ថវិកាចំនួន ១១៦ លានដុល្លារត្រូវបានចំណាយលើការផ្សាយពាណិជ្ជកម្មតាមរយៈប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី ដូចជា វិទ្យុ ទូរទស្សន៍ កាសែត និងទស្សនាវដ្ដី។ ចំនួននេះបានធ្លាក់ចុះមកនៅត្រឹមតែ ៨០លានដុល្លារក្នុងឆ្នាំ ២០២៤។

លោកបានព្រមានថា ប្រព័ន្ធផ្សព្វផ្សាយដែលមិនបត់បែនតាម ឌីជីថលប្រឈមមុខនឹងការបិទ ដោយសារប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណីកំពុងត្រូវបានជំនួសដោយប្រព័ន្ធឌីជីថល។

យោងតាមក្រសួងព័ត៌មាន នៅឆ្នាំ ២០២៤ មានអ្នកសារព័ត៌មានជាង ១០០០០ នាក់កំពុងធ្វើការក្នុងប្រទេស ក្នុងនោះជាង ៨ ពាន់នាក់កាន់បណ្ណសារព័ត៌មាន ចេញដោយក្រសួង។ ក្នុងចំណោមបណ្ណសារព័ត៌មានសរុបចំនួន ៣២០១ ចេញនៅឆ្នាំ ២០២៣ ក្រសួងបានរាយការណ៍ថា មាន២៦៩នាក់ជាអ្នកសារព័ត៌មានជាស្ត្រី។

ក្នុងឆ្នាំ ២០២៤ ក្រសួងបានចេញអាជ្ញាបណ្ណចំនួន ១៦២០ ដល់អង្គភាពប្រព័ន្ធផ្សព្វផ្សាយ រួមមាន ទូរទស្សន៍ វិទ្យុ កាសែត ទស្សនាវដ្ដី គេហទំព័រ និងប្រព័ន្ធផ្សព្វផ្សាយអនឡាញ ក្នុងនោះមាន ៨៧៥ អង្គភាពជាប្រព័ន្ធផ្សព្វផ្សាយអនឡាញ។

## ក្រសួងដាក់ឱ្យប្រើ «ធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន»

ធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មានត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី៦ ខែសីហា ឆ្នាំ២០២៤ បន្ទាប់ពីក្រសួងបានបង្ហាញធម្មនុញ្ញនេះជាសាធារណៈនៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៤។




រដ្ឋមន្ត្រីក្រសួងព័ត៌មានលោក នេត្រ ភក្ត្រា ថ្លែងក្នុងសន្និសីទសារព័ត៌មាននៃការដាក់ឲ្យដំណើរការធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាននៅថ្ងៃទី៦ សីហា ២០២៤។

អ្នកជំនាញរបស់អង្គការសហប្រជាជាតិ បានអំពាវនាវឱ្យផ្អាកជម្ពូនុញ្ញវិជ្ជាជីវៈសារព័ត៌មាននេះ។

អ្នកជំនាញនិយាយថា៖ «គ្មានការពិគ្រោះយោបល់ទូលំទូលាយណាមួយត្រូវបានធ្វើឡើងដែលជាផ្នែកនៃ ដំណើរការបង្កើតជម្ពូនុញ្ញនោះទេ ហើយភាគីពាក់ព័ន្ធមួយចំនួនត្រូវបានផ្តល់ពេលត្រឹមតែប្រាំបួនថ្ងៃដើម្បីផ្តល់យោបល់។ បួនថ្ងៃបន្ទាប់ពីកាលបរិច្ឆេទផុតកំណត់ ជម្ពូនុញ្ញនេះត្រូវបានប្រកាសឱ្យប្រើដោយមិនទុកឱ្យមានការពិភាក្សាបន្ថែមទៀត លើជាតុចូលដោយភាគីពាក់ព័ន្ធ»។

អ្នកជំនាញក៏មានការព្រួយបារម្ភផងដែរអំពីវិសាលភាពទូលំទូលាយនៃជម្ពូនុញ្ញ ដែលមានបំណងអនុវត្តចំពោះអ្នកសារព័ត៌មាន ស្ថាប័នសារព័ត៌មាន ចាងហ្វាង សមាគមអ្នកសារព័ត៌មាន និងអ្នកដែលប្រតិបត្តិការលើប្រព័ន្ធផ្សព្វផ្សាយសង្គម។

អ្នកជំនាញបានកត់សម្គាល់ថា ក្រមសារព័ត៌មានគួរតែត្រូវបានព្រៀងដោយអ្នកសារព័ត៌មានជាជាងតាមរយៈដំណើរការ ដែលដឹកនាំដោយក្រសួង។

## ម្ចាស់ជំនួយដ៏សំខាន់សម្រាប់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យត្រូវបានបិទ

ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (SIDA) បានបិទការិយាល័យរបស់ខ្លួនទាំងស្រុងនៅក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ២០២៤ ដែលជាការបង្ហាញពីការថយចុះនៃការគាំទ្រពីបរទេសសម្រាប់វិស័យសារព័ត៌មាន។

ជំនួយ SIDA បានដើរតួនាទីយ៉ាងសំខាន់ក្នុងការពង្រឹងសេរីភាពសារព័ត៌មាន និងគាំទ្រដល់វិស័យសារព័ត៌មានឯករាជ្យនៅកម្ពុជា ជាពិសេសនៅដើមទសវត្សរ៍ឆ្នាំ ២០០០។

តាមរយៈជំនួយឥតសំណង និងកម្មវិធីពង្រឹងសមត្ថភាព SIDA បានជួយលើកកម្ពស់ជំនាញរបស់អ្នកសារព័ត៌មានកម្ពុជា លើកកម្ពស់សេរីភាពសារព័ត៌មាន និងគាំទ្រអង្គការសង្គមស៊ីវិល ដែលតស៊ូមតិដើម្បីសេរីភាពនៃការបញ្ចេញមតិ។ ការកាត់បន្ថយការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ រួមជាមួយនឹងការបង្ក្រាបរបស់រដ្ឋាភិបាលលើប្រព័ន្ធផ្សព្វផ្សាយសំខាន់ៗ បានធ្វើឱ្យចុះខ្សោយយ៉ាងខ្លាំងនូវកម្មវិធីអភិវឌ្ឍន៍ប្រព័ន្ធផ្សព្វផ្សាយ។

## ការព្រួយបារម្ភអំពីការបង្កើតច្បាប់ស្តីពីច្រកទ្វារអ៊ីនធឺណិត

រដ្ឋាភិបាលកម្ពុជាកំពុងធ្វើសេចក្តីព្រាងច្បាប់ដើម្បីដោះស្រាយឧក្រិដ្ឋកម្មតាមអ៊ីនធឺណិត សន្តិសុខតាមអ៊ីនធឺណិត និងការការពារទិន្នន័យផ្ទាល់ខ្លួន ដែលទំនងជាមានបំណងបង្កើតបរិយាកាសឌីជីថលដែលមានសុវត្ថិភាព។

ទោះជាយ៉ាងណា សេចក្តីព្រាងច្បាប់ទាំងនេះត្រូវបានលើកឡើងនូវការព្រួយបារម្ភមួយចំនួន។ អ្នករិះគន់ បានអះអាងថា ច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមអ៊ីនធឺណិត និងសន្តិសុខតាមអនធឺណិតអាចនឹងបំពានលើសេរីភាពនៃការបញ្ចេញមតិ និងសិទ្ធិទទួលបានព័ត៌មាន។

សម្រាប់សេចក្តីព្រាងច្បាប់ការពារទិន្នន័យ ដែលចាំបាច់សម្រាប់ការការពារទិន្នន័យផ្ទាល់ខ្លួន ត្រូវតែស្របតាមស្តង់ដារអន្តរជាតិ ដើម្បីធានាថាវាការពារឯកជនភាពរបស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព ដោយគ្មានការរារាំងណាមួយ។

## រដ្ឋាភិបាលទទួលយកអនុសាសន៍មួយចំនួនទាក់ទងនឹងប្រព័ន្ធផ្សព្វផ្សាយពីអង្គការសហប្រជាជាតិ

ក្នុងវេទិកាពិភាក្សា ស្តីពីការត្រួតពិនិត្យជាសកលលើកទីបួនរបស់ប្រទេសកម្ពុជា (UPR) សមាជិកនៃក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិបានសម្តែងការព្រួយបារម្ភយ៉ាងខ្លាំងចំពោះស្ថានភាពសិទ្ធិមនុស្សរបស់ប្រទេសកម្ពុជា រួមទាំងសេរីភាពនៃការបញ្ចេញមតិផងដែរ។

មានអនុសាសន៍សរុបចំនួន ២៧៥ ត្រូវបានធ្វើឡើង ដោយភាគច្រើនផ្តោតលើការលើកកម្ពស់សេរីភាពសារព័ត៌មាន និងការការពារអ្នកសារព័ត៌មាន។ រាជរដ្ឋាភិបាលកម្ពុជា (RGC) បានគាំទ្រនូវអនុសាសន៍ចំនួន ២០ ដែលខ្លួនបានទទួលទាក់ទងនឹងសេរីភាពនៃការបញ្ចេញមតិ និងការទទួលបានព័ត៌មាន។

### អនុសាសន៍ដែលត្រូវបានគាំទ្រទាំងនោះរួមមាន៖

- ពង្រឹងកិច្ចខិតខំប្រឹងប្រែងទប់ស្កាត់ការយាយី និងការពារសិទ្ធិអ្នកការពារសិទ្ធិមនុស្ស និងអ្នកសារព័ត៌មាន (សាធារណរដ្ឋឆេក)។
- ចាត់វាល់វិធានការចាំបាច់ទាំងអស់ សម្រាប់ការអនុវត្តសេរីភាពនៃការបញ្ចេញមតិរបស់អ្នកសារព័ត៌មាន និងប្រជាជនទូទៅ និងបញ្ឈប់ការធ្វើទុក្ខបុកម្នេញលើពួកគេ (ប្រទេសព័រទុយហ្គាល់)។
- ធានានូវសេរីភាពនៃការបញ្ចេញមតិរបស់ប្រជាពលរដ្ឋ និងអ្នកសារព័ត៌មាន ដោយកែប្រែឡើងវិញនូវច្បាប់ក្រមព្រហ្មទណ្ឌ (ប្រទេសបារាំង)
- ធានានូវសេរីភាពនៃការបញ្ចេញមតិ និងឯករាជ្យភាពនៃប្រព័ន្ធផ្សព្វផ្សាយ ជាពិសេសតាមរយៈការលុបចោលមាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌ។ ដោយធ្វើវិសោធនកម្មច្បាប់ស្តីពីរបបសារព័ត៌មាន និងអនុម័តច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មានស្របតាមស្តង់ដារអន្តរជាតិ (ប្រទេសស្វីស)។
- រៀបចំឲ្យមានការពិគ្រោះយោបល់ប្រកបដោយអត្ថន័យ ជាមួយសង្គមស៊ីវិលលើសេចក្តីព្រាងច្បាប់ ដែលប៉ះពាល់ដល់សេរីភាពនៃការបញ្ចេញមតិ រួមទាំងសេចក្តីព្រាងច្បាប់ទាក់ទងនឹងឧក្រិដ្ឋកម្មតាមអ៊ីនធឺណិត សន្តិសុខតាមអ៊ីនធឺណិត និងការការពារទិន្នន័យផ្ទាល់ខ្លួន (ប្រទេសស៊ុយអែត)។
- ពង្រឹងការចូលរួមរបស់សង្គមស៊ីវិល និងសេរីភាពនៃការបញ្ចេញមតិ ដោយលុបចោលការសម្រេចចិត្តបិទគេហទំព័រប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងធ្វើការពិគ្រោះយោបល់ជាមួយសង្គមស៊ីវិលប្រកបដោយប្រកបដោយអត្ថន័យ លើការផ្លាស់ប្តូរនីតិបញ្ញត្តិដែលបានស្នើឡើង (ចក្រភពអង់គ្លេស និងប្រទេសអៀរឡង់ខាងជើង)។

# VII. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ខណៈពេលដែលលំហសេរីភាពសម្រាប់សារព័ត៌មានឯករាជ្យនៅកម្ពុជា កាន់តែតូចទៅៗ នៅតែមានអ្នកសារព័ត៌មានរាប់រយនាក់កំពុងធ្វើការដើម្បីរក្សាវា ដោយសរសេរអត្ថបទមួយ ឬការចាក់ផ្សាយក្នុងពេលណាមួយ។ ខេមបូចាមានមោទនភាពដែលបានក្លាយជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងនេះ ដើម្បីរក្សាប្រពៃណីសារព័ត៌មានដែលគ្មានការភ័យខ្លាចរបស់ប្រទេសយើង។

ជាការពិតណាស់ បើទោះបីអ្នករួមអាជីពសារព័ត៌មានជាច្រើនកំពុងប្រឈមមុខនឹងការយាយីអំឡុងពេលចុះបេសកកម្មនៅខាងក្រៅក៏ដោយ ប៉ុន្តែពួកគេនៅតែចេញក្រៅ ដោយទុកសន្តិសុខសុវត្ថិភាពរបស់ពួកគេនៅមួយឡែកដើម្បីជួយឱ្យប្រជាពលរដ្ឋទទួលបានព័ត៌មាន។ ករណីឃាតកម្មលើលោក ឈឿង ឈឹង និងការចាប់ខ្លួនលោក ម៉ិច ដារ៉ា បង្ហាញពីការរឹតត្បិត ដែលអ្នកសារព័ត៌មានជួបប្រទះ។

ទោះបីជាមានការធានារបស់រដ្ឋាភិបាលក្នុងការរក្សាសេរីភាពសារព័ត៌មានក៏ដោយ សកម្មភាពដូចជាការដកហូតអាជ្ញាបណ្ណប្រព័ន្ធផ្សព្វផ្សាយ ការវាយប្រហារជាយុទ្ធសាស្ត្រលើស្ថាប័នឯករាជ្យ និងការលំបាកក្នុងការទទួលបានកាតសារព័ត៌មាន បានបង្ហាញពីការរឹតបន្តឹងលើការបញ្ចេញមតិសារព័ត៌មាន។

ទោះបីជាជម្មនុញ្ញវិជ្ជាជីវៈអ្នកសារព័ត៌មាន ត្រូវបានដាក់ដំណើរការដើម្បីឈានទៅរកការរាយការណ៍ប្រកបដោយវិជ្ជាជីវៈ ប៉ុន្តែវាហាក់ដូចជាផ្តល់អទិភាពដល់ការគ្រប់គ្រងលើវិស័យសារព័ត៌មាន ជាជាងការលើកកម្ពស់ ឬការពារឯករាជ្យភាពអ្នកសារព័ត៌មាន។

ប្រព័ន្ធផ្សព្វផ្សាយសេរី និងឯករាជ្យមិនត្រឹមតែជាសិទ្ធិជាមូលដ្ឋានប៉ុណ្ណោះទេ ប៉ុន្តែជាមូលដ្ឋានគ្រឹះនៃសង្គមប្រជាធិបតេយ្យ។ របាយការណ៍នេះ បានបន្ថែមពីលើការរកឃើញរបស់អង្គការផ្សេងទៀត ដែលបានរៀបរាប់ស្ថានភាពគួរឱ្យព្រួយបារម្ភនៃប្រព័ន្ធផ្សព្វផ្សាយនាពេលបច្ចុប្បន្ននេះ។ ភាពធ្ងន់ធ្ងរនៃបញ្ហា គឺឆ្លុះបញ្ចាំងឱ្យឃើញនូវការធ្លាក់ចុះចំណាត់ថ្នាក់របស់កម្ពុជានៅក្នុងសន្ទស្សន៍សេរីភាពសារព័ត៌មានពិភពលោក ដែលឥឡូវនេះស្ថិតនៅក្រោម ២០ភាគរយជាសកល។

និន្នាការដ៏លេចធ្លោនៅឆ្នាំនេះគឺការកើនឡើងនៃករណីយាយីផ្លូវច្បាប់លើអ្នកសារព័ត៌មាន រួមទាំងការដកហូតអាជ្ញាបណ្ណប្រព័ន្ធផ្សព្វផ្សាយ និងការគំរាមកំហែងដាក់ពន្ធនាគារ។

បើទោះបីជារដ្ឋាភិបាលអះអាងថា វិស័យប្រព័ន្ធផ្សព្វផ្សាយមានស្ថានភាពល្អប្រសើរ ប៉ុន្តែលំហសេរីភាពសារព័ត៌មានដោយគ្មានការភ័យខ្លាច ដែលទាមទារអ្នកដឹកនាំនយោបាយយកចិត្តទុកដាក់ នៅតែបន្តធ្លាក់ចុះ។

អស់រយៈពេលប្រាំឆ្នាំ របាយការណ៍នេះបានប្រើជាការរំលឹកអំពីការគំរាមកំហែងទៅលើអ្នកសារព័ត៌មាន និងតម្រូវការច្បាប់ គោលនយោបាយ និងសកម្មភាពដែលធានានូវការការពាររបស់ពួកគេ។ ប៉ុន្តែវានឹងមិនមានការផ្លាស់ប្តូរនោះទេ ប្រសិនបើអ្នកនយោបាយគ្មានឆន្ទៈ ហើយនេះទាមទារឱ្យមានការចូលរួមជំរុញពីសាធារណជន។

យើងជំរុញឱ្យរដ្ឋាភិបាលកម្ពុជាចាត់វិធានការឱ្យបានម៉ត់ចត់ ដើម្បីធានាថាអ្នកសារព័ត៌មានអាចធ្វើការងាររបស់ពួកគេដោយមិនភ័យខ្លាច ការបំភិតបំភ័យ អំពើហិង្សា ឬការគាបសង្កត់ផ្នែកច្បាប់។

# អនុសាសន៍

យើងបន្តអំពាវនាវឱ្យរដ្ឋាភិបាល និងអាជ្ញាធរពាក់ព័ន្ធលើកកម្ពស់សេរីភាពសារព័ត៌មាន និងគោរពចំពោះកាតព្វកិច្ចប្រកបដោយវិជ្ជាជីវៈរបស់អ្នកសារព័ត៌មាន ដូចជាឯកជនភាពរបស់ប្រភព ក៏ដូចជាបង្ហាញការប្តេជ្ញាចិត្តក្នុងការបញ្ចប់ការយាយីមកលើអ្នកសារព័ត៌មាន។ ពិសេសជាងនេះទៅទៀត យើងទទូចឱ្យអាជ្ញាធរ និងបុគ្គលឯកជនៈ

1. បញ្ឈប់ការប្រើប្រាស់បទចោទប្រកាន់ព្រហ្មទណ្ឌទៅលើអ្នកសារព័ត៌មាន និងអ្នកសារព័ត៌មានពលរដ្ឋដែលបំពេការងារពាក់ព័ន្ធនឹងសារព័ត៌មាន អ្នកការពារសិទ្ធិមនុស្ស និងអ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម។
2. បញ្ចប់និទណ្ឌភាពប្រឆាំងនឹងអ្នកសារព័ត៌មាន ដោយធ្វើការស៊ើបអង្កេតភ្លាមៗ ផ្តន្ទាទោស និងដោះស្រាយករណីហិង្សា លើអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស។
3. ផ្តល់ការគាំទ្រដោយប្តេជ្ញាចិត្ត ការបណ្តុះបណ្តាល និងធនធានដល់អង្គភាពដែលមានភារកិច្ច ស៊ើបអង្កេតបទល្មើសប្រឆាំងអ្នកសារព័ត៌មាន។
4. ទម្លាក់បទចោទប្រកាន់ជាបន្ទាន់ប្រឆាំងនឹងអ្នកសារព័ត៌មាន និងពិនិត្យឡើងវិញនូវទោសព្រហ្មទណ្ឌទៅលើអ្នកសារព័ត៌មាន និង អ្នកការពារសិទ្ធិមនុស្ស និងស៊ើបអង្កេតករណីបង្កហិង្សាមកលើពួកគេ។
5. បង្កើត និងអនុវត្តកម្មវិធីបណ្តុះបណ្តាល សម្រាប់អាជ្ញាធរអនុវត្តច្បាប់ ស្តីពីការគោរពសិទ្ធិអ្នកសារព័ត៌មានក្នុងការរាយការណ៍ព័ត៌មាននៅកន្លែងតវ៉ា និងព្រឹត្តិការណ៍សាធារណៈ ផ្សេងទៀត។
6. អនុម័តច្បាប់ប្រព័ន្ធផ្សព្វផ្សាយដោយបង្កើតអាជ្ញាធរផ្សាយឯករាជ្យ និងវិធានច្បាស់លាស់ អព្យាក្រឹតសម្រាប់ការផ្តល់អាជ្ញាបណ្ណផ្សាយស្របតាមស្តង់ដារអន្តរជាតិ។
7. អនុម័តច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មានដែលស្របតាមស្តង់ដារអន្តរជាតិនៅឆ្នាំ២០២៥នេះ។
8. ធ្វើវិសោធនកម្មក្រមព្រហ្មទណ្ឌដើម្បីឱ្យស្របតាមស្តង់ដារអន្តរជាតិនៃសេរីភាព នៃការបញ្ចេញមតិ រួមមានការលុបចោល ឬកែប្រែបទល្មើសញុះញង់ (មាត្រា ៤៩៤, ៤៩៥) និងលុបចោទបទប្រមាថចំពោះអង្គព្រះមហាក្សត្រ (មាត្រា៤៣៧ស្ទួន) បទបរិហាកេរ្តិ៍ជាសាធារណៈ(មាត្រា៣០៥) និងបទជេរប្រមាថជាសាធារណៈ(មាត្រា៣០៧)។
9. ធ្វើវិសោធនកម្មច្បាប់ស្តីពីរបបសារព័ត៌មានឱ្យស្របតាមស្តង់ដារអន្តរជាតិ បង្កើតបទបញ្ញាតិច្បាស់លាស់ជុំវិញការទទួលស្គាល់ស្ថាប័សារព័ត៌មាន និងការចុះបញ្ជីស្ថាប័នព័ត៌មាន។
10. លុបចោលប្រកាសរបស់ក្រសួងព័ត៌មាន ដែលអនុញ្ញាតឱ្យរដ្ឋាភិបាលលុបអាជ្ញាបណ្ណប្រព័ន្ធផ្សព្វផ្សាយដោយមិនបានឆ្លងកាត់និតិវិធីតុលាការ ដែលរំលោភលើគោលការណ៍សេរីភាពសារព័ត៌មាន និងមាត្រា៤១ នៃរដ្ឋធម្មនុញ្ញកម្ពុជា។

11. លុបចោលប្រកាសអន្តរក្រសួងលេខ ១៧០ ដែលប្រើប្រាស់ ដើម្បីដកហូតអាជ្ញាបណ្ណប្រព័ន្ធផ្សព្វផ្សាយដោយគ្មានសេចក្ដីសម្រេចពីតុលាការ ក៏ដូចជាផ្ដល់អំណាចដល់រដ្ឋាភិបាលក្នុងការបញ្ជាឱ្យក្រុមហ៊ុនផ្ដល់សេវាអ៊ីនធឺណិតបិទគេហទំព័រ និងលុបចោលអនុក្រឹត្យស្ដីពីការចុះឈ្មោះដែនជាតិ ការចុះបញ្ជីស៊ីមកាតជាកាតព្វកិច្ច និងច្រកទ្វារអ៊ីនធឺណិតជាតិ។

12. កំណត់ព្រំដែនច្បាស់លាស់លើអំណាចរបស់អាជ្ញាធរក្នុងការតាមដាន និងបិទគេហទំព័រអ៊ីនធឺណិតដោយគ្មានដីការបស់តុលាការ និងកែសម្រួលច្បាប់ទូរគមនាគមន៍ឱ្យស្របតាមបទដ្ឋានអន្តរជាតិ។

13. រៀបចំការពិគ្រោះយោបល់ប្រកបដោយបរិយាបន្នលើសេចក្ដីព្រាងច្បាប់នានា ដែលប៉ះពាល់សេរីភាពនៃការបញ្ចេញមតិ ដើម្បីឱ្យសង្គមស៊ីវិលមានឱកាសផ្ដល់ធាតុចូល និងធានាឱ្យស្របជាមួយកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ (ICCPR) រួមទាំងសេចក្ដីព្រាងច្បាប់ទាក់ទងនឹងឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណិត សន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត និងការការពារទិន្នន័យផ្ទាល់ខ្លួន។

14. ពង្រីកការទទួលបានសេវាអ៊ីនធឺណិតដល់ប្រជាពលរដ្ឋ ដើម្បីធានាថាប្រជាពលរដ្ឋកម្ពុជាទាំងអស់អាចទទួលបានព័ត៌មានតាមអ៊ីនធឺណិត។ ការងារនេះអាចសម្រេចបានតាមរយៈ៖

    - ធានានូវសិទ្ធិទទួលបានស្មើគ្នាដោយក្រុមពលរដ្ឋដែលបាត់បង់ឱកាស រួមទាំងស្ត្រី ជនពិការ និងជនជាតិដើមភាគតិច។
    - លើកទឹកចិត្តដល់វិស័យទូរគមនាគមន៍ ផ្ដល់នូវជម្រើសដែលមានតម្លៃទាប ទាំងក្នុងទីក្រុង និងជនបទ តាមរយៈការបន្ធូរបន្ថយពន្ធ ការឧបត្ថម្ភធនធាន ឬគម្រោងស្រដៀងគ្នា។
    - ការពង្រីកសេវាទូរស័ព្ទចល័តនៅតំបន់ជនបទ អមដោយឥណទាន ឬការឧបត្ថម្ភធនដល់ប្រជាពលរដ្ឋ ដែលមិនមានលទ្ធភាពទិញឧបករណ៍ ឬសេវាអ៊ីនធឺណិតសម្រាប់ប្រើផ្ទាល់ខ្លួន។
    - បង្កើតមជ្ឈមណ្ឌលអ៊ីនធឺណិតសហគមន៍ជាកន្លែង ដែលសមាជិកសហគមន៍អាចប្រើប្រាស់សេវាអ៊ីនធឺណិតនិងកុំព្យូទ័រដោយឥតគិតថ្លៃឬក្នុងតម្លៃទាប។

15. បង្កើនការអប់រំអក្ខរកម្មឌីជីថល ទាំងនៅក្នុងកម្មវិធីអប់រំផ្លូវការ ដូចជានៅតាមសាលារៀន និងសាកលវិទ្យាល័យ ក៏ដូចជានៅក្នុងកម្មវិធីអប់រំក្រៅផ្លូវការ។ គោលបំណង គឺដើម្បីធ្វើឱ្យប្រជាពលរដ្ឋកម្ពុជាអាចបែងចែករវាងប្រភពព័ត៌មានល្អនិងប្រភពព័ត៌មានមិនល្អ ក៏ដូចជាអាចវាយតម្លៃព័ត៌មានដែលពួកគេទទួលបាន។

# VIII. ឧបសម្ព័ន្ធ

## យាយីផ្នែកច្បាប់

### ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៤ ខេត្តកណ្ដាល

អ្នកសារព័ត៌មានអនឡាញពីរនាក់មកពីអង្គភាព SSB TV News ត្រូវបានតុលាការ ខេត្តកណ្ដាល ចោទប្រកាន់ពីបទកំហែងហែកកេរ្តិ៍ តាមមាត្រា ៣៧២ និង ៣៧៣ នៃក្រមព្រហ្មទណ្ឌ ហើយត្រូវបានបញ្ជូនទៅឃុំខ្លួនបណ្ដោះអាសន្ននៅពន្ធនាគារខេត្តកណ្ដាល កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៤។

ដំបូងឡើយ នគរបាល បាននិយាយថា អ្នកសារព័ត៌មានទាំងពីរនាក់ត្រូវបានចាប់ខ្លួនពីបទជំរិតទារប្រាក់ និងក្លែងបន្លំឯកសារ។ ហើយពេលនោះ នគរបាលមិនបានបញ្ជាក់ថា តើអ្នកណាជាដើមបណ្ដឹងនោះទេ។

ទោះជាយ៉ាងណាក៏ដោយ ស្នងការដ្ឋាននគរបាលខេត្តកណ្ដាលកាលពីថ្ងៃទី១៦ ខែធ្នូ បានបង្ហោះសារសន្ទនារវាងអ្នកសារព័ត៌មានតាមបណ្ដាញ តេឡេក្រាម និងបុគ្គលម្នាក់ដែលមានឈ្មោះក្នុងតេឡេក្រាម “វាសនា” បានស្ម័គ្រចិត្តផ្ដល់ប្រាក់មួយចំនួនដល់អ្នកសារព័ត៌មាននោះសម្រាប់ថ្លៃសាំង។

### ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២៤ ខេត្តបាត់ដំបង

តុលាការខេត្តបាត់ដំបងបានកោះហៅចាងហ្វាងសារព័ត៌មានបាណន់សន្តិភាព តាមបណ្ដឹងរបស់លោក ស្រេង សុខា អភិបាលស្រុកបាណន់ ពីបទបរិហារកេរ្តិ៍ជាសាធារណៈ បន្ទាប់ពីលោកបានធ្វើសេចក្ដីរាយការណ៍ពីបញ្ហាសង្គម និងបរិស្ថាននៅក្នុងខេត្តនេះ។

ព្រះរាជអាជ្ញារង ឈ្មោះ ដួង សារ៉ន បានចេញដីកាកោះហៅចំនួន៥ កាលពីថ្ងៃទី២ ខែធ្នូ ដោយបង្គាប់ឱ្យអ្នកសារព័ត៌មានរូបនេះ ចូលទៅកាន់តុលាការ ដើម្បីសាកសួរនៅថ្ងៃទី១៨ ខែធ្នូ ពាក់ព័ន្ធនឹងការបង្ហោះសារនៅតាមហ្វេសប៊ុក និងសេចក្ដីរាយការណ៍ចំនួន៥លើកនៅចន្លោះខែតុលា ដល់ ខែវិច្ឆិកា។ អ្នកសារព័ត៌មានរូបនេះបាននិយាយថា លោកត្រូវបានតុលាការសាកសួរអំពីព័ត៌មានដែលលោកបានចេញផ្សាយនៅអំឡុងពេលនោះ។

ក្នុងចំណោមការបង្ហោះសារទាំងនោះ ដែលខេមបូចាបានពិនិត្យ មានសារចំនួន៤ ត្រូវបានបង្ហោះលើគណនីផ្ទាល់ខ្លួនរបស់លោក ដោយលើកឡើងថា អាជ្ញាធរមូលដ្ឋានបានប្រព្រឹត្តអំពើពុករលួយក្នុងការគ្រប់គ្រងសម្បត្តិសាធារណៈរបស់រដ្ឋ និងរបាយការណ៍មួយ ដែលជាការផ្សាយផ្ទាល់អំពីក្រុមកីឡាករប្រណាំងទូក បានទទូចឱ្យអាជ្ញាធរមានតម្លាភាពចំពោះអំណោយ ដែលប្រមូលបានពីសប្បុរសជនពេលពួកគេចូលរួមប្រណាំងក្នុងពិធីបុណ្យអុំទូក។

## ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២៤ ខេត្តកំពង់ចាម

តុលាការខេត្តកំពង់ចាមបានកោះហៅចាងហ្វាងសារព័ត៌មានអនឡាញ KH Plus News ជុំវិញការចោទប្រកាន់ថា បាននិយាយបង្ខូចកេរ្តិ៍ឈ្មោះស្ថាប័ន តុលាការ បន្ទាប់ពីតុលាការមិនទទួលយកការសុំទោសពីអ្នកសារព័ត៌មានរូបនោះ។

យោងតាមដីកាកោះហៅ ចាងហ្វាងការផ្សាយរូបនេះ ត្រូវបានចោទថា បានប្រើសម្តីមិនសមរម្យលើស្ថាប័នតុលាការជាបន្តបន្ទាប់ ចែករំលែកព័ត៌មានមិនពិតដែលធ្វើឱ្យប៉ះពាល់កិត្តិយសរបស់តុលាការ និងបានរិះគន់សេចក្តីសម្រេចរបស់តុលាការលើវិវាទដីធ្លី។

សារព័ត៌មានអនឡាញ KH Plus News បានថតវីដេអូផ្សាយផ្ទាល់អំពីវិវាទដីធ្លីរវាងប្រជាពលរដ្ឋពីរគ្រួសារនៅស្រុកកំពង់សៀម កាលពីថ្ងៃទី២០ និង២១ ខែវិច្ឆិកា ឆ្នាំ២០២៤។ ចាងហ្វាងការផ្សាយរូបនេះ ត្រូវបានចោទថា បានប្រើពាក្យសម្តីមិនសមរម្យនៅក្នុងវីដេអូទាំងនោះ និងបានរិះគន់អាជ្ញាធរមូលដ្ឋាន និងតុលាការខេត្តថា មិនបានដោះស្រាយវិវាទនេះដោយត្រឹមត្រូវ និងយុត្តិធម៌ទេ ។

ករណីនេះត្រូវបានទម្លាក់ចោល បន្ទាប់ពីមានការសម្របសម្រួលពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

## ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២៤ ខេត្តមណ្ឌលគិរី

ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តមណ្ឌលគិរីបានបង្គាប់ឱ្យចាងហ្វាងអង្គភាពព័ត៌មាន MDTV News នៅខេត្តមណ្ឌលគិរី ចូលខ្លួនទៅកាន់តុលាការនៅថ្ងៃទី២៦ ខែធ្នូ ដើម្បីសាកសួរពាក់ព័ន្ធនឹងពាក្យបណ្តឹងរបស់ឈ្មោះ យូ ចាន់ទី ដែលតាមចោទថា បានចាក់ដីរំលោភយកប្រឡាយសាធារណៈដោយខុសច្បាប់។ ករណីនេះ ផ្តោតលើសេចក្តីរាយការណ៍ចំនួនពីរ ដែលបានចេញផ្សាយកាលពីថ្ងៃទី១៨ និង ១៩ ខែមិថុនា។

ចាងហ្វាងរូបនេះបានឱ្យដឹងថា សេចក្តីរាយការណ៍របស់លោក គឺផ្អែកលើព័ត៌មានដែលផ្តល់ដោយអ្នកភូមិ ដែលរស់នៅក្បែរប្រឡាយនោះ ក៏ដូចជាការចុះធ្វើសេចក្តីរាយការណ៍ដល់ទីតាំងផងដែរ។ លោកបាននិយាយថា នៅថ្ងៃទី២០ ខែមិថុនា រដ្ឋបាលក្រុងសែនមនោរម្យ បានទទួលស្គាល់ថា លោក ចាន់ទី ដែលជាអតីតសមាជិកក្រុមប្រឹក្សាស្រុកកោះញែកបានចាក់ឱ្យាច់លុបប្រឡាយនេះមែន ហើយបានបញ្ជាឱ្យគាត់កាយឱ្យាច់ចេញពីប្រឡាយនោះវិញ។

លោកបាននិយាយថា ក្រោយមកលោកបានទទួលលិខិតមួយច្បាប់ពីរដ្ឋបាលក្រុងសែនមនោរម្យ ដោយបញ្ជាឱ្យ លោកធ្វើការកែតម្រូវអត្ថបទក្នុងរយៈពេល៧២ម៉ោង។ អាជ្ញាធរអះអាងថា សេចក្តីរាយការណ៍នេះ មិនគ្រប់ជ្រុងជ្រោយ និងផ្អែកលើ "ការញុះញង់" ពីបុគ្គលផ្សេង។

## ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៤ ខេត្តស្ទឹងត្រែង

អ្នកសារព័ត៌មានសេរីម្នាក់ (Freelancer) ដែលរាយការណ៍អំពីបញ្ហាបរិស្ថាន ត្រូវបានអាជ្ញាធរខេត្តស្ទឹងត្រែងចាប់ និងឃុំខ្លួនដើម្បីសាកសួរអស់រយៈពេល២ថ្ងៃ ដោយសារបានចូលទៅទីតាំង ដែលគេអះអាងថាជាតំបន់ហាមឃាត់។

អ្នកសារព័ត៌មានរូបនេះ ដែលធ្លាប់ធ្វើការឱ្យស្ថាប័នព័ត៌មានមួយចំនួន រួមទាំងសារព័ត៌មានម៉ុងហ្គាបេផងនោះ ត្រូវបានចាប់ខ្លួនជាមួយសកម្មជនបរិស្ថាន ៥នាក់ផ្សេងទៀត។ ទីតាំងដែលពួកគេបានចូលនោះ ត្រូវបានគេជឿថា ស្ថិតក្រោមប្រតិបត្តិការដោយក្រុមហ៊ុន T.S.M.W Co Ltd ក្នុងឧទ្យានជាតិវីរៈសៃ-សៀមប៉ាង ក្នុងខេត្តស្ទឹងត្រែង។ ទាហានដែលឈរជើងក្នុងតំបន់ឧទ្យានជាតិនេះ បានចាប់ខ្លួនពួកគេ និងបញ្ជូនទៅបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្ត ដើម្បីសាកសួរ។

អំឡុងពេលសាកសួរ កងរាជអាវុធហត្ថបានគំរាមចោទប្រកាន់អ្នកសារព័ត៌មានរូបនេះ តាមមាត្រា៤៩៤ នៃក្រមព្រហ្មទណ្ឌ ពីបទចូលទៅតំបន់ហាមឃាត់ និងប្រមូលព័ត៌មាន ដើម្បី “លក់ទៅឱ្យបរទេស”។

អ្នកសារព័ត៌មានរូបនេះ បាននិយាយថា អាជ្ញាធរបានរឹបអូសសម្ភារៈរបស់លោករួមមានដ្រូន ទូរសព្ទស្មាតហ្វូន ឧបករណ៍ចាប់ទីតាំង និងថ្នាំងសាក ដើម្បីធ្វើការស៊ើបអង្កេតបន្ថែម។

លោកបន្តថា មនុស្សម្នាក់ ដែលមកជាមួយព្រះរាជអាជ្ញាខេត្តក្នុងអំឡុងពេលសាកសួរបានអះអាងថាជាមេធាវីផង និងបានសុំឱ្យលោក និងសកម្មជនផ្សេងទៀតបង់ប្រាក់ម្នាក់ៗ ១០០០ ដុល្លារ (សរុប ៦០០០ ដុល្លារ) ជាថ្នូរនឹងការដោះលែង និងមិនចោទប្រកាន់ ។ អ្នកសារព័ត៌មានរូបនោះបានឱ្យដឹងថាក្រោយមានការចរចាគ្នា លោក និងសកម្មជន ៥នាក់ផ្សេងទៀតយល់ព្រមបង់ ១០០០ដុល្លារជាថ្នូរ នឹងការដោះលែង និង មិនចោទប្រកាន់ ។ លោកបន្តថា សម្ភារៈមិនត្រូវបានប្រគល់ឱ្យវិញទេ។

## ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៤ ខេត្តកណ្ដាល

អ្នកសារព័ត៌មានអនឡាញចំនួន៥នាក់ មកពីស្ថាប័នសារព័ត៌មានផ្សេងៗគ្នា ត្រូវបានមន្ត្រីនគរបាលខេត្តកណ្ដាលសាកសួរបន្ទាប់ពីធ្វើសេចក្តីរាយការណ៍អំពីប្រតិបត្តិការល្បែងស៊ីសងខុសច្បាប់មួយកន្លែងនៅក្នុងខេត្តនេះ។

សារព័ត៌មាន វីអូឌី រាយការណ៍កាលពីថ្ងៃទី១៩ ខែវិច្ឆិកាថា អ្នកសារព័ត៌មានទាំង៥នាក់នោះ ត្រូវបានឃាត់ខ្លួន និងឃុំខ្លួនរយៈពេលមួយថ្ងៃ ដើម្បីសាកសួរ។

ស្នងការនគរបាលខេត្តកណ្ដាលបានបដិសេធថា ពុំមានការឃាត់ខ្លួន និងឃុំខ្លួនអ្នកសារព័ត៌មានទាំងនោះទេ ដោយអះអាងថា នគរបាលគ្រាន់តែស្នើសុំឱ្យពួកគេផ្ដល់ព័ត៌មានលម្អិតពាក់ព័ន្ធនឹងសេចក្តីរាយការណ៍នោះប៉ុណ្ណោះ ហើយថា ពួកគេត្រូវបានអនុញ្ញាតឱ្យត្រឡប់ទៅផ្ទះវិញ បន្ទាប់ពីសាកសួររួច។

សារព័ត៌មាន វីអូឌី បានស្រង់សម្ដីប្រភពមួយ ដែលអះអាងថា អ្នកសារព័ត៌មានទាំង៥នាក់នោះ ត្រូវបានឃុំខ្លួនមួយយប់ ដើម្បីសាកសួរ និងស្នើឱ្យធ្វើកិច្ចសន្យាមុនពេលពួកគេត្រូវបានដោះលែង។

អ្នកសារព័ត៌មានទាំងនោះក៏បានបង្ហាញមុខនៅក្នុងវីដេអូមួយដែលបានផ្សាយនៅលើទូរទស្សន៍អនឡាញ ធីអេសភី ៦៨ ធីវី (TSP68 TV) ដោយនិយាយថា ពួកគេមិនត្រូវបានឃាត់ខ្លួន និងឃុំខ្លួនដូច ដែលសារព័ត៌មាន វីអូឌី បានរាយការណ៍នោះទេ។

## ថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២៤ ខេត្តកែប

អ្នកសារព័ត៌មានអនឡាញម្នាក់មកពីស្ថាប័នព័ត៌មាន ICDTV ប្រចាំខេត្តកែប ត្រូវបានតុលាការខេត្តកែបកោះហៅមកសាកសួរ បន្ទាប់ពីទទួលបានបណ្តឹងពីលោក សៅ សារឿន ដែលគេអះអាងថា ជាមន្រ្តីយោធា។

អ្នកសារព័ត៌មានរូបនេះ ត្រូវបានប្តឹងពីបទរំលោភសិទ្ធិឯកជនភាព បន្ទាប់ពីលោកបានចុះផ្សាយសេចក្តីរាយការណ៍កាលពីថ្ងៃទី១០ និងថ្ងៃទី២២ ខែសីហា ថា លោក សារឿន មានជាប់ពាក់ព័ន្ធការឈូសឆាយ និងទន្ទ្រានយកដីភ្នំរបស់រដ្ឋ។

អ្នកសារព័ត៌មានរូបនេះ និយាយថា សេចក្តីរាយការណ៍នេះ គឺផ្អែកលើព័ត៌មានពីអ្នកភូមិ និងឯកសារចេញដោយអាជ្ញាធរស្រុកដំណាក់ចង្អើរ។

លិខិតរបស់រដ្ឋបាលស្រុកដំណាក់ចង្អើរផ្ញើជូនលោក សៅ សារឿន ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២៤ បានជូនដំណឹងអំពីការកាន់កាប់ខុសច្បាប់លើដីទំហំជាង ៨៩០០០ម៉ែត្រការ៉េ ទីដែលលោកបានសាងសង់ផ្លូវបេតុង បង្គន់អនាម័យ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀត។ រដ្ឋបាលស្រុកដំណាក់ចង្អើរបានស្នើឱ្យលោក សារឿន បញ្ឈប់ការសាងសង់ និងការឈូសឆាយដីបន្ថែមទៀត។

ប៉ុន្តែបន្ទាប់ពីមានសេចក្តីរាយការណ៍នេះ លោក សារឿន ក៏បានដាក់ពាក្យប្តឹងទៅក្រសួងព័ត៌មាន មុនពេលលោកប្តឹងទៅតុលាការ ។

នៅថ្ងៃទី២០ ខែកញ្ញា ក្រសួងបានកោះហៅអ្នកសារព័ត៌មានរូបនេះ មកពិភាក្សាអំពីក្រមសីលធម៌វិជ្ជាជីវៈ និងជំរុញឱ្យលោកគោរពធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន។ នៅថ្ងៃទី២៦ ខែតុលា ក្រសួងបានចេញលិខិតព្រមានដោយបញ្ជាឱ្យស្ថាប័នព័ត៌មាននេះ ដកអត្ថបទ រូបភាព និងវីដេអូ ដែលពាក់ព័ន្ធនឹងលោក សៅ សារឿន។

ចាងហ្វាងការផ្សាយរបស់ស្ថាប័នព័ត៌មាន ICDTV បាននិយាយថា ស្ថាប័នរបស់លោកបានដកសេចក្តីរាយការណ៍ព័ត៌មានទាំងពីរចេញ ហើយបានសុំអភ័យទោសលោក សៅ សារឿន។ ប៉ុន្តែលោក បានចេញផ្សាយសេចក្តីរាយការណ៍ព័ត៌មាននេះឡើងវិញថ្ងៃទី២២ ខែសីហា បន្ទាប់ពីលោក សារឿន បានប្តឹងអ្នកសារព័ត៌មានរូបនេះទៅតុលាការ។

## ២៤ ខែតុលា ឆ្នាំ២០២៤ ខេត្តតាកែវ

អ្នកសារព័ត៌មានពីរនាក់មកពីទូរទស្សន៍អនឡាញ Sunday TV Online និងសារព័ត៌មានកោះសន្តិភាព ត្រូវបានបុរសម្នាក់ដែលគេស្គាល់ឈ្មោះថា សុត វុធ ប្តឹងទៅតុលាការ។ នៅក្នុងសេចក្តីរាយការណ៍របស់អ្នកសារព័ត៌មានទាំងពីរបានចោទប្រកាន់បុរសឈ្មោះ សុត វុធ ថាបានជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តអំពើពុករលួយទាក់ទងនឹងការនាំចេញស្រូវនៅច្រកព្រំដែនកម្ពុជា វៀតណាមក្នុងខេត្តតាកែវ។

បើតាមពាក្យបណ្តឹងចុះថ្ងៃទី២២ ខែតុលា ដែលខេមបូចាទទួលបាន លោក សុត វុធ ដែលអះអាងក្នុងពាក្យបណ្តឹងនោះថា ជាកូនប្រុសរបស់លោកស្រី ហ៊ុន ប៊ុនធឿន ប្អូនស្រីបង្កើតរបស់លោក ហ៊ុន សែន ប្រធានព្រឹទ្ធសភា បានស្នើឱ្យក្រសួងព័ត៌មានចាត់វិធានការតាមផ្លូវច្បាប់ចំពោះបុគ្គល និងស្ថាប័នព័ត៌មានទាំងពីរនេះ និងដកហូតអាជ្ញាបណ្ណសារព័ត៌មានរបស់ពួកគេ។

លោក សុត វុធ បានចោទស្ថាប័នព័ត៌មានទាំងពីរថា បានផ្សាយព័ត៌មានមិនពិត ដែលធ្វើឲ្យប៉ះពាល់ដល់កិត្តិយស និងសេចក្ដីថ្លៃថ្នូររបស់លោក និងទាមទារសំណងជំងឺចិត្តចំនួន ២០ម៉ឺនដុល្លារពីអ្នកសារព័ត៌មានទាំងពីរនោះ។

ករណីនេះក្រោយមកត្រូវបានបញ្ចប់ដោយស្ថាប័នទាំងពីរនេះបានដកអត្ថបទនោះចេញ។

## ថ្ងៃទី៣០ កញ្ញា ឆ្នាំ២០២៤ ភ្នំពេញ

លោក ម៉ិច ដារ៉ា អតីតអ្នកយកព័ត៌មាននៅ វីអូឌី ដែលគេស្គាល់ភាគច្រើនតាមរយៈការរាយការណ៍យ៉ាងសកម្ម អំពីការជួញដូរមនុស្ស និងការឆបោកតាមប្រព័ន្ធអនឡាញនៅកម្ពុជា ត្រូវបានចាប់ខ្លួននៅថ្ងៃទី៣០ ខែកញ្ញា និង ចោទប្រកាន់ពីបទ «ញុះញង់បង្កឱ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម» ជុំវិញការបង្ហោះរូបភាព និងការ បញ្ចេញមតិរបស់លោកលើបណ្ដាញសង្គម។ ភ្លាមៗលោកត្រូវបានឃុំខ្លួននៅពន្ធនាគារខេត្តកណ្ដាល។ ការចាប់ ខ្លួននេះបានរងនូវប្រតិកម្មពីសំណាក់ក្រុមសង្គមស៊ីវិលជាតិ អន្តរជាតិ ស្ថាប័នប្រព័ន្ធផ្សព្វផ្សាយ អ្នកសារព័ត៌មាន ក្លឹបអ្នកសារព័ត៌មាន និងរដ្ឋាភិបាលបរទេស។

លោក ម៉ិច ដារ៉ា ដែលជាអ្នកសារព័ត៌មានឯករាជ្យ ត្រូវបានអាជ្ញាធរចាប់ខ្លួនវេលាម៉ោង ៣ និង ៥៧ នាទីរសៀល នៅត្រង់ផ្លូវបំបែកស្រែអំបិលនៃផ្លូវល្បឿនលឿនឆ្ពោះមកទីក្រុងភ្នំពេញ ស្ថិតក្នុងស្រុកស្រែអំបិលខេត្តកោះកុង ថ្ងៃទី៣០ ខែកញ្ញា ខណៈលោកកំពុងឈប់រថយន្តនៅបញ្ជរបង់ប្រាក់នៅលើផ្លូវល្បឿនលឿន។

តាមការបញ្ជាក់ពីមន្ត្រីអង្គការការពារសិទ្ធិមនុស្សលីកាដូ លោក ម៉ិច ដារ៉ា បានផ្ញើសារពីការចាប់ខ្លួនរបស់លោក មកបុគ្គលិកអង្គការលីកាដូ មុនពេលទូរស័ព្ទលោកត្រូវបានដកហូត ដោយសរសេរថា៖«ខ្ញុំត្រូវបានចាប់ខ្លួន ហើយ ត្រូវបានបញ្ជូនទៅកងរាជអាវុធហត្ថខេត្ត»។

តាមប្រភពព័ត៌មាន លោក ម៉ិច ដារ៉ា បានធ្វើដំណើរកម្សាន្តជាមួយក្រុមគ្រួសារទៅកាន់ខេត្តព្រះសីហនុ ប៉ុន្តែនៅ តាមផ្លូវត្រឡប់មកភ្នំពេញវិញលោកត្រូវបានចាប់ខ្លួនតែម្ដង។

មួយថ្ងៃមុនពេលចាប់ខ្លួន លោក ដារ៉ាបានបង្ហោះរូបភាពដែលអះអាងថាមានការបំផ្លិចបំផ្លាញភ្នំនៅរមណីយដ្ឋាន «បាភ្នំ» ប៉ុន្តែត្រូវបានរដ្ឋបាលស្រុកបាភ្នំច្រានចោលតាមរយៈវីដេអូ និងសេចក្ដីប្រកាសដែលបង្ហោះលើបណ្ដាញ សង្គមហ្វេសប៊ុកដោយបញ្ជាក់ថា ការបង្ហោះរបស់លោកដារ៉ា ជាការផ្សព្វផ្សាយព័ត៌មានក្លែងក្លាយ។ នៅក្នុងវីដេអូ បង្ហោះដោយរដ្ឋបាលស្រុកបាភ្នំ បានស្នើឱ្យក្រសួងព័ត៌មានចាត់វិធានការផ្លូវច្បាប់ចំពោះលោក ដារ៉ា។
លោក ម៉ិច ដារ៉ា ត្រូវបានដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្ននៅថ្ងៃទី២៤ តុលា បន្ទាប់ពីជាប់ពន្ធនាគារ ខេត្តកណ្ដាលជាង២០ថ្ងៃ។

## ថ្ងៃទី១៧ កញ្ញា ឆ្នាំ២០២៤ ខេត្តស្ទឹងត្រែង

អ្នកសារព័ត៌មាននៃអង្គភាព Intri Plus News ម្នាក់ដែលតែងតែរាយការណ៍ពីបញ្ហាបរិស្ថានក្នុងខេត្តស្ទឹងត្រែង ត្រូវបានតុលាការខេត្តចោទប្រកាន់ពីបទញុះញង់ និងទន្ទ្រានយកដីព្រៃ។ នេះបើយោងតាមមេធាវីរបស់ អ្នក សារព័ត៌មាន។

កាលពីថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២៤ មេធាវីបាននិយាយថា អ្នកសារព័ត៌មានត្រូវបានសាកសួរដោយតុលាការខេត្តក្រោមបទចោទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ និងទន្ទ្រានយកដីព្រៃ។ គាត់ត្រូវបានចោទថាបាន ប្រព្រឹត្តបទល្មើសកំឡុង ឆ្នាំ២០២៣ និងក្នុងខែមិថុនា ឆ្នាំ២០២៤ នៅឃុំសំអាង ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង។ អ្នកសារព័ត៌មានត្រូវបានដាក់ ឱ្យស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការ។ អ្នកសារព័ត៌មានដែលជាសកម្មជនបរិស្ថានរូបនេះ បានបដិសេធការចោទ ប្រកាន់នេះ ហើយបាននិយាយថា ចំណាត់ការផ្លូវច្បាប់លើរូបគាត់ដោយសារតែគាត់តែងតែធ្វើសេចក្តីរាយការណ៍ដែល ធ្វើឱ្យប៉ះពាល់ដល់ផល ប្រយោជន៍បុគ្គលមួយចំនួន។

មុនពេលរងការចោទប្រកាន់ អ្នកសារព័ត៌មានរូបនេះត្រូវបានកងរាជអាវុធហត្ថខេត្តកោះហៅមកសាកសួរ រយៈពេល ៨ ម៉ោង កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៤ តាមពាក្យបណ្តឹងរបស់អ្នកស្រី កែ កុលសោភា ម្ចាស់ក្រុមហ៊ុន លីម វត្តី ដែល ប្រកបអាជីវកម្មថ្មម៉ាបក្នុងខេត្ត។

ក្រុមហ៊ុននេះបានប្តឹងអ្នកសារព័ត៌មានពីបទប៉ះពាល់ដល់សិទ្ធិខាងរូបភាពនៃបុគ្គល តាមមាត្រា ៣០២ នៃក្រមព្រហ្មទណ្ឌ ដែលបានប្រព្រឹត្តកាលពីថ្ងៃទី១៦ ខែ ឧសភា ឆ្នាំ២០២៤។ គាត់ត្រូវបានចោទប្រកាន់ពី បទចូលក្នុងទីតាំងរបស់ក្រុមហ៊ុន និងថតរូបនៅក្នុងបរិវេណ។

ទោះជាយ៉ាងណា អ្នកសារព័ត៌មានបាននិយាយថា គាត់បានចូលទៅព្រៃសហគមន៍ភ្នំជម្រកសត្វ បន្ទាប់ពីអ្នកភូមិរាយការណ៍ពីការកាប់ឈើខុសច្បាប់។ ទូរសព្ទរបស់អ្នកសារព័ត៌ មានត្រូវបានដកហូត ក្នុងអំឡុងពេលសាកសួរ ហើយរូបភាព និងវីដេអូត្រូវបានលុបចោល។ ក្រោយមកគាត់ត្រូវបានគេស្នើឱ្យ សុំទោសក្រុមហ៊ុនជាសាធារណៈ។

កាលពីថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៤ អ្នកសារព័ត៌មានត្រូវបានចៅក្រមស៊ើបសួរសាលាដំបូងខេត្តស្ទឹង ត្រែង លោក ផុន វណ្ណា បង្គាប់ឱ្យចូលខ្លួនទៅតុលាការនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២៤ ក្រោមការចោទ ប្រកាន់ពីបទទន្ទ្រានយកដីព្រៃ និងញុះញង់។ លោកត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តនៅតំបន់អភិរក្សក្នុងដែនជម្រកសត្វព្រៃធែប-ព្រះរកាក្នុងឃុំសំអាង ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង។
ថ្លែងប្រាប់សារព័ត៌មាន អ្នកនាំពាក្យសាលាដំបូងខេត្តបាននិយាយថា ចំណាត់ការផ្លូវច្បាប់លើ អ្នកសារព័ត៌មានគឺផ្អែកលើភស្តុតាង ប៉ុន្តែលោកមិនអាចផ្តល់ព័ត៌មានលម្អិតបានទេ។

នេះមិនមែនជាករណីទីមួយលើអ្នកសារព័ត៌មាននោះទេ។ មកដល់ពេលនេះ លោកមានសំណុំរឿងផ្លូវច្បាប់ចំនួន ៥ផ្សេង គ្នាដែលភាគច្រើនមានបទចោទប្រកាន់ដូចគ្នា។ នៅខែកញ្ញា ឆ្នាំ២០២៣ គាត់ត្រូវបានកាត់ ទោសឱ្យជាប់ពន្ធនាគារ៥ឆ្នាំ ក្រោមការចោទប្រកាន់ពីបទទន្ទ្រានយកដីព្រៃ។ សំណុំរឿងនេះបានឈានដល់ តុលាការកំពូល។

## ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២៤ ខេត្តឧត្តរមានជ័យ

ចាងហ្វាងសារព័ត៌មានអនឡាញបីនាក់ត្រូវបានប្តឹងពីបទញុះញង់ឱ្យមានការរើសអើងបន្ទាប់ពីរាយការណ៍ អំពីអគារមួយកន្លែងរបស់«បុគ្គលមានអំណាច»កំពុងត្រូវបានជួលទៅឱ្យក្រុមប្រតិបត្តិការល្បែងតាមប្រព័ន្ធអនឡាញនៅក្នុងខេត្តឧត្តរមានជ័យ។

យោងតាមដីការបស់តុលាការចេញនៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២៤ ចាងហ្វាងចំនួនពីររូបត្រូវបានបញ្ជាឱ្យ ចូលខ្លួនទៅសាលាដំបូងរាជធានីភ្នំពេញនៅថ្ងៃទី២១ ខែតុលា ដើម្បីសាកសួរលើបទចោទញុះញង់ឱ្យមានការ រើសអើង ខណៈម្នាក់ទៀតត្រូវបានបង្គាប់ឱ្យចូលខ្លួននៅតុលាការនៅថ្ងៃទី៨ ខែតុលា។

ដីកានេះបង្ហាញថា ពាក្យបណ្ដឹងធ្វើឡើងដោយបុគ្គលម្នាក់ឈ្មោះ វង់ សីហា កាលពីថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២៤។ បើតាមអ្នកសារព័ត៌មាន លោក វង់ សីហា ត្រូវបានគេស្គាល់ថាជាតំណាងឧកញ៉ា លឹម ហេង ម្ចាស់សណ្ឋាគារ រ៉ូយ៉ាល់ហ៊ីល រីសត និងកាស៊ីណូ ដែលមានទីតាំងនៅច្រកទ្វារអន្តរជាតិអូរស្មាច់។

នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ ២០២៤ អង្គភាពសារព័ត៌មានបានចុះផ្សាយព័ត៌មានមួយថា អគារនេះស្ថិតនៅខាងក្នុងបរិវេណកាស៊ីណូមួយដែលត្រូវបានចោទប្រកាន់ថា ជាកម្មសិទ្ធិរបស់ឧកញ៉ាលឹម ហេង និងលោក លី យ៉ុងផាត់

(អត្ថបទត្រូវបានលុបចោល)។ មួយថ្ងៃក្រោយមកអង្គភាពសារព័ត៌មាន S.A TV HD បានចុះផ្សាយព័ត៌មានមួយដែលមានអត្ថន័យដូចគ្នា។

## ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២៤ ភ្នំពេញ

អ្នកសារព័ត៌មាននៃអង្គភាពសារព័ត៌មានអនឡាញ សាន ព្រហ្ម ត្រូវបានកោះហៅមកសាកសួរនៅ អគ្គស្នងការនគរបាលជាតិនៅថ្ងៃទី៩ ខែកញ្ញា តាមពាក្យបណ្តឹងរបស់បុគ្គលម្នាក់ឈ្មោះ ម៉ិច ច័ន្ទមុន្នី ។

កាលពីថ្ងៃទី១៦ ខែកក្កដា អ្នកសារព័ត៌មានបានចុះផ្សាយពីកិច្ចសម្ភាសន៍មួយអំពីជម្លោះដីធ្លីក្នុងគ្រួសារពួកគេ។ អ្នកសារព័ត៌មានបាននិយាយថា ប្រភពខ្លួនឯងផ្ទាល់បានលើកឡើងពីបុគ្គលម្នាក់ឈ្មោះ ច័ន្ទមុន្នី ថាបានពាក់ព័ន្ធនឹងបញ្ហានេះ។

នៅថ្ងៃទី១៨ ខែកក្កដា មេធាវីរបស់លោក ច័ន្ទមុន្នី បានផ្ញើលិខិតមួយច្បាប់ទៅកាន់អ្នកសារព័ត៌មានដោយស្នើ ឱ្យអ្នកសារព័ត៌មានលុបវីដេអូសម្ភាសក្នុងរយៈពេល២៤ម៉ោង បើមិនដូច្នេះទេនឹងប្រឈមមុខនឹងច្បាប់។ គិតត្រឹមថ្ងៃទី៣០ ខែកក្កដា អ្នកសារព័ត៌មានមិនទាន់បានទទួលលិខិតពីមេធាវីទេ។
យ៉ាងណាក៏ដោយលោក ច័ន្ទមុន្នី ក្រោយមកបានដាក់ពាក្យបណ្តឹងទៅអគ្គស្នងការនគរបាលជាតិ ដើម្បីចាត់វិធានការ លើអ្នកសារព័ត៌មាន។ អ្នកសារព័ត៌មានរូបនេះបាននិយាយថាលោកមិនបានដឹងអំពីការប្តឹងនេះទេ។ វីដេអូត្រូវបានលុបចេញនៅថ្ងៃទី២ ខែសីហា បន្ទាប់ពីពិភាក្សាជាមួយចាងហ្វាងអង្គភាព ក្រោយពីលោកបានទទួលពាក្យបណ្តឹង។

អ្នកសារព័ត៌មានត្រូវបានសាកសួរចាប់ពីម៉ោង ៩:៤០ព្រឹក ដល់ម៉ោង ២ រសៀលនិងអនុញ្ញាតឱ្យត្រឡប់ទៅផ្ទះវិញ បន្ទាប់ពីភាគីទាំងពីរបានព្រមព្រៀងបញ្ចប់ជម្លោះ ក៏ដូចជាចេញវីដេអូថ្មីដើម្បីបំភ្លឺវីដេអូមុន ដែលថាមិនពាក់ព័ន្ធនឹង លោក ច័ន្ទមុន្នី។

កំឡុងពេលសាកសួរក្រុមអ្នកសារព័ត៌មានអនឡាញបានប្រមូលផ្តុំគ្នានៅខាងមុខអគ្គស្នងការនគរបាលជាតិដើម្បីមកផ្តល់ការគាំទ្រអ្នកសារព័ត៌មាន។ ក្រុមនេះបាននិយាយថា អ្នកសារព័ត៌មានមិនគួររងការគំរាមកំហែងផ្លូវច្បាប់ឡើយ ។

## ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៤ ខេត្តមណ្ឌលគិរី

អ្នកសារព័ត៌មានអនឡាញ ក្នុងខេត្តមណ្ឌលគិរី ដែល រាយការណ៍ ពីករណីដឹកជញ្ជូន ឈើពីដែនជម្រកសត្វព្រៃកែវសីមាទៅប្រទេសវៀតណាម ត្រូវបានកោះហៅមកសាកសួរតាមពាក្យបណ្តឹងរបស់មន្រ្តីនគរបាលព្រំដែនឡាបាខេក្នុងខេត្តមណ្ឌលគិរី។

អត្ថបទព័ត៌មានចុះផ្សាយនៅថ្ងៃទី២៣ ខែកក្កដា លើកឡើងពីមេប៉ុស្តិ៍នគរបាលព្រំដែនម្នាក់បានសម្របសម្រួលការនាំចេញឈើខុសច្បាប់ទៅប្រទេសវៀតណាម។ មេប៉ុស្តិ៍នគរបាលព្រំដែនឡាបាខេ លោក សា ផល្លា បានប្រាប់ថាលោកមិនជាប់ពាក់ព័ន្ធនឹងបទល្មើសនេះទេ។

## ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៤ ខេត្តពោធិ៍សាត់

អ្នកសារព័ត៌មានបួននាក់មកពីអង្គភាពសារព័ត៌មានផ្សេងគ្នាត្រូវបានចាប់ខ្លួន និងចោទប្រកាន់ដោយតុលាការខេត្តពោធិ៍សាត់ពីបទធ្វើឱ្យប៉ះពាល់ដល់សិទ្ធិខាងរូបភាពនៃបុគ្គលតាមមាត្រា៣០២ នៃក្រមព្រហ្មទណ្ឌ និងជំរិតទារប្រាក់ ក្រោយពួកគេបានចូលក្នុងតំបន់ ដែលគេអះអាងថាជាតំបន់ហាមឃាត់។ ចាងហ្វាងនៃអង្គភាពសារព័ត៌មានម្នាក់ក្នុងចំណោមសារព័ត៌មានទាំងបួននេះបានប្រាប់ខេមបូចាថាអ្នកសារព័ត៌មានបានចូលទៅតំបន់នោះដើម្បីស្វែងរកព័ត៌មាន ដែលសង្ស័យអំពីសកម្មភាពរុករករ៉ែមាស ប៉ុន្តែត្រូវបានចាប់ខ្លួនភ្លាមៗដោយអាជ្ញាធរ។ អ្នកសារព័ត៌មានត្រូវបានដោះលែងឱ្យនៅក្រៅឃុំ កាលពីថ្ងៃទី១៤ ខែកក្កដា បន្ទាប់ពីពួកគេបានសរសេរលិខិតសុំទោសដោយទទួលស្គាល់កំហុសរបស់ខ្លួន។ ពួកគេត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ។

## ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២៤ ខេត្តកណ្តាល

អ្នកសារព័ត៌មានអនឡាញម្នាក់ត្រូវបានអាជ្ញាធរខេត្តកណ្តាលប្តឹងចោទប្រកាន់ពីបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ តាមមាត្រា ៤៩៤, ៤៩៥ នៃក្រមព្រហ្មទណ្ឌ ហើយត្រូវបានកាត់ទោសនៅក្នុងខែសីហា ឱ្យជាប់ ពន្ធនាគាររយៈពេលមួយឆ្នាំ។ អ្នកសារព័ត៌មានរូបនេះបានជាប់ពន្ធនាគាររយៈពេល១ខែ ១៤ថ្ងៃ ហើយទោសដែលនៅសល់ត្រូវបានព្យួរ។ សមាជិកសមាគមសារព័ត៌មានសុក្រឹតរូបនេះ ត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី៦ ខែកក្កដា បន្ទាប់ពីបានចុះផ្សាយអត្ថបទរិះគន់អាជ្ញាធរមូលដ្ឋានថាមិនបានបង្ក្រាបល្បែងជល់មាន់ និងឆ្នោតឡូតូអនឡាញ ដែលបើកដំណើរការនៅក្នុងហាងកាហ្វេមួយក្នុងក្រុងតាខ្មៅ។ នៅក្នុងអត្ថបទដែលបានចុះផ្សាយ បានភ្ជាប់ជាមួយនឹងរូបភាពមន្ត្រីនគរបាលខេត្ត និងអភិបាលខេត្តដែលទើបតែងតាំងថ្មី លោកគួច ចំរើន។ នៅក្នុងអត្ថបទបានរៀបរាប់ថា អាជ្ញាធរមូលដ្ឋានមិនអើពើនឹងសកម្មភាពល្បែងស៊ីសងខុសច្បាប់ ដែលបើកដោយសេរី។ អាជ្ញាបណ្ណរបស់អង្គភាពផ្សព្វផ្សាយព័ត៌មាននេះក្រោយមកត្រូវបានលុបចោលដោយក្រសួងព័ត៌មាន។

## ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៤ ខេត្តមណ្ឌលគិរី

កាលពីថ្ងៃទី១២ ខែមិថុនា ភ្នាក់ងារព័ត៌មានអនឡាញម្នាក់នៅខេត្តមណ្ឌលគិរី មកពីស្ថាប័នព័ត៌មាន Norkor Meas GTV ត្រូវបានតុលាការខេត្តមណ្ឌលគិរីផ្តន្ទាទោសដាក់ពន្ធនាគារ៣ឆ្នាំ ពីបទផ្តើមគំនិតក្នុងអំពើកំហែងយក ប៉ុន្តែទោសទាំងអស់ត្រូវបានព្យួរ។

លោក មាស ប្រុស អ្នកនាំពាក្យសាលាដំបូងខេត្តមណ្ឌលគិរី បានបញ្ជាក់ថា តុលាការបានផ្តន្ទាទោសអ្នកសារព័ត៌មានរូបនេះឱ្យជាប់ពន្ធនាគាររយៈពេល៣ឆ្នាំ ប៉ុន្តែត្រូវបានព្យួរទាំងអស់។

អ្នកសារព័ត៌មានរូបនេះបានបដិសេធការចោទប្រកាន់ ដោយអះអាងថា សេចក្តីសម្រេចរបស់តុលាការ គឺជារឿងអយុត្តិធម៌សម្រាប់រូបលោក។ លោកបាននិយាយថា៖ «ខ្ញុំមិនបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់នោះទេ។ ខ្ញុំក៏មិនបានទទួលប្រាក់សូម្បីមួយរៀលផងដែរ»។

អ្នកសារព័ត៌មានរូបនេះត្រូវបានចោទប្រកាន់ជាមួយអ្នកសារព័ត៌មានបួននាក់ផ្សេងទៀត ដែលរងពីបទកំហែងយកកាលពីខែតុលា ឆ្នាំ២០២៣។ ខណៈដែលអ្នកសារព័ត៌មានបួននាក់ផ្សេងទៀត ដែលនៅពេលនោះត្រូវបានចាប់ និងឃុំខ្លួនក្នុងពន្ធនាគាររយៈពេល៦ខែ មុនត្រូវបានដោះលែងឱ្យនៅក្រៅឃុំកាលពីខែមីនា ឆ្នាំ២០២៤ អ្នកសារព័ត៌មានរបស់ Norkor Meas GTV រូបនេះ មិនត្រូវបានចាប់ខ្លួនទេរហូតដល់លោកត្រូវបានកាត់ទោស។

## ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៤ ខេត្តកំពង់ធំ

អ្នកសារព័ត៌មានអនឡាញម្នាក់នៅខេត្តកំពង់ធំ ត្រូវបានចាប់ និងឃុំខ្លួននៅពន្ធនាគារ ដោយចោទប្រកាន់ពីបទញុះញង់ និងបរិហារកេរ្តិ៍។ អ្នកសារព័ត៌មានរូបនេះបានធ្វើការឡាយវីដេអូរិះគន់ប្រធានមន្ទីរបរិស្ថានខេត្ត និងអាជ្ញាធរជុំវិញសកម្មភាពកាប់បំផ្លាញព្រៃឈើនៅក្នុងខេត្តនេះ។

នគរបាលខេត្តបានចាប់ខ្លួនអ្នកសារព័ត៌មានរូបនេះ កាលពីថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៤ បន្ទាប់ពីមន្ទីរបរិស្ថានខេត្តបានដាក់ពាក្យបណ្តឹងនៅតុលាការកាលពីថ្ងៃទី២០ ឧសភា ដោយចោទពីបទញុះញង់ និងបរិហារកេរ្តិ៍។

ពាក្យបណ្តឹងដែលដាក់ទៅតុលាការបានបង្ហាញថា មន្ទីរបរិស្ថានខេត្ត ដែលតំណាងដោយមេធាវី ស្រី សុផាន់ណារ៉ា បានចោទប្រកាន់អ្នកសារព័ត៌មានរូបនេះថា បានបំពានលើមាត្រាមួយចំនួននៃក្រមព្រហ្មទណ្ឌកម្ពុជា។

ការចោទប្រកាន់ទាំងនោះរួមមានបទញុះញង់ឱ្យមានការរើសអើងតាមមាត្រា ៤៩៦ បទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍តាមមាត្រា ៤៩៥ និងបទបរិហារកេរ្តិ៍តាមមាត្រា ៣០៥។ ពាក្យបណ្តឹងបានលើកឡើងថា ព័ត៌មានដែលអ្នកសារព័ត៌មានរូបនេះបានផ្សព្វផ្សាយតាមរយៈតេឡេក្រាម និង ហ្វេសប៊ុកគឺ «មិនពិត» និងមានលក្ខណៈ «ញុះញង់»។ អ្នកសារព័ត៌មានរូបនេះត្រូវបានបញ្ជូនទៅពន្ធនាគារខេត្តកំពង់ធំកាលពីថ្ងៃទី២៦ ខែឧសភា។

កាលពីថ្ងៃ៦ ខែវិច្ឆិកា ឆ្នាំ២០២៤ លោកត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគាររយៈពេលពីរឆ្នាំក្នុងសំណុំរឿងមួយទៀត ប៉ុន្តែត្រូវបានដោះលែងឲ្យនៅក្រៅឃុំ។ លោកបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់សាលាដំបូងខេត្ត។

## ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៤ ខេត្តរតនគិរី

អ្នកសារព័ត៌មាន HPN News ប្រចាំខេត្តរតនគិរី ត្រូវបានតុលាការខេត្តកោះហៅមកសាកសួរ បន្ទាប់ពីបានចុះផ្សាយអត្ថបទមួយដែលអះអាងថា អាជ្ញាធរមូលដ្ឋាន បានយកប្រាក់ពីអ្នកភូមិជាថ្នូរឲ្យអ្នកភូមិចូលប្រមូលផ្លែសំរងក្នុងដែនអភិរក្ស។

លោកបាននិយាយថា តុលាការបានស្នើឲ្យលោកបង្ហាញភស្តុតាងដែលបញ្ជាក់ថា សេចក្តីរាយការណ៍របស់លោកគឺជាការពិត។

កាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៤ HPN News បានចុះផ្សាយអត្ថបទមួយថា អាជ្ញាធរនៅឧទ្យានជាតិវីរៈជ័យ ក្នុងស្រុកអណ្តូងមាស ខេត្តរតនគិរី បានយកលុយពីអ្នកភូមិជាថ្នូរនឹងការអនុញ្ញាតឱ្យអ្នកភូមិចូលព្រៃ ដើម្បីបេះផ្លែសំរង។

នៅថ្ងៃទី២៥ ខែមេសា តុលាការខេត្ត បានចេញដីកាកោះហៅដោយបង្គាប់ឲ្យអ្នកសារព័ត៌មានរូបនេះចូលខ្លួនបំភ្លឺនៅតុលាការនៅថ្ងៃទី២៣ ខែឧសភា។ លោកបាននិយាយថា ដីកាកោះនេះមិនត្រូវបានផ្ញើមកលោកដោយផ្ទាល់ទេ ប៉ុន្តែផ្សព្វផ្សាយតាមបណ្តាញសង្គមតេឡេក្រាម។

## ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៤ ខេត្តពោធិ៍សាត់

អាជ្ញាធរមូលដ្ឋានខេត្តពោធិ៍សាត់បានប្តឹងស្ថាប័នព័ត៌មានអនឡាញចំនួន៤ ពីបទបរិហារកេរ្តិ៍ និងញុះញង់ឱ្យមានការរើសអើង បន្ទាប់ពីពួកគេធ្វើសេចក្តីរាយការណ៍អំពីការរានដីព្រៃក្នុងតំបន់ដែនជម្រកសត្វព្រៃភ្នំសំកុស។

អង្គភាពសារព័ត៌មានទាំង៤ រួមមាន Phally News, BSN, Ray Phon និង UKK News បានរាយការណ៍អំពីការឈូសឆាយដីព្រៃនៅក្នុងដែនជម្រកសត្វព្រៃភ្នំសំកុស ស្រុកវាលវែង ខេត្តពោធិ៍សាត់ តាំងពីខែកុម្ភៈ។ សេចក្តីរាយការណ៍ទាំងនេះត្រូវបានចេញផ្សាយជាអត្ថបទ និងវីដេអូ។

កាលពីថ្ងៃទី២២ ខែកុម្ភៈ មន្ទីរបរិស្ថានខេត្តពោធិ៍សាត់បានចេញសេចក្តីប្រកាសមួយច្រានចោលសេចក្តីរាយការណ៍ទាំងនោះថាជាព័ត៌មាន «មិនពិត» និងបានបញ្ជាឱ្យស្ថាប័នព័ត៌មានទាំង៤ ធ្វើការកែតម្រូវ។

យោងតាមសេចក្តីប្រកាសព័ត៌មានរបស់តុលាការ ដើមបណ្តឹងមាន ៣នាក់នោះមានឈ្មោះ កន ខាន់ដា ជាជំទប់ទីមួយឃុំក្រពើពីរ លោក យ៉ែម សំប៊ុល ជាស្មៀនឃុំ និង លោក សាត សុគា ដែលគេមិនដឹងច្បាស់អំពីតួនាទីរបស់គាត់។

មានតែអ្នកសារព័ត៌មានអនឡាញម្នាក់ មកពីអង្គភាពព័ត៌មាន Ray Phon ត្រូវបានសាលាដំបូងខេត្តពោធិ៍សាត់កោះហៅមកសាកសួរកាលពីថ្ងៃទី១១ ខែមិថុនា។

## ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៤ ខេត្តតាកែវ

អ្នកសារព័ត៌មានអនឡាញពីរនាក់មកពីអង្គភាពព័ត៌មាន LSN ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅតុលាការខេត្តតាកែវ ដើម្បីសាកសួរ ដោយពួកគេត្រូវបានចោទពីបទញុះញង់ និងរើសអើងជុំវិញការរាយការណ៍ព័ត៌មានផ្សាយផ្ទាល់តាមហ្វេសប៊ុកអំពីកង្វះទឹកស្រោចស្រប់ដំណាំស្រូវនៅស្រុកអង្គរបុរី ដែលអាជ្ញាធរអះអាងថាជា «ព័ត៌មានក្លែងក្លាយ»។

នគរបាលបានចាប់ខ្លួនអ្នកទាំងពីរកាលពីថ្ងៃទី១៣ ខែឧសភា ហើយឃុំខ្លួនរយៈពេលពីរយប់នៅស្នងការដ្ឋាននគរបាលខេត្ត ដើម្បីសាកសួរ។

ដោយឡែក រដ្ឋបាលស្រុកអង្គរបុរី និងស្នងការដ្ឋាននគរបាលខេត្តតាកែវ បានចេញសេចក្តីប្រកាសព័ត៌មាននៅថ្ងៃទី១៤ និងទី១៥ ខែឧសភា ដោយអះអាងថា សេចក្តីរាយការណ៍ព័ត៌មានផ្សាយផ្ទាល់តាមហ្វេសប៊ុកនេះ គឺមិនពិតទេ ។ សេចក្តីប្រកាសព័ត៌មានទាំងពីរលើកឡើងថារឿងនេះត្រូវបានបង្កើតឡើងដោយអ្នកសារព័ត៌មាន ដើម្បីធ្វើឱ្យសាធារណជនមានការភាន់ច្រឡំ និងប៉ះពាល់ដល់មុខមាត់អាជ្ញាធរ។

អាជ្ញាធរបានចោទប្រកាន់អ្នកសារព័ត៌មានទាំងពីរនាក់ពីបទញុះញង់ និងរើសអើង ដែលបង្កភាពវឹកវរដល់សន្តិសុខសង្គម។

បើតាមសេចក្តីប្រកាសព័ត៌មាននេះ អ្នកសារព័ត៌មានទាំងពីរមានសំណុំរឿងមួយទៀតនៅសាលាដំបូងខេត្ត ដែលរដ្ឋបាលខេត្តតាកែវបានប្តឹងពួកគេពីការផ្សព្វផ្សាយព័ត៌មានមិនពិត។

អ្នកសារព័ត៌មានទាំងពីរត្រូវបានបញ្ជូនទៅសាលាដំបូងខេត្តនៅថ្ងៃទី១៥ ខែឧសភា ហើយត្រូវបានដោះលែងនៅល្ងាចថ្ងៃដដែល។

## ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៤ ខេត្តបាត់ដំបង

សាលាដំបូងខេត្តបាត់ដំបងបានតម្កល់សេចក្តីសម្រេចលើកទី១ របស់ខ្លួនក្នុងការផ្តន្ទាទោសចាងហ្វាងការផ្សាយទូរទស្សន៍អនឡាញមួយរូបពីបទបរិហារកេរ្តិ៍តាមមាត្រា៣០៥ នៃក្រមព្រហ្មទណ្ឌ កាលពីថ្ងៃទី៩ ខែឧសភា។

ចាងហ្វាងការផ្សាយទូរទស្សន៍អនឡាញ TNM ត្រូវបានលោក មិុល សុផល អភិបាលស្រុកឯកភ្នំ ខេត្តបាត់ដំបង ប្តឹងពីបទបរិហារកេរ្តិ៍ បន្ទាប់ពីលោករាយការណ៍ព័ត៌មានអំពីករណីជម្លោះដីធ្លីមួយកាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២២។ លោកត្រូវបានតុលាការកាត់ទោសកំបាំងមុខកាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៣ និងបង្គាប់ឱ្យបង់ប្រាក់ពិន័យចំនួន ៤លានរៀល ($១,០០០) ប៉ុន្តែតុលាការទើបតែប្រកាសសាលក្រមនៅថ្ងៃទី១១ ខែមករា ឆ្នាំ២០២៤ ប៉ុណ្ណោះ។

ចាងហ្វាងរូបនេះ បានប្រានចោលសេចក្តីសម្រេចនេះ ហើយបានស្វះស្វែងរកការជំនុំជម្រះឡើងវិញ ដោយតុលាការដដែលនេះ បានបើកសវនាការជំនុំជម្រះម្តងទៀតនៅថ្ងៃទី២៥ ខែមេសា។ ទោះជាយ៉ាងណាក៏ដោយ សេចក្តីសម្រេចនេះត្រូវបានតម្កល់កាលពីថ្ងៃទី៩ ខែឧសភា។

ក្នុងបទសម្ភាសន៍ជាមួយខេមបូចា ចាងហ្វាងរូបនេះ បានសម្តែងការខកចិត្ត ដែលតុលាការមិនបានប្រើប្រាស់ច្បាប់ស្តីពីរបបសារព័ត៌មានចំពោះអ្នកសារព័ត៌មាន ដែលមានតួនាទីលើកយកបញ្ហាប៉ះពាល់ដល់ប្រជាពលរដ្ឋមកបង្ហាញ។

លោកបាននិយាយថា៖«ខ្ញុំសូមស្នើឲ្យរដ្ឋាភិបាលពិនិត្យមើលប្រព័ន្ធច្បាប់ ដើម្បីកុំឲ្យពួកគាត់ [តុលាការ] ចេះប្រើតែឆន្ទានុសិទ្ធិរបស់ខ្លួន ដើម្បីរាំងអ្នកសារព័ត៌មានមិនឲ្យរាយការណ៍ការពិត»។

## ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៤ ខេត្តក្រចេះ

អ្នកសារព័ត៌មានសេរីម្នាក់នៃវិទ្យុសំឡេងសហគមន៍ស្ត្រីខេត្តក្រចេះ ត្រូវបានតុលាការខេត្តកោះហៅមកសាកសួរ បន្ទាប់ពីលោកបានរាយការណ៍ព័ត៌មានអំពីការតវ៉ារបស់ជនជាតិដើមភាគតិចប្រឆាំងនឹងមន្ត្រីបរិស្ថាន។

អ្នកសារព័ត៌មានរូបនេះត្រូវបានចោទប្រកាន់ពីបទញុះញង់ឱ្យប្រជាពលរដ្ឋផុតបំផ្លាញស្នាក់ការបរិស្ថានក្នុងការតវ៉ាកាលពីថ្ងៃទី៩ ខែសីហា ឆ្នាំ២០២៣ នៅឃុំស្រែជិះ ស្រុកអូរគ្រៀងសែនជ័យ។

លោកត្រូវបានក្រសួងបរិស្ថានហៅមកសាកសួរលើកដំបូងនៅរាជធានីភ្នំពេញនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៣ ជាមួយអ្នកភូមិ ៨នាក់ផ្សេងទៀត។ ក្នុងជំនួបជាមួយក្រសួង មន្ត្រីក្រសួងបានយល់ព្រមដកឈ្មោះលោកចេញពីបញ្ជីជនសង្ស័យ។ ប៉ុន្តែនៅថ្ងៃទី២ ខែមីនា ឆ្នាំ២០២៤ លោកត្រូវបានកោះហៅឱ្យចូលខ្លួនទៅកាន់តុលាការខេត្តក្រចេះ ដើម្បីសាកសួរនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ ២០២៤ ។

លោកបាននិយាយថា ចៅក្រមស៊ើបអង្កេតសាលាដំបូងខេត្តបានស្នើឱ្យលោកដាក់ឯកសារ ដើម្បីបញ្ជាក់ថាលោកជាអ្នកសារព័ត៌មាន។

## ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៤ ខេត្តតាកែវ

កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៤ និពន្ធនាយកនៃសារព័ត៌មានពេញចិត្ត មេឌា ត្រូវបានក្រុមហ៊ុនឯកជនមួយនៅខេត្តតាកែវប្ដឹងពីបទធ្វើឲ្យប៉ះពាល់ដល់ក្រុមហ៊ុនបន្ទាប់ពីបានរាយការណ៍ព័ត៌មានដោយសង្ស័យថា ក្រុមហ៊ុនប្រតិបត្តិការដោយពុំមានច្បាប់ត្រឹមត្រូវ។

និពន្ធនាយករូបនេះបានប្រាប់ខេមបូចាថា បណ្ដឹងនេះធ្វើឡើងនៅថ្ងៃនៃការចេញសេចក្ដីរាយការណ៍ព័ត៌មាន។ លោកបាននិយាយថា មុនពេលមានបណ្ដឹងនេះ លោកត្រូវបានអ្នកសារព័ត៌ មានអនឡាញផ្សេងទៀតស្នើឱ្យលុបអត្ថបទជាថ្នូរនឹងប្រាក់ ប៉ុន្តែលោកបានបដិសេធ។

និពន្ធនាយករូបនេះបាននិយាយថា នៅទីបំផុតលោកបានលុបអត្ថបទតាមសំណើរបស់មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត។ លោកបន្តថា ជម្លោះផ្លូវច្បាប់បានបញ្ចប់បន្ទាប់ពីលោកលុបអត្ថបទ។

## ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៤ ខេត្តមណ្ឌលគិរី

មន្ត្រីខេត្តមណ្ឌលគិរីបានកោះហៅអ្នកសារព័ត៌មានពីរនាក់មកសាកសួរពាក់ព័ន្ធនឹងការរាយការណ៍ព័ត៌មានទាក់ទងនឹងបទល្មើសព្រៃឈើនៅស្រុកកែវសីមា។

លិខិតកោះហៅរបស់រដ្ឋបាលស្រុកកែវសីមា បានស្នើឱ្យអ្នកសារព័ត៌មានទាំងពីរនាក់ ដែលរស់នៅខេត្តព្រៃវែង មកបង្ហាញខ្លួននៅការិយាល័យរដ្ឋបាលស្រុកនៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៤។

អ្នកសារព័ត៌មាន BPNC News និង សារព័ត៌មានដើមក្រសាំង បានប្រាប់ខេមបូចាថា ពួកគេបានធ្វើដំណើរទៅខេត្តមណ្ឌលគិរី កាលពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៤ ដើម្បីទៅឆ្លើយបំភ្លឺតាមការកោះហៅ ប៉ុន្តែពេលទៅដល់ទីនោះ គេត្រូវបានប្រាប់ថា ការសាកសួរត្រូវបានពន្យាពេលដោយគ្មានបញ្ជាក់ហេតុផល។

## ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៤ ខេត្តស្ទឹងត្រែង

អ្នកសារព័ត៌មានអនឡាញម្នាក់នៅអង្គភាពសារព័ត៌មាន ជីវិត និងកីឡា បានរងនូវការគំរាមចាត់វិធានការតាមផ្លូវច្បាប់ បន្ទាប់ពីបានចុះផ្សាយអំពីអំពើពុករលួយពាក់ព័ន្ធនឹងប្រធានមន្ទីរសុខាភិបាលខេត្តស្ទឹងត្រែង។

កាលពីថ្ងៃទី១៦ ខែកុម្ភៈ សារព័ត៌មានជីវិត និងកីឡា បានចុះផ្សាយអត្ថបទព័ត៌មានមួយស្តីពីភាពមិនប្រក្រតីពាក់ព័ន្ធនឹងការទិញបរិក្ខាពេទ្យដែលមានតម្លៃខ្ពស់។ ព័ត៌មាននេះបានបង្ហាញពីឯកសារវិក្កយបត្រពីអ្នកផ្គត់ផ្គង់ និងរួមបញ្ចូលបទសម្ភាសន៍ជាមួយមន្ត្រីមន្ទីរម្នាក់ ដែលសុំមិនបញ្ចេញឈ្មោះ។

កាលពីថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៤ មន្ទីរសុខាភិបាលខេត្តបានចេញលិខិតបដិសេធអត្ថបទព័ត៌មាននេះ ដោយនិយាយថា ព័ត៌មានមិនមានការបញ្ជាក់ត្រឹមត្រូវ ហើយអ្នកសារព័ត៌មានផ្សាយព័ត៌មានមិនពិត និងខ្វះវិជ្ជាជីវៈ។ នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៤ ក្រសួងព័ត៌មានបានដកអាជ្ញាបណ្ណស្ថាប័នរបស់សារព័ត៌មាននេះ។

## ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៤ ខេត្តព្រះសីហនុ

កាលពីថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ ២០២៤ អ្នកយកព័ត៌មានអនឡាញ៣នាក់របស់សារព័ត៌មាន សាន្ត ព្រហ្ម ត្រូវបាននគរបាលឃាត់ខ្លួនដើម្បីសាកសួររយៈពេលជាង១០ម៉ោង បន្ទាប់ពីពួកគេបានសម្ភាសគ្រួសារដែលមានជម្លោះដីធ្លីនៅខេត្តព្រះសីហនុ។

ក្នុងពេលឃាត់ខ្លួន នគរបាលបានថតរូបពួកគេពាក់កណ្តាលខ្លួន ហើយបង្ខំពួកគេឱ្យផ្តិតមេដៃលើឯកសារដែលយល់ព្រមមិនចេញផ្សាយព័ត៌មានទាំងនេះ បើមិនដូច្នេះទេនឹងត្រូវប្រឈមនឹងវិធានការផ្លូវច្បាប់។

នៅថ្ងៃបន្ទាប់ រូបថតពាក់កណ្តាលខ្លួនរបស់ពួកគេត្រូវបានផ្សព្វផ្សាយតាមបណ្តាញតេលេក្រាម និងហ្វេសប៊ុក។

ពួកគេបាននិយាយថា ការផ្សព្វផ្សាយជាសាធារណៈនូវរូបថតពួកគេដោយនគរបាលស្រុក គឺបានរំលោភសិទ្ធិ និងធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់ពួកគេ ព្រោះពួកគេមិនបានប្រព្រឹត្តបទល្មើសអ្វីទេ។

## ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៤ ភ្នំពេញ

ចាងហ្វាងទូរទស្សន៍ TN TV ត្រូវបានប្តឹងដោយមន្ត្រីយោធាផ្កាយបី ពីបទបរិហារកេរ្តិ៍ និងញុះញង់ បន្ទាប់ពីបានចុះផ្សាយព័ត៌មានពីបញ្ហាមួយពាក់ព័ន្ធនឹងមន្ត្រីយោធារូបនេះបានខ្ចីប្រាក់១លានដុល្លារពីស្ត្រីម្នាក់។

កាលពីថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ ២០២៤ TN TV បានចុះផ្សាយអត្ថបទមួយអំពីជម្លោះរវាងលោកឧត្តមសេនីយ៍ផ្កាយបីដែលរស់នៅខេត្តកំពង់ស្ពឺ និងអ្នកឱ្យខ្ចីប្រាក់ម្នាក់។

ផ្អែកតាមព័ត៌មាន មន្ត្រីយោធារូបនេះត្រូវបានគេចោទថា បានខ្ចីប្រាក់ចំនួន ១លានដុល្លារពីស្ត្រីម្នាក់ កាលពីខែតុលា ឆ្នាំ២០២១ ហើយមិនព្រមសង។ នៅក្នុងការផ្សព្វផ្សាយព័ត៌មាននោះ មានទាំងដាក់រូបភាពនៃមន្ត្រីយោធា ឯកសារច្បាប់ចម្លងនៃកិច្ចសន្យាខ្ចី និងឯកសារផ្សេងទៀត។

បន្ទាប់ពីការចុះផ្សាយ មេធាវីមន្ត្រីយោធា បានផ្ញើលិខិតមួយច្បាប់ទៅ TN TV នៅថ្ងៃទី៨ ខែកុម្ភៈ ដោយស្នើសុំលុបអត្ថបទនេះចេញ។ មេធាវីរូបនេះបានចោទអ្នកសារព័ត៌មានថាបានបំផ្លើសព័ត៌មាន ក្នុងចេតនាបង្ខូចកេរ្តិ៍ឈ្មោះ និងញុះញង់ ហើយមិនបានស្វែងរកការបំភ្លឺពីកូនក្តីរបស់លោក។

ចាងហ្វាងបានប្រាប់ខេមបូចាថា លោកមិនអាចទាក់ទងលោកឧត្តមសេនីយ៍បានទេមុនចេញផ្សាយ ហើយបាននិយាយថា លោកបានបដិសេធលុបអត្ថបទនេះ ព្រោះវាផ្អែកលើព័ត៌មាន និងភស្តុតាងច្បាស់លាស់។

ចាងហ្វាងរូបនេះបានទទួលដីកាកោះហៅពីសាលាដំបូងរាជធានីភ្នំពេញនៅថ្ងៃទី១៦ ខែកុម្ភៈ ដោយជូនដំណឹងដល់លោកអំពីបណ្តឹងរបស់មន្ត្រីយោធា ដែលបានប្តឹងលោកពីបទបរិហារកេរ្តិ៍ និងញុះញង់។

លោកឧត្តមសេនីយ៍ក៏បានដាក់ពាក្យបណ្តឹងទៅក្រសួងព័ត៌មានដែរ ដោយស្នើឱ្យលុបអាជ្ញាបណ្ណប្រព័ន្ធផ្សព្វផ្សាយនេះ។

## ថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤ ខេត្តក្រចេះ

ចាងហ្វាង Network News ត្រូវបានបុរសម្នាក់ ដែលតំណាងឱ្យក្រុមហ៊ុនកៅស៊ូប្តឹងពីបទបរិហារកេរ្តិ៍ បន្ទាប់ពីរាយការណ៍ព័ត៌មានអំពីជម្លោះដីធ្លីនៅស្រុកស្នួល ខេត្តក្រចេះ។

យោងតាមពាក្យបណ្តឹងរបស់ ព្រំ ចន្ថា ទៅតុលាការខេត្ត កាលពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤ អ្នកសារព័ត៌មានរូបនេះ ត្រូវបានចោទប្រកាន់ពីបទផ្សាយព័ត៌មានមិនពិត និងទាមទារសំណងជំងឺចិត្តចំនួន ១០.០០០ ដុល្លារអាមេរិក។

Network News បានចេញផ្សាយព័ត៌មានពីរអំពីការតវ៉ាប្រឆាំងនឹងការឈូសឆាយដីនៅថ្ងៃទី ១២ និង ១៨ ខែមករា ឆ្នាំ ២០២៤ ដែលផ្សាយផ្ទាល់តាមហ្វេសប៊ុក ។

នៅក្នុងលិខិតកិច្ចព្រមព្រៀងចុះថ្ងៃទី២៣ ខែមករា ដែលខេមបូចាទទួលបាន ក្រុមហ៊ុន Eastern Rubber (Cambodia) Co Ltd) បានយល់ព្រមសងសំណងដល់គ្រួសារទាំងពីរសម្រាប់ការខូចខាតដំណាំ។

អ្នកសម្របសម្រួលសមាគមអាដហុកប្រចាំខេត្តក្រចេះប្រាប់ខេមបូចាថា ព្រំ ចន្ថា ជាតំណាងក្រុមហ៊ុន ហ៊ុន Eastern Rubber។ លោកបានបន្តថា ឈ្មោះចន្ថា បានបង្ខំអ្នកភូមិឱ្យលក់ដីទៅឱ្យក្រុមហ៊ុន ប៉ុន្តែអ្នកភូមិមិនព្រមទើបធ្វើឱ្យមានការតវ៉ា។ លោកថា អ្នកភូមិបីនាក់ផ្សេងទៀតក៏ត្រូវឈ្មោះ ព្រំ ចន្ថា ប្តឹងដែរ៕

# ការយាយីផ្នែករូបរាងកាយ

## ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៤ ខេត្តសៀមរាប

លោក ឈឿង ឈឹង អ្នកសារព័ត៌មាននៅខេត្តសៀមរាបមកពីសារព័ត៌មានអនឡាញ កម្ពុជាអភិវឌ្ឍន៍ ត្រូវបានខ្មាន់កាំភ្លើងបាញ់ និងបានស្លាប់ក្រោយពីការបាញ់ប្រហារបានបីថ្ងៃ។

លោក ឈឹង អាយុ៦៣ឆ្នាំ ត្រូវជនដៃដល់បាញ់ត្រូវចំពោះកាលពីថ្ងៃទី៤ ខែធ្នូ ខណៈលោកកំពុងធ្វើដំណើរស្ថិតក្នុងស្រុកជីក្រែង ដើម្បីធ្វើសេចក្តីរាយការណ៍នៅតំបន់អភិរក្សព្រៃឈើ។ បើតាមអ្នកសារព័ត៌មានម្នាក់ ដែលបានឃើញហេតុការណ៍នេះ បានឱ្យដឹងថា លោកឈឹង ស្ថិតនៅចម្ងាយប្រហែល ៤០ម៉ែត្រពីខាងមុខលោក ពេលដែលលោកឈឹង ត្រូវគេបាញ់ ដែលបណ្តាល ឱ្យរងរបួសធ្ងន់ និងបានស្លាប់នៅយប់ថ្ងៃទី៧ ខែធ្នូ។

អាជ្ញាធរបានចាប់ខ្លួនជនសង្ស័យម្នាក់ក្នុងករណីនេះ ដែលបានសារភាពថា បានបាញ់សម្លាប់លោក ឈឹងដោយសារ " ជម្លោះផ្ទាល់ខ្លួន"។ ទោះបីជាយ៉ាងណា នៅក្នុងសេចក្តីរាយការណ៍មួយចំនួនកន្លងមករបស់លោកឈឹងបានចោទប្រកាន់ជនសង្ស័យឈ្មោះ ស៊ី លឿយ អាយុ៤០ឆ្នាំ ថាតែងតែធ្វើសកម្មភាពកាប់ឈើខុសច្បាប់។

អ្នកសារព័ត៌មានគ្មានព្រំដែន (RSF) បានចេញសេចក្ដីថ្លែងការណ៍នៅថ្ងៃទី៨ ខែធ្នូ ទាមទារអាជ្ញាធរត្រូវធានាថាគ្រប់ភាគីពាក់ព័ន្ធនៃការស្លាប់អ្នកសារព័ត៌មានរូបនេះត្រូវទទួលបានការកាត់ទោសបានធ្ងន់ធ្ងរ និងសំណូមពរទៅកាន់រាជរដ្ឋាភិបាលកម្ពុជាមានវិធានការយ៉ាងម៉ឺងម៉ាត់ដើម្បីធានានូវការបញ្ចប់ហិង្សាលើអ្នកសារព័ត៌មាន។ ហើយធានាថាជនល្មើសនឹងទទួលទោសឱ្យបានសាកសម។

## ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៤ ខេត្តសៀមរាប

អ្នកសារព័ត៌មានម្នាក់មកពីស្ថាប័នព័ត៌មាន មហាខ្មែរ បាននិយាយថា មន្ត្រីកងរាជអាវុធខេត្តម្នាក់បានវាយលោក ខណៈអ្នកសារព័ត៌មានម្នាក់ទៀតមកពីគេហទំព័រសៀមរាបប៉ុស្តិ៍ត្រូវបានគេកញ្ឆក់យកទូរស័ព្ទបោកចោល ពេលពួកគាត់កំពុងថតរាយការណ៍ផ្ទាល់នៅសារមន្ទីជាតិក្នុងខេត្តសៀមរាប។

អ្នកសារព័ត៌មានម្នាក់ក្នុងចំណោមនោះ បាននិយាយថា ឧបទ្ទវហេតុនេះបានកើតឡើងនៅម៉ោងប្រហែល ១១យប់ នៅក្នុងសង្កាត់ស្វាយដង្គុំ ខណៈពេលលោកកំពុងរាយការណ៍ផ្ទាល់អំពីព័ត៌មានសន្តិសុខនៅសារមន្ទីរ ដែលសមត្ថកិច្ចកំពុងសាកសួរមនុស្សម្នាក់ ដែលសង្ស័យប៉ុនប៉ងចូលក្នុងសារមន្ទីរនៅពេលយប់។

អ្នកសារព័ត៌មានមកពី ស្ថាប័នសារព័ត៌មានសៀមរាបប៉ុស្តិ៍ បាននិយាយថា ខណៈលោកកំពុងថត បុរស ដែលកំពុងត្រូវបានគេសួរនាំនោះ មានមន្ត្រីកងរាជអាវុធហត្ថម្នាក់បានប្រាប់ឱ្យលោកឈប់ថត។

អ្នកសារព័ត៌មានរូបនេះបាននិយាយថា មន្ត្រីរូបនោះបានដើរមកជិតលោក សួររកបណ្ណសារព័ត៌មានរបស់លោក ហើយស្រែកដាក់លោក និងបានព្យាយាមចាប់យកទូរសព្ទដៃរបស់លោក។ លោកនិយាយថា នៅពេលនោះ អ្នកសារព័ត៌មានមកពីសារព័ត៌មានមហាខ្មែរ បានព្យាយាមជួយលោក ប៉ុន្តែបែរជាត្រូវមន្ត្រីរូបនោះដាល់ ហើយបន្ទាប់មក មន្ត្រីរូបនេះឆក់យកទូរសព្ទ របស់លោកទៅបោកចោល ដែលបណ្ដាលឱ្យរងការខូចខាត។

នៅថ្ងៃបន្ទាប់ អ្នកសារព័ត៌មាន និងមន្ត្រីកងរាជអាវុធហត្ថ ត្រូវបានស្នើឱ្យដោះស្រាយ ដើម្បីបញ្ចប់ជម្លោះ ដោយមានការសម្រុះសម្រួលពីកងរាជអាវុធហត្ថខេត្ត។

អ្នកសារព័ត៌មានជាម្ចាស់ទូរសព្ទ ដែលរងការខូចខាតនោះ បានទទួលសំណងនៃការខូចខាត ខណៈមន្ត្រីកងរាជអាវុធហត្ថ បានសុំទោសអ្នកសារព័ត៌មានម្នាក់ទៀតចំពោះទង្វើរបស់ខ្លួន។

## ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៤ ខេត្តបន្ទាយមានជ័យ

អ្នកសារព័ត៌មានអង្គភាព SNTV Breaking News ប្រចាំខេត្តបន្ទាយមានជ័យម្នាក់រងហិង្សាលើរាងកាយ ខណៈកំពុងថតវីដេអូពីគ្រោះថ្នាក់ចរាចរណ៍។

នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៤ អ្នកសារព័ត៌មានត្រូវបានរុញផ្ដួលទៅនឹងដី ហើយទូរសព្ទរបស់គាត់បានឆក់យកដោយបុរសម្នាក់ដែលត្រូវបានគេចោទប្រកាន់ថាបានបង្កគ្រោះថ្នាក់ ខណៈអ្នកសារព័ត៌មានកំពុងរៀបចំថតវីដេអូអំពីគ្រោះថ្នាក់ចរាចរណ៍។

បុរសនោះត្រូវបានគេដឹងថាជាមន្ត្រីកងរាជអាវុធហត្ថចូលនិវត្តន៍បានបើករថយន្តបុកអ្នកជិះម៉ូតូនៅលើផ្លូវជាតិលេខ ៥៦ ក្នុងសង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។

វីដេអូមួយដែលត្រូវបានបង្ហោះដោយអង្គភាពសារព័ត៌មាន CPN TV Online បានបង្ហាញឱ្យឃើញថា អ្នកសារព័ត៌មានបានស្រែកឱ្យគេជួយជាច្រើនដង ខណៈគាត់កំពុងដួលនៅលើដី។ ក្នុងវីដេអូ ម្ចាស់រថយន្តបាននិយាយថា «គាត់មិនបានវាយតប់ជាមួយអ្នកសារព័ត៌មានទេ»។
អ្នកសារព័ត៌មានបាននិយាយថា ករណីនេះត្រូវបានដោះស្រាយបន្ទាប់ពីចាងហ្វាង អង្គភាពរបស់គាត់បាន ណែនាំគាត់កុំឱ្យផ្សាយព័ត៌មាននេះ។

អ្នកសារព័ត៌មាន បាននិយាយថាទូរសព្ទរបស់គាត់ត្រូវបាន ប្រគល់ជូនគាត់វិញ បន្ទាប់ពីមន្ត្រីកងរាជអាវុធហត្ថបានអន្តរាគមន៍ដោះស្រាយជម្លោះរវាងអ្នកសារព័ត៌មាន និងម្ចាស់រថយន្ត។

## ថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៤ ខេត្តរតនគិរី

កាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៤ អ្នកសារព័ត៌មានទូរទស្សន៍ម្នាក់ប្រចាំ ខេត្តរតនគិរី ត្រូវបានឃាត់ ខ្លួនក្នុងចំការឯកជនមួយក្នុងខេត្តរតនគិរីរយៈពេល៤ម៉ោង ក្រោយពេលដែលគាត់ចូលទៅយកព័ត៌មានពីបញ្ហាដីកវ៉ៃ។ ទីតាំងដីនេះត្រូវបានគេរាយការណ៍ថាជាកម្មសិទ្ធិរបស់ «បុគ្គលមានអំណាច» ក្នុងរាជធានីភ្នំពេញ។

ក្រោយមកអ្នកសារព័ត៌មានត្រូវបានដោះលែងវិញនៅម៉ោងប្រមាណ៧ យប់ពេលគាត់ចេញមុខសុំទោស និងយល់ព្រមចុះកិច្ចសន្យាមិនបញ្ចេញព័ត៌មាន។ អ្នកសារព័ត៌មានបាននិយាយថាម្ចាស់ដីបានព្រមានថានឹងចាត់វិធានការផ្លូវច្បាប់មកលើរូបគាត់ ហើយចោទគាត់ថាចូលទៅក្នុងទីតាំងឯកជនដោយគ្មានការអនុញ្ញាតក្នុងបំណង ជំរិតទារប្រាក់។

## ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៤ ខេត្តបន្ទាយមានជ័យ

អ្នកសារព័ត៌មានអនឡាញម្នាក់នៅក្រុងប៉ោយប៉ែតបាននិយាយថា លោកត្រូវបានកម្លាំងកងរាជអាវុធហត្ថក្រុងឃាត់ខ្លួន និងបញ្ជូនទៅសាកសួរ ខណៈពេលកំពុងចុះយកព័ត៌មានស្តីពីការបង្ក្រាប «សកម្មភាពអនាធិបតេយ្យ» មួយនៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២៧ ខែមិថុនា។

ទោះបីយ៉ាងនេះក្តី មន្ត្រីកងរាជអាវុធហត្ថបានអះអាងកាលពីថ្ងៃទី២៨ មិថុនា ថានេះមិនមែនជា «ករណីចាប់ខ្លួន» ទេ ប៉ុន្តែអាជ្ញាធរគ្រាន់តែ «ចង់ធ្វើឱ្យប្រាកដថា អ្នកសារព័ត៌មានរូបនោះមិនរាំងការងាររបស់អាជ្ញាធរ» ដោយសារគាត់ «មិនបានពាក់កាតសារព័ត៌មាន» ដើម្បីបញ្ជាក់ថា គាត់ជាអ្នកសារព័ត៌មាន។

អ្នកសារព័ត៌មានរូបនេះនិយាយថា លោកត្រូវបានដោះលែងវិញប្រហែលជាបីម៉ោងក្រោយមក បន្ទាប់ពីបានធ្វើកិច្ចសន្យាថានឹងមិនរាយការករណីឃាត់ខ្លួនគាត់។

## ថ្ងៃទី២ ខែមីនា ឆ្នាំ២០២៤ ខេត្តបន្ទាយមានជ័យ

អ្នកសារព័ត៌មាន៣នាក់មកពី Sameang Hot News ត្រូវបានមនុស្សមួយក្រុមព្រួតគ្នាវាយដំ ខណៈកំពុងរៀបចំការផ្សាយផ្ទាល់តាមហ្វេសប៊ុកអំពីសកម្មភាពអាជីវកម្មល្បែងបាញ់ត្រីក្នុងក្រុងប៉ោយប៉ែត ដែលអះអាងថាខុសច្បាប់។

អ្នកសារព័ត៌មានម្នាក់ បាននិយាយថា កាលពីថ្ងៃទី២ ខែមីនា មានអ្នកសារព័ត៌មានចំនួន៨នាក់ មកពី៣អង្គភាព ផ្សេងគ្នា បានទៅដល់ទីតាំងនោះ នៅម៉ោងប្រហែល៨យប់ បន្ទាប់ពីថត រូបបានខ្លះ និងរៀបចំផ្សាយផ្ទាល់ ស្រាប់តែមានមនុស្សមួយក្រុមបានដើរតម្រង់មករកអ្នកសារព័ត៌មាន ហើយចាប់ផ្ដើមវាយដំទៅលើពួកគេ ដោយប្រើដំបង និងដុំថ្ម។

សម្ភារៈរបស់អ្នកសារព័ត៌មាន រួមមានទូរសព្ទពីរគ្រឿង ជើងកាមេរ៉ាថតពីរ វិទ្យុទាក់ទងពីរគ្រឿង និងរថយន្តពីរគ្រឿង រងការខូចខាត។ វីដេអូឃ្លីបនៃឧបទ្ទវហេតុនេះ បានបង្ហាញឱ្យឃើញអ្នកសារព័ត៌មានត្រូវបានមនុស្សមួយក្រុមវាយដំធ្វើបាប។ ពួកគេបានប្រាប់ខេមបូចាថា អ្នកសារព័ត៌មានម្នាក់ត្រូវរបួសបាក់ដៃ និងម្នាក់ទៀតបែកមាត់ ។

អ្នកសារព័ត៌មានបានដាក់ពាក្យបណ្ដឹងភ្លាមៗទៅនគរបាលប៉ុស្ដិ៍នគរបាលផ្សារកណ្ដាល ប៉ុន្តែមិនមានចំណាត់ការអ្វីឡើយ។
ចាងហ្វាងម្នាក់ បានប្រាប់ខេមបូចាថា អ្នកសារព័ត៌មានបានដាក់ពាក្យបណ្ដឹងទៅនគរបាលក្រុងប៉ោយប៉ែត បន្ទាប់ពីនគរបាលសង្កាត់មិនចាត់វិធានការទេ។

# ការយាយីផ្សេងៗទៀត

## ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៤ ភ្នំពេញ

អ្នកសារព័ត៌មាន(Freelancer) អះអាងថា ត្រូវបានបុគ្គលមិនស្គាល់អត្តសញ្ញាណបានទូរសព្ទ និងផ្ញើរសារតាមតេឡេក្រាម សាកសួរអំពីភាពជាប់ពាក់ព័ន្ធរបស់អ្នកសារព័ត៌មានរូបនេះជុំវិញការផលិតព័ត៌មានស៊ើបអង្កេតរបស់ស្ថាប័នសារព័ត៌មានបរទេសមួយអំពីបញ្ហាបរិស្ថាននៅក្នុងប្រទេសកម្ពុជា។

លេខទូរសព្ទដែលបានតេមកគាត់ បានបង្ហាញឈ្មោះនៅលើតេឡេក្រាម «មករា ឬ ឈ្មោះក្រៅ Ty Hun»។

នៅថ្ងៃ១១ ខែធ្នូ ឆ្នាំ២០២៤ វេលាម៉ោង ៨និង១៨នាទី បុរសម្នាក់នោះបានទូរសព្ទមកសាកសួរអ្នកសារព័ត៌មានរូបនេះថា តើគាត់គឺជាអ្នកនាំក្រុមអ្នកសារព័ត៌មានបរទេសនោះមកធ្វើសេចក្ដីរាយការណ៍នោះឬយ៉ាងណា។ អ្នកសារព័ត៌មានរូបនេះ ក៏ត្រូវបានសួរនាំអំពីទីតាំងទំនប់វារីអគ្គិសនី ដែលបានបង្ហាញនៅក្នុងរបាយការណ៍នោះថាតើជារូបភាព យកពីប្រទេសផ្សេងឬយ៉ាងណា។

## ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៤ ភ្នំពេញ

អ្នកសារព័ត៌មានវីដេអូម្នាក់ និងស្ត្រីពលរដ្ឋអ្នកសារព័ត៌មានម្នាក់ ត្រូវបានហាមឃាត់មិនឱ្យសម្ភាស និងថតវីដេអូពលរដ្ឋ ១០០នាក់ ដែលប្រមូលផ្ដុំគ្នានៅមុខសាលារាជធានីភ្នំពេញ ដើម្បីទាមទារឱ្យលោកអភិបាលក្រុង ឃួង ស្រេង ពន្លឿនការចេញប័ណ្ណកម្មសិទ្ធិដីធ្លី។

អ្នកសារព័ត៌មានរូបនេះនិយាយថា មន្ត្រីខណ្ឌម្នាក់បានរារាំងប្រជាពលរដ្ឋមិនឱ្យនិយាយជាមួយអ្នកសារព័ត៌មានខណៈដែលលោកកំពុងថតបទសម្ភាសន៍។

មន្ត្រីរូបនោះអះអាងថា អ្នកសារព័ត៌មានធ្វើការក្នុងគោលបំណងបម្រើនយោបាយឱ្យក្រុមប្រឆាំង។ នៅក្នុងរូបភាពវីដេអូ ដែលចែករំលែកជាមួយខេមបូចា គេឃើញមន្ត្រីរូបនេះស្រែក និងចង្អុលទៅអ្នកថតវីដេអូឱ្យបិទកាមេរ៉ារបស់គាត់។ អ្នកសារព័ត៌មានរូបនេះបាននិយាយថា មន្ត្រីរូបនេះ បានស្រែកដាក់គាត់ពីរដង ដែលធ្វើឱ្យពួកគាត់ភ័យខ្លាច ហើយបិទកាមេរ៉ា។

## ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២៤ ខេត្តព្រះវិហារ

អ្នកសារព័ត៌មានស្ត្រីម្នាក់ដែលជារឿយៗបានចូលរួមកិច្ចពិភាក្សាតាមអនឡាញស្តីពីសេរីភាពសារព័ត៌មាននៅក្នុងប្រទេសកម្ពុជា បានរាយការណ៍ថា នាងត្រូវបានគេតាមដាន និងឃ្លាំមើល។

បើតាមអ្នកសារព័ត៌មានស្រីរូបនេះ អ្នករស់នៅក្បែរផ្ទះឪពុកម្តាយរបស់នាងនៅក្នុងខេត្តព្រះវិហារ ដែលគេស្គាល់ឈ្មោះថា កុសល ហើយពីមុនជាសមាជិកក្រុមប្រឹក្សាស្រុក បានយករូបភាពស្រ្គីនសត់ (screenshoot) របស់នាងអំឡុងកម្មវិធីផ្សាយផ្ទាល់តាមអនឡាញមួយ មកបង្ហាញឪពុកម្តាយរបស់នាង។ បុគ្គលនោះបានប្រាប់ឪពុកម្តាយរបស់នាងថា កាលពីថ្ងៃទី២ ខែធ្នូ មានគេផ្ញើរូបភាពនេះមក និងសួររកអាសយដ្ឋានរបស់នាង ក្នុងខ្លឹមសារដើមដូច្នេះ៖ តើមានស្គាល់ស្ត្រីអ្នកសារព័ត៌មាននេះទេ? ហើយផ្ទះរបស់នាងនៅឯណា?»។

អ្នកសារព័ត៌មានរូបនេះ បាននិយាយថា នាងបានទទួលព័ត៌មាននេះពីឪពុកម្តាយរបស់នាងកាលពីថ្ងៃទី៣ ខែធ្នូ។

មុនថ្ងៃកើតហេតុកាលពីថ្ងៃទី២៨ ខែវិច្ឆិកា អ្នកសារព័ត៌មានរូបនេះ បានចូលរួមកម្មវិធីពិភាក្សាតាមអនឡាញ ដែលរៀបចំដោយអង្គការសិទ្ធិមនុស្សក្នុងស្រុកមួយ ដើម្បីពិភាក្សាអំពី «សេរីភាពនៃការបញ្ចេញមតិ និងសេរីភាពសារព័ត៌មាន»។

អ្នកសារព័ត៌មានស្រីរូបនេះជឿជាក់ថានាង និងគ្រួសារនាង កំពុងតែត្រូវបានគេតាមដាននាងពីក្រោយ ហើយនាងព្រួយបារម្ភពីសុវត្ថិភាពនាង និងគ្រួសារ។

## ថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៤ ភ្នំពេញ

កាលពីថ្ងៃទី២១ ខែសីហា អ្នកសារព័ត៌មានសេរីពីររូបត្រូវបានមន្ត្រីជាន់ខ្ពស់សាលារាជធានីភ្នំពេញ ព្រមានដោយសារបណ្ណសារព័ត៌មានរបស់ពួកគេផុតសុពលភាព។

អ្នកសារព័ត៌មាន បាននិយាយថាពួកគេបានទាក់ទងទៅមន្ត្រីរូបនោះ ដើម្បីធ្វើបទសម្ភាសន៍ទាក់ទងនឹង បញ្ហាបឹងតាមោក និងសមាជគណបក្សកម្លាំងជាតិ។ បន្ទាប់មកអ្នកសារព័ត៌មានត្រូវបានស្នើឱ្យបង្ហាញបណ្ណសារព័ត៌មានដើម្បីផ្ទៀងផ្ទាត់ថា ពួកគេគឺជា «អ្នកសារព័ត៌មានពិតប្រាកដ» មុនពេលផ្តល់បទសម្ភាសន៍។ «គាត់ថាបណ្ណសារព័ត៌មានរបស់ខ្ញុំមិនត្រឹមត្រូវទេ ហើយបានសុំឱ្យខ្ញុំ គោរពវិជ្ជាជីវៈ»។ «គាត់បាននិយាយថាប្រសិនបើខ្ញុំបន្តការងារ [ដោយគ្មានបណ្ណសារព័ត៌មានត្រឹមត្រូវ] គាត់នឹង រាយការណ៍ទៅអាជ្ញាធរ»។ នេះជាការអះអាងរបស់អ្នកសារព័ត៌មាន។

«គាត់បាននិយាយថាគាត់នឹងប្រាប់អាជ្ញាធរឱ្យស្វែងរក និងចាប់ខ្លួនខ្ញុំ។ គាត់បានព្រមានខ្ញុំឱ្យប្រយ័ត្ន ឬគាត់ នឹងប្ដឹងខ្ញុំ បើខ្ញុំនៅតែបន្តសួរគាត់ទៀត។ ខ្ញុំមិនមានអារម្មណ៍ថាមានសុវត្ថិភាពទេ»។

## ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៤ ភ្នំពេញ

ចាងហ្វាងសារព័ត៌មានអនឡាញម្នាក់បានបង្ហោះនៅក្នុងគណនីហ្វេសប៊ុករបស់ខ្លួនថា គាត់បានទទួលការគំរាមសម្លាប់ ដោយជនអនាមិក ហើយបានអំពាវនាវឱ្យលោកនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត ជួយ។ ខេមបូចាបានទាក់ទងទៅអ្នកសារព័ត៌មានដើម្បីបញ្ជាក់បន្ថែម ប៉ុន្តែអ្នកសារព័ត៌មានរូបនោះបដិសេធផ្តល់ព័ត៌មានលម្អិត ដោយគ្រាន់តែអះអាងថា បញ្ហាត្រូវបានដោះស្រាយរួចរាល់ ហើយសារដែលបានបង្ហោះនៅលើហ្វេសប៊ុកត្រូវបានលុបចោល។

## ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៤ ភ្នំពេញ

អ្នកសារព័ត៌មានមកពីអង្គភាពព័ត៌មានមួយចំនួន រួមទាំងវិទ្យុបារាំងអន្តរជាតិ ខេមបូចា និងវិទ្យុសំឡេងសហរដ្ឋអាមេរិក មិនត្រូវបានគេអនុញ្ញាតឱ្យចូលក្នុងបន្ទប់សវនាការកាត់ក្តីលោក កឹម សុខា អតីតប្រធានគណបក្សសង្គ្រោះជាតិទេ។

អ្នកសារព័ត៌មានដែលបានចុះឈ្មោះជាមុនសម្រាប់ចូលរួមសវនាការ ត្រូវបានប្រាប់ថាបន្ទប់សវនាការពេញ ហើយមានតែអ្នកដែលមានលិខិតអនុញ្ញាតពីតុលាការប៉ុណ្ណោះទើបអនុញ្ញាតឱ្យចូល។

សាលាឧទ្ធរណ៍រាជធានីភ្នំពេញបានបើកសវនាការលើកទី១ លើបណ្តឹងសាទុក្ខរបស់លោក កឹម សុខា ពីបទក្បត់ជាតិ និងសមគំនិតជាមួយបរទេសកាលពីថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៤។

អ្នកយកព័ត៌មានខេមបូចាបានចុះឈ្មោះ ដើម្បីចូលស្តាប់សវនាការទាំងបីលើក ប៉ុន្តែមន្ត្រីតុលាការបានប្រាប់អ្នកសារព័ត៌ មានមួយថ្ងៃបន្ទាប់ពីការចុះឈ្មោះថា ពួកគេនឹងមិនអាចចូលរួមបានទេ ដោយសារបន្ទប់ចង្អៀត។

នេះមិនត្រឹមតែប៉ះពាល់ដល់អ្នកសារព័ត៌មានខេមបូចាប៉ុណ្ណោះទេ ប៉ុន្តែក៏មានអ្នករាយការណ៍ព័ត៌មានមកពីស្ថាប័នផ្សេងទៀត ក៏មិនត្រូវបានអនុញ្ញាតឱ្យចូលបន្ទប់សវនាការដែរ។

អង្គការសិទ្ធិមនុស្សលីកាដូ ដែលឃ្លាំមើលនីតិវិធីនៃសវនាការរបស់តុលាការ បានចេញព័ត៌មានបន្ទាន់ ដោយកត់សម្គាល់ថា សាធារណជនត្រូវបានរឹតត្បិតមិនឱ្យចូលសវនាការ រួមទាំងអ្នកសារព័ត៌មានផងដែរ។

មុនពេលបើកសវនាការលើកដំបូង សន្តិសុខត្រូវបានរឹតបន្តឹងនៅជុំវិញសាលាឧទ្ធរណ៍ ដែលមានមន្ត្រីនគរបាលកងរាជអាវុធហត្ថ និងកងសន្តិសុខរាប់សិបនាក់ឈរយាមកាម។ ច្រកចូលតុលាការត្រូវបានបិទ ដោយរាំងមិនឱ្យសាធារណជន និងប្រព័ន្ធផ្សព្វផ្សាយចូលទៅក្នុងអគារតុលាការទេ។

យោងតាមអង្គការលីកាដូ នគរបាលពាក់ឯកសណ្ឋាន និងស្លៀកស៊ីវិល និងកងសន្តិសុខ ត្រូវបានដាក់ពង្រាយនៅតុលាការ។

## ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៤ ភ្នំពេញ

កាលពីថ្ងៃទី៤ ខែមករា ឆ្នាំ២០២៤ អ្នកសារព័ត៌មានម្នាក់របស់អង្គភាព Luos Seng News ត្រូវបាននគរបាលព្រំដែនហាមមិនឱ្យយកព័ត៌មាននៅច្រកទ្វារព្រំដែនបាវិត ក្នុងខេត្តស្វាយរៀង ដែលជាកន្លែងដឹកជញ្ជូនទំនិញឆ្លងកាត់រវាងកម្ពុជា និងវៀតណាម។ លោកបានបន្តថា៖ «ពេលខ្ញុំទៅដល់ទីនោះ ខ្ញុំមិនទាន់បានថតរូប ឬវីដេអូនៅឡើយទេ ប៉ុន្តែនៅពេលនោះ មាននគរបាល ប្រហែល៧នាក់បានមកដល់ ហើយសួរថាតើខ្ញុំមានលិខិតអនុញ្ញាតដើម្បីយកព័ត៌មានឬអត់?»

លោកបានបន្ថែមថា៖ «នគរបាលគ្រាន់តែប្រាប់ខ្ញុំថា អ្នកសារព័ត៌មានមិនត្រូវបានអនុញ្ញាតឱ្យចូលទៅយកព័ត៌មាននៅទីនោះទេ»។

**រាយការណ៍អំពីករណីនៃការយាយី ៖**

+៨៥៥ ១០ ៨៨២ ៣១១ (តេឡេក្រាម)

feedback@camboja.net

ផ្ទះលេខ១៩ ផ្លូវ៣៨៨ សង្កាត់ទួលស្វាយព្រៃ១
ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ

www.camboja.net